# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ទសកនិបាត

## ភាគ ៥០

ពុទ្ធសករាជ ២៥៥៣

អធិប្បាយ

ទសកនិបាត មាន ២ បណ្ណាសកៈ

ចែកជា ១០ វគ្គ មាន ១០០ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ៨៥ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ទសកនិបាត

## ភាគ ៥០

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ទសកនិបាត មាន ២ បណ្ណាសកៈ

ចែកជា ១០ វគ្គ មាន ១០០ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ៨៥ សូត្រ

# អង្គុត្តរនិកាយ ទសកនិបាត

## រួមមាន

### ២ បណ្ណាសកៈ មាន ១០ វគ្គ

### សរុបមាន ១០០ សូត្រ

## ព្រះអដ្ឋកថាកែសេចក្តី ៨៥ សូត្រ

**បឋមបណ្ណាសកៈ**

| | | | |
|---|---|---|---|
| ១ | អានិសង្សវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ០៨ សូត្រ |
| ២ | នាថករណាវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ១០ សូត្រ |
| ៣ | មហាវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ១០ សូត្រ |
| ៤ | ឧបាលិវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ០៧ សូត្រ |
| ៥ | អក្កោសវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ០៧ សូត្រ |

**ទុតិយបណ្ណាសកៈ**

| | | | |
|---|---|---|---|
| ១ | សចិត្តវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ០៦ សូត្រ |
| ២ | យមកវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ០៩ សូត្រ |
| ៣ | អាកង្ខវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ០៨ សូត្រ |
| ៤ | ថេរវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ១០ សូត្រ |
| ៥ | ឧបាសកវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ១០ សូត្រ |

# ស្រៈនិងស្យ៉យ

## *Signes et accents:*



# ស្រះពេញតួ
## *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូប Romain | *a* | *.ā* | *i* | *i* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | [illegible] | [illegible] | [illegible] | [illegible] | ເ | [illegible] |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

## *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡាតាំង Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ᨠ | ᨡ | ᨣ | ᨥ | ᨦ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡាតាំង Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ဉ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម<br>Romain | c | ch | j | jh | ñ |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡាតាំង Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ឈ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

## ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី*

រីកពាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ

សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់

ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ពាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសិរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍- សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជួសជុលវត្តនៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុឋៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្តាប់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់ លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន ឧបាសក ឆាក់ម៉ៅ

ឧបាសក ឌុំ ធួន ឧបាសក ហុកសីង់ហួត

ឧបាសក ជីម ជំនិត ឧបាសក កើត និត្យ

ឧបាសក សន ម៉ារឌី ឧបាសក ហាយ ចំរើន

ឧបាសក អ៊ុម វ៉ៃយ៉ា ឧបាសក សុក្រ ហ៊ត

ឧបាសក សោម រតនៈ ឧបាសក សំ ឆាយ

ឧបាសក ម៉ៅ ឌុន ឧបាសក ជា ស៊ីថាន

ឧបាសិកា ថាប់ លឿម ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា ប៊ុត សុម៉ាលី ឧបាសិកា យស សម្បត្តិ

ឧបាសិកា ពូ ហ៊ាង ឧបាសិកា ប៊ុត សេដាដួង

ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិន្នោ | ឆូវ ប៊ូ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ដុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ធាវ ធាន | ធម្មាចារ្យ |

សាមណេរ កោវិនោ ឡោះសូវៀត សមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជឹម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ–

ឧទ្ទិសថ្វាយ និងគោរពជូនៈ

–ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

–ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

–សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

–មាតាបិតានៃយើងទាំងអស់គ្នា

–លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

–លោកគ្រូធម្មបណ្ឌិត រស់ សុជាត

–សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

–សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ៕.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | | ទំព័រ |
|---|---|---|
| **ទសកនិបាត បឋមបណ្ណាសកៈ** | | |
| **អានិសង្សវគ្គ ទី ១** | | |
| អដ្ឋកថា កិមត្ថិយសូត្រ | ទី ១ | ១ |
| អដ្ឋកថា ចេតនាសូត្រ | ទី ២ | ៣ |
| អដ្ឋកថា សីលសូត្រ | ទី ៣ | ៤ |
| អដ្ឋកថា ឧបនិសាសូត្រ | ទី ៤ | ៥ |
| អដ្ឋកថា អានន្ទសូត្រ | ទី ៥ | ៦ |
| អដ្ឋកថា សមាធិសូត្រ | ទី ៦ | ៧ |
| អដ្ឋកថា សារីបុត្តសូត្រ | ទី ៧ | ៩ |
| អដ្ឋកថា សទ្ធាសូត្រ | ទី ៨ | ១០ |
| អដ្ឋកថា សន្តសូត្រ | ទី ៩ | ១១ |
| អដ្ឋកថា វិជ្ជយសូត្រ | ទី ១០ | ១២ |
| **នាថករណវគ្គ ទី ២** | | |
| អដ្ឋកថា សេនាសនសូត្រ | ទី ១ | ១៣ |
| អដ្ឋកថា អង្គសូត្រ | ទី ២ | ១៥ |
| អដ្ឋកថា សំយោជនសូត្រ | ទី ៣ | ១៦ |
| អដ្ឋកថា ខីលសូត្រ | ទី ៤ | ១៧ |
| អដ្ឋកថា អប្បមាទសូត្រ | ទី ៥ | ១៨ |
| អដ្ឋកថា អាហុនេយ្យសូត្រ | ទី ៦ | ២១ |
| អដ្ឋកថា បឋមនាថសូត្រ | ទី ៧ | ២២ |
| អដ្ឋកថា ទុតិយនាថសូត្រ | ទី ៨ | ២៦ |
| អដ្ឋកថា បឋមអរិយវាសសូត្រ | ទី ៩ | ២៧ |
| អដ្ឋកថា ទុតិយអរិយវាសសូត្រ | ទី ១០ | ២៨ |

**មហាវគ្គ ទី ៣**


| | | | |
|---|---|---|---|
| អដ្ឋកថា សីហសូត្រ | ទី ១ | | ៣២ |
| អដ្ឋកថា អធិមុត្តិសូត្រ | ទី ២ | | ៥១ |
| អដ្ឋកថា កាយសូត្រ | ទី ៣ | | ៥៤ |
| អដ្ឋកថា មហាចុន្ទសូត្រ | ទី ៤ | | ៥៦ |
| អដ្ឋកថា កសិណសូត្រ | ទី ៥ | | ៥៧ |
| អដ្ឋកថា កាឡីសូត្រ | ទី ៦ | | ៦០ |
| អដ្ឋកថា បឋមមហាបញ្ហាសូត្រ | ទី ៧ | | ៦៣ |
| អដ្ឋកថា ទុតិយមហាបញ្ហាសូត្រ | ទី ៨ | | ៧១ |
| អដ្ឋកថា បឋមកោសលសូត្រ | ទី ៩ | | ៧៣ |
| អដ្ឋកថា ទុតិយកោសលសូត្រ | ទី ១០ | | ៧៨ |


**ឧបាលិវគ្គ ទី ៤**


| | | | |
|---|---|---|---|
| អដ្ឋកថា បឋមឧបាលិសូត្រ | ទី ១ | | ៨៤ |
| អដ្ឋកថា ទុតិយឧបាលិសូត្រ | ទី ២ | | ៩១ |
| អដ្ឋកថា ឧព្វាហសូត្រ | ទី ៣ | | ៩២ |
| អដ្ឋកថា ឧបសម្បទាសូត្រ | ទី ៤ | | ៩៤ |
| អដ្ឋកថា និស្សយសូត្រ | ទី ៥ | មិនមានអដ្ឋកថា | ៩៥ |
| អដ្ឋកថា សាមណេរសូត្រ | ទី ៦ | មិនមានអដ្ឋកថា | ៩៦ |
| អដ្ឋកថា ឧបាលិសង្ឃភេទសូត្រ | ទី ៧ | | ៩៧ |
| អដ្ឋកថា ឧបាលិសាមគ្គីសូត្រ | ទី ៨ | មិនមានអដ្ឋកថា | ៩៨ |
| អដ្ឋកថា អានន្ទសង្ឃភេទសូត្រ | ទី ៩ | | ៩៩ |
| អដ្ឋកថា អានន្ទសាមគ្គីសូត្រ | ទី ១០ | | ១០០ |


**អក្កោសវគ្គ ទី ៥**


| | | | |
|---|---|---|---|
| អដ្ឋកថា វិវាទសូត្រ | ទី ១ | មិនមានអដ្ឋកថា | ១០១ |
| អដ្ឋកថា បឋមវិវាទមូលសូត្រ | ទី ២ | មិនមានអដ្ឋកថា | ១០២ |
| អដ្ឋកថា ទុតិយវិវាទមូលសូត្រ | ទី ៣ | មិនមានអដ្ឋកថា | ១០៣ |
| អដ្ឋកថា កុសិនារាសូត្រ | ទី ៤ | | ១០៤ |
| អដ្ឋកថា បវេសនសូត្រ | ទី ៥ | | ១០៧ |

| | | | |
|---|---|---|---|
| អដ្ឋកថា សក្កសូត្រ | ទី ៦ | | ១០៨ |
| អដ្ឋកថា មហាលិសូត្រ | ទី ៧ | | ១១១ |
| អដ្ឋកថា អភិណ្ហាប្ប...សូត្រ | ទី ៨ | | ១១២ |
| អដ្ឋកថា សីរវឌ្ឍធម្មសូត្រ | ទី ៩ | | ១២០ |
| អដ្ឋកថា កណ្ឌូនសូត្រ | ទី ១០ | | ១២១ |


# ទុតិយបណ្ណាសកៈ

## សចិត្តវគ្គ ទី ១


| | | | |
|---|---|---|---|
| អដ្ឋកថា សចិត្តសូត្រ | ទី ១ | | ១២២ |
| អដ្ឋកថា សារីបុត្តសូត្រ | ទី ២ | មិនមានអដ្ឋកថា | ១២៣ |
| អដ្ឋកថា ឋិតិសូត្រ | ទី ៣ | | ១២៤ |
| អដ្ឋកថា សមថសូត្រ | ទី ៤ | | ១២៥ |
| អដ្ឋកថា បរិហានសូត្រ | ទី ៥ | មិនមានអដ្ឋកថា | ១២៦ |
| អដ្ឋកថា បឋមសញ្ញាសូត្រ | ទី ៦ | មិនមានអដ្ឋកថា | ១២៧ |
| អដ្ឋកថា ទុតិយសញ្ញាសូត្រ | ទី ៧ | មិនមានអដ្ឋកថា | ១២៨ |
| អដ្ឋកថា មូលសូត្រ | ទី ៨ | | ១២៩ |
| អដ្ឋកថា បព្វជិតសូត្រ | ទី ៩ | | ១៣០ |
| អដ្ឋកថា អាពាធសូត្រ | ទី ១០ | | ១៣២ |


## យមកវគ្គ ទី ២


| | | | |
|---|---|---|---|
| អដ្ឋកថា អវិជ្ជាសូត្រ | ទី ១ | | ១៣៤ |
| អដ្ឋកថា តណ្ហាសូត្រ | ទី ២ | | ១៣៥ |
| អដ្ឋកថា និដ្ឋាសូត្រ | ទី ៣ | | ១៣៦ |
| អដ្ឋកថា អវេច្ចសូត្រ | ទី ៤ | | ១៣៧ |
| អដ្ឋកថា បឋមសុខសូត្រ | ទី ៥ | | ១៣៨ |
| អដ្ឋកថា ទុតិយសុខសូត្រ | ទី ៦ | | ១៣៩ |
| អដ្ឋកថា បឋមនឡកបានសូត្រ | ទី ៧ | | ១៤០ |
| អដ្ឋកថា ទុតិយនឡកសូត្រ | ទី ៨ | មិនមានអដ្ឋកថា | ១៤២ |

| | | | |
|---|---|---|---|
| អដ្ឋកថា បឋមវត្ថុកថាសូត្រ | ទី ៩ | | ១៤៣ |
| អដ្ឋកថា ទុតិយវត្ថុកថាសូត្រ | ទី ១០ | | ១៤៩ |


**អាកង្ខវគ្គ ទី ៣**


| | | | |
|---|---|---|---|
| អដ្ឋកថា អាកង្ខសូត្រ | ទី ១ | | ១៥០ |
| អដ្ឋកថា កណ្ដកសូត្រ | ទី ២ | | ១៥៩ |
| អដ្ឋកថា ឥដ្ឋសូត្រ | ទី ៣ | | ១៦០ |
| អដ្ឋកថា វឌ្ឍិសូត្រ | ទី ៤ | | ១៦១ |
| អដ្ឋកថា មិគសាលាសូត្រ | ទី ៥ | | ១៦២ |
| អដ្ឋកថា អភព្វសូត្រ | ទី ៦ | មិនមានអដ្ឋកថា | ១៦៧ |
| អដ្ឋកថា កាកសូត្រ | ទី ៧ | | ១៦៨ |
| អដ្ឋកថា និគណ្ឋសូត្រ | ទី ៨ | មិនមានអដ្ឋកថា | ១៦៩ |
| អដ្ឋកថា អាឃាតវត្ថុសូត្រ | ទី ៩ | | ១៧០ |
| អដ្ឋកថា អាឃាតបដិវិនិយសូត្រ | ទី ១០ | មិនមានអដ្ឋកថា | ១៧១ |


**ថេរវគ្គ ទី ៤**


| | | | |
|---|---|---|---|
| អដ្ឋកថា វាហុនសូត្រ | ទី ១ | | ១៧២ |
| អដ្ឋកថា អានន្ទសូត្រ | ទី ២ | មិនមានអដ្ឋកថា | ១៧៣ |
| អដ្ឋកថា បុណ្ណិយសូត្រ | ទី ៣ | | ១៧៤ |
| អដ្ឋកថា ព្យាករណសូត្រ | ទី ៤ | | ១៧៥ |
| អដ្ឋកថា កត្ថីសូត្រ | ទី ៥ | | ១៧៦ |
| អដ្ឋកថា អញ្ញសូត្រ | ទី ៦ | | ១៧៧ |
| អដ្ឋកថា អធិករណសូត្រ | ទី ៧ | | ១៧៨ |
| អដ្ឋកថា ព្យសនសូត្រ | ទី ៨ | | ១៨០ |
| អដ្ឋកថា កោកាលិកសូត្រ | ទី ៩ | | ១៨១ |
| អដ្ឋកថា ពលសូត្រ | ទី ១០ | មិនមានអដ្ឋកថា | ១៩២ |


**អានិសង្សវគ្គ ទី ៥**


| | | | |
|---|---|---|---|
| អដ្ឋកថា កាមភោគីសូត្រ | ទី ១ | | ១៩៣ |
| អដ្ឋកថា វេរសូត្រ | ទី ២ | | ១៩៤ |

| | | | |
|---|---|---|---|
| អដ្ឋកថា ទិដ្ឋិសូត្រ | ទី ៣ | | ១៩៦ |
| អដ្ឋកថា វឌ្ឍិយសូត្រ | ទី ៤ | | ១៩៧ |
| អដ្ឋកថា ឧត្តិយសូត្រ | ទី ៥ | | ២០០ |
| អដ្ឋកថា កោកនុទសូត្រ | ទី ៦ | | ២០៣ |
| អដ្ឋកថា អាហុនេយ្យសូត្រ | ទី ៧ | | ២០៦ |
| អដ្ឋកថា ថេរសូត្រ | ទី ៨ | | ២០៧ |
| អដ្ឋកថា ឧចាលិសូត្រ | ទី ៩ | | ២០៨ |
| អដ្ឋកថា អភព្វសូត្រ | ទី ១០ | មិនមានអដ្ឋកថា | ២១២ |

# បឋមបណ្ណាសកៈ

## អានិសង្សវគ្គវណ្ណនាទី ១

## អដ្ឋកថា កិមត្ថិយសូត្រទី ១

### *ផលរបស់សីលដែលជាកុសល*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កិមត្ថិយសូត្រទី ១ ដូចតទៅនេះ ៖*

[១] *បទថា* ***កុសលានិ សីលានិ*** *(សីលដែលជាកុសល) បាន ដល់ សីលដែលមិនមានទោស ។ សីល ឈ្មោះថា* **មានការមិនក្តៅក្រហាយ ជាផល** *ក៏ព្រោះប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ភាពជាអ្នកមិនស្តាយក្រោយ ការមិនក្តៅក្រហាយ ។ ឈ្មោះថា* **មានការមិនក្តៅក្រហាយជាអានិសង្ស** *ក៏ព្រោះសីលនោះ មានការមិនក្តៅក្រហាយនោះឯងជាអានិសង្ស ។ ក្នុងបទ ថា* ***យថាភូតញ្ញាណទស្សនត្ថោ*** *(មានយថាភូតញ្ញាណទស្សនៈជាផល) ជា ដើម វិបស្សនាទន់ខ្ចី ឈ្មោះថា* ***យថាភូតញ្ញាណទស្សនៈ*** *វិបស្សនាមាន កម្លាំង ឈ្មោះថា* ***និព្វិទា*** *។ មគ្គ ឈ្មោះថា* ***វិរាគៈ*** *។ អរហត្តផល ឈ្មោះ*

ថា *វិមុត្តិ* ។ បច្ចវេក្ខណញាណ ឈ្មោះថា *ញាណទស្សនៈ* ។ បទថា *អរហត្តាយ បូរេន្តិ* (រមែងដល់អរហត្ត) បានដល់ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ព្រះអរហត្ត ។

ចប់អដ្ឋកថា កិមត្ថិយសូត្រទី ១

# អដ្ឋកថា ចេតនាសូត្រទី ២

## *មិនចាំបាច់តាំងចេតនាឲ្យកើតអវិប្បដិសារៈ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចេតនាសូត្រទី ២ ដូចតទៅនេះ ៖*

[២] *បទថា* ***ន ចេតនាយ ករណីយំ*** *(មិនចាំបាច់ធ្វើចេតនា) បានដល់ មិនគិតនឹងកំណត់ធ្វើ ។ បទថា* ***ធម្មតា ឯសា*** *(នេះជាធម្មតា) បានដល់ នោះជាសភាវធម៌ នេះជានិយាមនៃហេតុ ។ បទថា* ***អភិសន្ទេន្តិ*** *(រមែងហូរ) បានដល់ ឲ្យប្រព្រឹត្តទៅ ។ បទថា* ***បរិបូរេន្តិ*** *(ឲ្យបរិបូរ) បានដល់ ធ្វើឲ្យបរិបូរណ៌ ។ បទថា* ***អបារាបារំ គមនាយ*** *(ចាកទីមិនមែនត្រើយ ទៅដល់ត្រើយ) បានដល់ ដើម្បីប្រយោជន៍ដល់ការទៅកាន់ត្រើយនាយ គឺ ព្រះនិព្វាន ចាកវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាត្រើយអាយ ។*

ចប់អដ្ឋកថា ចេតនាសូត្រទី ២

# អដ្ឋកថា សីលសូត្រទី ៣

## *អវិប្បដិសារៈមិនមានដល់អ្នកទ្រុស្តសីល*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សីលសូត្រទី ៣ ដូចតទៅនេះ ៖*

[៣] *បទថា ហតូបនិសោ (ឈ្មោះថាមានហេតុ... កម្ចាត់ហើយ) សេចក្ដីថា និព្វិទា និងវិរាគៈ មានហេតុត្រូវកម្ចាត់ចេញហើយ ។*

ចប់អដ្ឋកថា សីលសូត្រទី ៣

# អដ្ឋកថា ឧបនិសាសូត្រទី ៤

*អវិប្បដិសារៈ បុគ្គលទ្រុស្តសីលកម្ចាត់ចេញហើយ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបនិសាសូត្រទី ៤ ដូចតទៅនេះ ៖*

*[៤] ក្នុងឧបនិសាសូត្រទី ៤ និងអានន្ទសូត្រទី ៥ មានសេចក្តីផ្សេងគ្នាត្រង់ពាក្យដែលព្រះថេរៈទាំងពីរ (គឺព្រះសារីបុត្រ និងព្រះអានន្ទ) ពោលទុកប៉ុណ្ណោះ ។*

ចប់អដ្ឋកថា ឧបនិសាសូត្រទី ៤

# អដ្ឋកថា អានន្ទសូត្រទី ៥

*អវិប្បដិសារៈមិនមានដល់បុគ្គលទ្រុស្តសីល*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អានន្ទសូត្រទី ៥ ដូចតទៅនេះ ៖*

[៥] *ក្នុងឧបនិសាសូត្រទី ៤ និងអានន្ទសូត្រទី ៥ មានសេចក្តីផ្សេងគ្នាត្រង់ពាក្យដែលព្រះថេរៈទាំងពីរ (គឺព្រះសារីបុត្រ និងព្រះអានន្ទ)ពោលទុកប៉ុណ្ណោះ ។*

ចប់អដ្ឋកថា អានន្ទសូត្រទី ៥

# អដ្ឋកថា សមាធិសូត្រទី ៦

## មិនគប្បីសម្គាល់ថា ដីក្នុងដីជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុង សមាធិសូត្រទី ៦ ដូចតទៅនេះ ៖

[៦] បទថា **នេវ បឋវិយំ បឋវីសញ្ញី អស្ស** (មិនគប្បីសម្គាល់ថា ដីក្នុងដី) សេចក្តីថា ខ្ជួនធ្វើបឋវីធាតុឲ្យជាអារម្មណ៍ហើយ មិនគប្បីមានការសម្គាល់ ដោយការសម្គាល់យ៉ាងនេះថា បឋវីធាតុ ។ ក្នុងអាបោធាតុជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា **ន ឥធលោកេ** (មិន... ក្នុងលោកនេះ) សេចក្តីថា មិនគប្បីមានការសម្គាល់ ដោយការសម្គាល់ថា ជាឈាន ៤ ឈាន ៥ នឹងកើតឡើងក្នុងលោកនេះ ។ បទថា **ន បរលោកេ** (មិន... ក្នុងលោកដទៃ) សេចក្តីថា មិនគប្បីមានការសម្គាល់ ដោយការសម្គាល់ថា ឈាន ៤ ឈាន ៥ នឹងកើតក្នុងលោកខាងមុខ ។ បទថា **សញ្ញី ច បន អស្ស** (ប៉ុន្តែថា គប្បីជាអ្នកមានសញ្ញា) សេចក្តីថា ប៉ុន្តែថា ម្យ៉ាងទៀត គប្បីមានសមាបត្តិ គឺ គប្បីមានសមាបត្តិដែលមានវិតក្កៈនោះឯង ព្រោះហេតុនោះ លោកទើបពោលទុក ។

*បទថា ឯតំ សន្តំ ឯតំ បណីតំ (នោះស្ងប់ នោះប្រណីត) សេចក្តីថា ចិត្តុប្បាទរបស់បុគ្គលអង្គុយកំណត់ថា ស្ងប់ ស្ងប់ ក៏រមែងប្រព្រឹត្តទៅថា ស្ងប់ ស្ងប់ នោះឯង រហូតអស់ថ្ងៃ ចិត្តុប្បាទរបស់បុគ្គលអង្គុយកំណត់ថា ប្រណីត ប្រណីត ក៏រមែងប្រព្រឹត្តទៅថា ប្រណីត ប្រណីតនោះឯង រហូតអស់ថ្ងៃ ។ បទថា **យទិទំ សព្វសង្ខារសមថោ** (ស្ងប់សង្ខារទាំងពួង) សេចក្តីថា ចិត្តុប្បាទរបស់បុគ្គលអង្គុយកំណត់ថា ការស្ងប់សង្ខារទាំងពួង ការស្ងប់សង្ខារទាំងពួង ថា និព្វាន និព្វាន ក៏រមែងប្រព្រឹត្តទៅថា និព្វាន និព្វាននោះឯង រហូតអស់ថ្ងៃ ។ ក៏ពាក្យទាំងអស់នោះ លោកពោលសំដៅយកសមាធិដែលជាផលសមាបត្តិ ។*

ចប់អដ្ឋកថា អានន្ទសូត្រទី ៦

# អដ្ឋកថា សារីបុត្តសូត្រទី ៧

## មិនគប្បីសម្គាល់ថា ដីក្នុងដីជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុង សមាធិសូត្រទី ៦ ដូចតទៅនេះ ៖

[៧] បទថា សញ្ញី ច បនាហំ អាវុសោ តស្មឹ សមយេ អហោសឹ (លោកដ៏មានអាយុ ក៏ក្នុងសម័យនោះ ផលដែលមានសញ្ញា) សេចក្តីថា លោកដ៏មានអាយុ ក្នុងសម័យនោះ ផលដែលមានការសម្គាល់ ដោយការសម្គាល់ថា ជាផលសមាបត្តិនេះថា ការរលត់ភព ជានិព្វាន ដូច្នេះ លោកពោលការពិចារណាទុកថា សមាបត្តិនោះ ឈ្មោះថា ប្រព្រឹត្តទៅជាមួយចិត្ត យ៉ាងដូច្នេះ ។

ចប់អដ្ឋកថា សារីបុត្តសូត្រទី ៧

# អដ្ឋកថា សទ្ធាសូត្រទី ៨

## ភិក្ខុមានសទ្ធាជាដើម រមែងឲ្យកើតការជ្រះថ្លាដោយជុំវិញ

គប្បីជ្រាបវិនិច្ឆ័យក្នុង សទ្ធាសូត្រទី ៨ ដូចតទៅនេះ ៖

[៨] បទថា *សមន្តបាសាទិកោ* (ជាអ្នកឲ្យកើតសេចក្តីជ្រះថ្លាដោយជុំវិញ) សេចក្តីថា នាំមកនូវសេចក្តីជ្រះថ្លាដោយជុំវិញ ដោយប្រការទាំងពួងនៃការធ្វើ មានការធ្វើតាមកាយជាដើម ដែលនាំមកនូវសេចក្តីជ្រះថ្លានោះឯង ។ បទថា *សព្វាការបរិបូរោ* (ជាអ្នកបរិបូរដោយអាការទាំងពួង) បានដល់ បរិបូរណ៍ហើយដោយហេតុទាំងអស់ ។

ចប់អដ្ឋកថា សទ្ធាសូត្រទី ៨

# អដ្ឋកថា សន្តសូត្រទី ៩

## *ភិក្ខុប្រកបដោយធម៌ ១០ រមែងឲ្យកើតសេចក្តីជ្រះថ្លា*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សន្តសូត្រទី ៩ ដូចតទៅនេះ ៖*

[៩] *បទថា **សន្តា** (ស្ងប់) បានដល់ ស្ងប់ ព្រោះមានអារម្មណ៍ស្ងប់ខ្ទះ ព្រោះមានអង្គស្ងប់ខ្ទះ ។ ដែលបានឈ្មោះយ៉ាងនេះថា **វិមោក្ខ** ក៏ព្រោះរួចផុតចាកធម៌ដែលជាសត្រូវ និងព្រោះរួចផុតដោយល្អ ដោយប្រាសចាកសេចក្តីសង្ស័យក្នុងអារម្មណ៍ ។ បទថា **អតិក្កម្ម រូបេ** (ព្រោះកន្លងរូបចេញបាន) បានដល់ កន្លងរូបឈាន ហើយប្រព្រឹត្តទៅ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា សន្តសូត្រទី ៩

# អដ្ឋកថា វិជ្ជយសូត្រទី ១០

*ភិក្ខុប្រកបដោយធម៌ ១០ រមែងឲ្យកើតសេចក្តីជ្រះថ្លា*

[១០] *សូត្រទី ១០ នេះ មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា វិជ្ជយសូត្រទី ១០

## ចប់អានិសង្សវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# នាថករណវគ្គវណ្ណនាទី ២

## អដ្ឋកថា សេនាសនសូត្រទី ១

### *ភិក្ខុប្រកបដោយអង្គ ៥ សេពសេនាសនៈប្រកបដោយអង្គ ៥ គប្បីលះអាសវៈក្នុងវេលាមិនយូរ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សេនាសនៈសូត្រទី ១ ដូចតទៅនេះ ៖*

[១១] *បទថា* ***បញ្ចង្គសមន្នាគតោ*** *(បុគ្គលប្រកបដោយអង្គ ៥) បានដល់ អ្នកប្រកបដោយអង្គគុណ ៥ ។ បទថា* ***នាតិទូរំ ហោតិ នាច្ចាសន្នំ*** ***(នៅមិនឆ្ងាយពេក មិនជិតពេក)*** *សេចក្តីថា ទីកន្លែងណាឆ្ងាយពេក ភិក្ខុត្រាច់បិណ្ឌបាតទៅក្នុងទីកន្លែងនោះ ក៏មានសេចក្តីលំបាកកាយ និងចិត្ត លោកក៏ធ្វើសមាធិដែលនៅមិនកើតឲ្យកើតឡើងមិនបាន ឬធ្វើសមាធិដែលកើតហើយឲ្យតាំងមាំមិនបាន ទីជិតពេកក៏ច្រើនទៅដោយមនុស្ស ។ ឯទីកន្លែងដែលផុតចាកទោសទាំងពីរនោះ ក្នុងប្រទេសប្រមាណ ៤០០ ឧសភៈ ក៏ឈ្មោះថា ដល់ព្រមដោយការគមនាគមន៍ ។ បទថា* ***ទិវា អបកិណ្ណំ*** ***(ពេលថ្ងៃ***

*មិនអ៊ូអរ)* បានដល់ មិនកុះករដោយមនុស្សច្រើន ក្នុងវេលាពេលថ្ងៃ ។

ចប់អដ្ឋកថា សេនាសនសូត្រទី ១

# អដ្ឋកថា អង្គសូត្រទី ២

## *ភិក្ខុលះអង្គ ៥ ប្រកបដោយអង្គ ៥ ជាឧត្តមបុរស*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អង្គសូត្រទី ២ ដូចតទៅនេះ ៖*

[១២] *បទថា* ***កេវលី*** *ប្រែថា អ្នកប្រកបដោយគុណទាំងអស់ ។ បទថា* ***វុសិតវា*** *ប្រែថា អ្នកនៅព្រហ្មចរិយៈចប់ហើយ ។ បទថា* ***អសេក្ខេន*** *(ជារបស់ព្រះអសេក្ខៈ) បានដល់ លោកុត្តរធម៌ដែលរាប់បញ្ចូលក្នុងអសេក្ខធម៌ ។ បទថា* ***សីលក្ខន្ធេន*** *(ដោយសីលក្ខន្ធ) បានដល់ ដោយកងនៃសីល ។ ក្នុងបទថា* ***វិមុត្តិក្ខន្ធេន*** *(ដោយវិមុត្តិក្ខន្ធ) នេះ វៀរសីលជាដើមចេញ ផលធម៌ដ៏សេសទាំង ៣ ឈ្មោះថា វិមុត្តិ ។ វិមុត្តិញាណទស្សនៈ ឈ្មោះថា បច្ចវេក្ខណញ្ញាណ ។ បច្ចវេក្ខណញ្ញាណនោះ ជាលោកិយៈតែម្យ៉ាង ។*

ចប់អដ្ឋកថា អង្គសូត្រទី ២

# អដ្ឋកថា សញ្ញោជនសូត្រទី ៣

## *សំយោជនៈ ១០ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សញ្ញោជនសូត្រទី ៣ ដូចតទៅនេះ ៖*

*[១៣] បទថា **ឱរម្ភាគិយានិ** (ប្រព្រឹត្តទៅក្នុងចំណែកខាងក្រោម) បានដល់ ជាចំណែកខាងក្រោម ។ បទថា **ឧទ្ធម្ភាគិយានិ** (ប្រព្រឹត្តទៅក្នុងចំណែកខាងលើ) បានដល់ ជាចំណែកខាងលើ ។ ក្នុងសូត្រនេះ លោកពោលវដ្តៈតែម្យ៉ាង ។*

ចប់អដ្ឋកថា សញ្ញោជនសូត្រទី ៣

# អដ្ឋកថា ខីលសូត្រទី ៤

## *ភាពរឹងត្អឹងនៃចិត្ត ៥ ចំណងរបស់ចិត្ត ៥*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ខីលសូត្រទី ៤ ដូចតទៅនេះ ៖*

[១៤] *កិលេសជាចម្រឹងនៃចិត្តដូចជាដែកគោល ពោលទុកពិស្តារហើយក្នុងបញ្ចកនិបាត ។ បទថា **អារោហបរិណាហេន** (ដោយចំណែកវែង និងធំ) បានដល់ ដោយចំណែកវែង និងធំ ។*

ចប់អដ្ឋកថា ខីលសូត្រទី ៤

# អដ្ឋកថា អប្បមាទសូត្រទី ៥

## ការមិនប្រមាទជាកំពូលនៃកុសលធម៌

គប្បីជ្រាបវិនិច្ឆ័យក្នុង អប្បមាទសូត្រទី ៥ ដូចតទៅនេះ ៖

[១៥] បទថា *ឯវមេវ ខោ* (ដូច្នោះឯង) សេចក្ដីថា ការមិនប្រមាទជាហេតុឲ្យធ្វើកុសល គប្បីឃើញថា ជាកំពូលនៃកុសលធម៌គ្រប់យ៉ាង ដូចព្រះសម្មាសម្ពុទ្ធ ទ្រង់ជាកំពូលនៃសត្វទាំងពួង ដូច្នោះ ។ សួរថា ក៏ការមិនប្រមាទនោះជាលោកិយៈ ចំណែកកុសលធម៌ទាំងឡាយ ជាលោកុត្តរៈក៏មាន ក៏ការមិនប្រមាទនេះជាកាមាវចរៈតែម្យ៉ាង ចំណែកកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅក្នុងភូមិ ៤ មិនមែនឬ ក៏ការមិនប្រមាទនេះ ជាកំពូលនៃកុសលធម៌ពួកនោះបានយ៉ាងណា ។ ឆ្លើយថា ព្រោះអត្ថថា ជាហេតុឲ្យបាន ។ ពិតណាស់ កុសលធម៌ទាំងនោះ បុគ្គលរមែងបានដោយសេចក្ដីមិនប្រមាទ ព្រោះដូច្នោះ សេចក្ដីមិនប្រមាទនោះ ទើបឈ្មោះថា ជាកំពូលនៃកុសលធម៌នោះឯង ព្រោះហេតុនោះ ទើបត្រាស់ថា កុសលធម៌ទាំងអស់នោះ មានសេចក្ដីមិនប្រមាទជាមូល ។ បទថា ជង្គលានំ (ដែលត្រាច់ទៅ

លើផែនដី) បានដល់ អ្នកសញ្ចរទៅរហូតផុតផែនដី ។ បទថា **បាណានំ** បានដល់ សត្វមានជើង ។ បទថា **បទជាតានិ** ប្រែថា ស្នាមជើង ។ បទថា **សមោធានំ គច្ឆន្តិ** (រមែងដល់ការរួមចុះ) បានដល់ រមែងរួមចុះ គឺ ដាក់ចុះ ។ បទថា **អគ្គមក្ខាយតិ** (ពោលថាជាកំពូល) បានដល់ លោកពោលថា ប្រសើរ ។ បទថា **យទិទំ ហន្តត្តេន** (ព្រោះជារបស់ធំ) សេចក្តីថា លោកពោលថា ជាកំពូលលើស ព្រោះជាស្នាមជើងធំ មិនមែនពោលដោយគុណ ។ បទថា **វស្សិកំ** ប្រែថា ផ្កាម្លិះ ។ គេថា ព្រះរាជាភាតិ-យមហារាជ ទ្រង់ស្តាប់ព្រះសូត្រនេះហើយ ទ្រង់បំណាងនឹងសាកល្បង ទើបឲ្យយកផ្កាឈើក្រអូបមក ដោយរបស់ក្រអូប ៤ ប្រភេទដាក់ក្នុងបន្ទប់មួយៗ ដាក់ផ្កាម្លិះមួយក្តាប់ទុកត្រង់កណ្តាលបន្ទប់ ធ្វើផ្កាឈើដ៏សេសមួយក្តាប់ ៗ ទុកជុំវិញផ្កាម្លិះនោះ ហើយទ្រង់បិទទ្វារ ស្តេចក៏ចេញទៅខាងក្រៅ កាលទ្រង់សម្រាកខាងក្រៅមួយស្របក់ហើយ ទ្រង់បើកទ្វារស្តេចចូលទៅ ក្លិនផ្កាម្លិះក៏ជះក្លិនខ្ទប់ព្រះនាសិកមុនផ្កាឈើទាំងអស់ ។ ព្រះរាជាទ្រង់ចុះពីក្រឡាបន្ទំត្រង់ផ្ទៃនៃព្រះទែនធំនោះឯង បែរព្រះភក្ត្រទៅកាន់ព្រះមហាចេតិយ ទ្រង់

ថ្វាយបង្គំព្រះចេតិយ ដោយទ្រង់ព្រមទទួលថា ព្រះសម្មាសម្ពុទ្ធកាលត្រាស់ថា ផ្កាម្ទិះជាកំពូលនៃបុប្ផគន្ធជាតិនោះឯង ឈ្មោះថា ត្រាស់ទុកល្អហើយ ។ បទថា កុឌ្ឌរកជាតិ ប្រែថា ព្រះរាជាតូច ។ បាឋៈថា កុដរកជា ដូច្នេះក៏មាន ។

ចប់អដ្ឋកថា អប្បមាទសូត្រទី ៩

# អដ្ឋកថា អាហុនេយ្យសូត្រទី ៦

## *អាហុនេយ្យបុគ្គល ១០ ពួក*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាហុនេយ្យសូត្រទី ៦ ដូចតទៅនេះ ៖*

[១៦] *បទថា គោត្រភូ (លោកជាគោត្រភូ) បានដល់ អ្នកប្រកប ដោយគោត្រភូញាណ ដែលមាននិព្វានជាអារម្មណ៍ ដែលជាវិបស្សនាដល់ នូវទីបំផុតហើយ ។*

ចប់អដ្ឋកថា អាហុនេយ្យសូត្រទី ៦

# អដ្ឋកថា បឋមនាថសូត្រទី ៧

## ធម៌ជាទីពឹង ១០ ប្រការ

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមនាថសូត្រទី ៧ ដូចតទៅនេះ ៖*

*[១៧] បទថា **សនាថា** (ជាអ្នកមានទីពឹង) សេចក្ដីថា មានញាតិ គឺ មានញាតិច្រើន ។ ជនពួកណាធ្វើទីពឹង ហេតុនោះ ជនទាំងនោះឈ្មោះថា អ្នកធ្វើទីពឹង អធិប្បាយថា ធ្វើឲ្យមានទីពឹង គឺ ធ្វើទីពំនាក់ដល់ខ្លួន ។ ក្នុងបទថា **កល្យាណមិត្តោ** (ជាអ្នកមានមិត្តល្អ) ជាដើម ឈ្មោះថា មានកល្យាណមិត្ត ក៏ព្រោះមានមិត្តល្អ ដែលសម្បូរណ៍ដោយសីលជាដើម ។ ឈ្មោះថា មានសម្លាញ់ល្អ ក៏ព្រោះជនទាំងនោះជាសម្លាញ់របស់គេ ព្រោះទៅរួមគ្នាក្នុងឥរិយាបថ មានឈរអង្គុយជាដើម ។ ឈ្មោះថា មានមិត្តល្អ ក៏ព្រោះជាអ្នកឆាកចិត្តទៅតាមមិត្តល្អ ដោយកាយ និងចិត្ត ។*

*បទថា **សុវចោ ហោតិ** (ភិក្ខុជាអ្នកប្រដៅងាយ) សេចក្ដីថា រមែងជាអ្នកដែលគេគប្បីប្រដៅបានងាយ ដែលគេគប្បីទូន្មានបានងាយ ។ បទថា **ខមោ** (ជាអ្នកអត់ទ្រាំ) បានដល់ សូម្បីត្រូវពោលដោយពាក្យគ្រោតគ្រាត*

ពាក្យផ្ទួន់ ក៏អត់ទ្រាំបាន មិនក្រោធ ។ បទថា **បទក្ខិណគ្គាហី អនុសាសនី** **(ទទួលអនុសាសនីដោយគោរព)** សេចក្តីថា មិនធ្វើដូចអ្នកខ្លះ កាលត្រូវលោកឲ្យឱវាទក៏ទទួលយកខាងឆ្វេង (មិនគោរព) តបត ឬមិនស្តាប់ហើយដើរចេញទៅ ដូច្នោះ ទទួលយកខាងស្តាំ គឺ (ដោយគោរព) ដោយពោលថា សូមលោកទូន្មានចុះ បើលោកមិនទូន្មាន អ្នកដទៃណានឹងទូន្មាន ។

បទថា **ឧច្ចាវចានិ** ប្រែថា ទាំងខ្ពស់ទាំងទាប ។ បទថា **កឹករណីយានិ (កិច្ចដែលគួរធ្វើដូចម្តេច)** បានដល់ កិច្ចកម្មដែលសួរយ៉ាងនេះថា ខ្ញុំនឹងធ្វើអ្វី ហើយក៏ធ្វើ ។ បណ្តាកិច្ចកម្មខ្ពស់ទាបទាំងនោះ ឈ្មោះថា កិច្ចកម្មខ្ពស់ បានដល់ កិច្ចកម្ម ដូចជាធ្វើចីវរ ជ្រលក់ចីវរ បូកលាបព្រះចេតិយ កិច្ចកម្មដែលគប្បីធ្វើក្នុងរោងឧបោសថ ផ្ទះព្រះចេតិយ និងផ្ទះព្រះពោធិ៍ ដូច្នេះជាដើម ។ ឈ្មោះថា កិច្ចកម្មទាប បានដល់ កិច្ចកម្មតិចតួច ដូចជាលាងជើង លាបប្រេងជាដើម ។ បទថា **តត្រុបាយាយ (ជាឧបាយក្នុងកិច្ចនោះ)** បានដល់ ដែលប្រព្រឹត្តទៅក្នុងកិច្ចកម្មនោះ ។ បទថា **អលំ កាតុំ (អាចធ្វើ)** បានដល់ ជាអ្នកអាចធ្វើបានឯង ។ បទថា **អលំ សំវិធាតុំ**

(អាចចាត់ចែង) បានដល់ រមែងជាអ្នកអាចចាត់ការបាន ។

ភិក្ខុឈ្មោះថា ជាអ្នកប្រាថ្នាក្នុងធម៌ ព្រោះមានសេចក្តីស្រឡាញ់ធម៌ អធិប្បាយថា រមែងស្រឡាញ់ព្រះត្រៃបិដកពុទ្ធវចនៈ ។ បទថា **បិយសមុទាហារោ** (ជាអ្នកស្តាប់ និងសម្តែងធម៌ដែលជាទីស្រឡាញ់) សេចក្តីថា កាលអ្នកដទៃពោលហើយ ក៏ស្តាប់ដោយគោរព ទាំងខ្លួនឯងក៏ប្រាថ្នានឹងសម្តែងដល់អ្នកដទៃ ។ ក្នុងបទថា **អភិធម្មេ អភិវិនយេ** (ក្នុងធម្មដ៏ក្រៃលែង ក្នុងវិន័យដ៏ក្រៃលែង) នេះ គប្បីជ្រាប ៤ ពួក គឺ ធម្មៈ អភិធម្មៈ វិន័យ អភិវិន័យ ។ ក្នុង ៤ ពួកនោះ ឈ្មោះថា ធម្មៈ បានដល់ ព្រះសុត្តន្តបិដក ឈ្មោះថា អភិធម្មៈ បានដល់ បករណ៍ទាំង ៧ ។ ឈ្មោះថា វិន័យ បានដល់ វិភង្គទាំងពីរ ភិក្ខុវិភង្គ ភិក្ខុនីវិភង្គ ឈ្មោះថា អភិវិន័យ បានដល់ ខន្ធកៈ និងបរិវារៈ ។ ន័យម្យ៉ាងទៀត ទាំងសុត្តន្តបិដក ទាំងអភិធម្មបិដក ឈ្មោះថា ធម្មៈ នោះឯង ។ មគ្គផលឈ្មោះថា អភិធម្មៈ ។ វិន័យបិដកទាំងអស់ ឈ្មោះថា វិន័យ ការរម្ងាប់កិលេស ឈ្មោះថា អភិវិន័យ អធិប្បាយថា ជាអ្នកមានបាមោជ្ជៈយ៉ាងឧឡារក្នុងធម្មៈ

អភិធម្មៈ វិន័យ និងអភិវិន័យនោះ ដោយប្រការដូច្នេះ ។ បទថា កុស-លេសុ ធម្មេសុ (ក្នុងកុសលទាំងឡាយ) ជាសត្តមីវិភត្តិចុះក្នុងអត្ថតតិយា-វិភត្តិ ។ អធិប្បាយថា ជាអ្នកមិនជាក់ធុរៈ ដើម្បីត្រូវការសម្រេចធម៌ទាំងនោះ ព្រោះហេតុនៃកុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។

ចប់អដ្ឋកថា បឋមឆាជសូត្រទី ៧

# អដ្ឋកថា ទុតិយនាថសូត្រទី ៨

## ធម៌ជាទីពឹង ១០ ប្រការ

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយនាថសូត្រទី ៨ ដូចតទៅនេះ ៖*

[១៨] *បទថា* ***ថេរានុកម្បិតស្ស*** *(ភិក្ខុដែលជាថេរៈ... អនុគ្រោះហើយ) បានដល់ ភិក្ខុដែលព្រះថេរៈទាំងឡាយអនុគ្រោះដោយការបង្ហាញប្រយោជន៍ដ៏សម្បូរ ដែលឧស្សាហ៍ក្នុងការឲ្យឱវាទ និងទូន្មាន ។*

ចប់អដ្ឋកថា ទុតិយនាថសូត្រទី ៨

# អដ្ឋកថា បឋមអរិយវាសសូត្រទី ៩

## *ធម៌ជាទីនៅនៃព្រះអរិយៈ ១០ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអរិយវាសសូត្រទី ៩ ដូចតទៅនេះ ៖*

[១៩] *បទថា* ***អរិយវាសា*** *បានដល់ ដែលឈ្មោះថា អរិយវាសៈ ក៏ព្រោះជាទីដែលព្រះអរិយៈទាំងឡាយនៅហើយ កំពុងនៅ និងនៅចប់ព្រហ្មចរិយៈ ។ ពាក្យថា* ***យទរិយា*** *បានដល់* ***យេ វាសេ អរិយា*** *។*

ចប់អដ្ឋកថា បឋមអរិយវាសសូត្រទី ៩

# អដ្ឋកថា ទុតិយអរិយាវាសសូត្រទី ១០

## *ធម៌ជាទីនៅនៃព្រះអរិយៈ ១០ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអរិយាវាសសូត្រទី ១០ ដូចតទៅនេះ ៖*

*[២០] ក៏ព្រោះហេតុដែលភិក្ខុអ្នកដែនកុរុរដ្ឋ មានបញ្ញាជ្រាលជ្រៅខ្វល់ខ្វាយក្នុងវេលាដែលសមគួរ ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ព្រះសូត្រដ៏ជ្រាលជ្រៅនេះ នាំត្រៃលក្ខណ៍ដ៏ល្អិតសុខុមមក ដូច្នោះ ដូចដែលត្រាស់មហានិទានសូត្រជាដើម ក្នុងគម្ពីរទីឃនិកាយជាអាទិ៍ ដល់ភិក្ខុទាំងនោះ ៗ បណ្ដាបទទាំងនោះ បទថា* ***បញ្ចង្គវិប្បហីនោ*** *(ជាអ្នកលះអង្គ ៥* ***បានហើយ****) សេចក្ដីថា ភិក្ខុជាអ្នកមិនប្រកបដោយអង្គ ៥ អស់អាសវៈហើយ នៅចប់ព្រហ្មចរិយៈហើយ កំពុងនៅ នឹងនៅ ព្រោះដូច្នោះ ភិក្ខុនេះ ទើបត្រាស់ហៅថា អរិយាវាសៈ ព្រោះមានធម៌គ្រឿងនៅសម្រាប់ព្រះអរិយៈ ព្រោះជាអ្នកលះអង្គ ៥ បានហើយ ក្នុងបទទាំងពួងក៏ន័យនេះ ៗ*

*បទថា* ***ឯវំ ភិក្ខវេ ភិក្ខុ ឆឡង្គសមន្នាគតោ ហោតិ*** *(ម្នាលភិក្ខុ* ***ទាំងឡាយ ភិក្ខុជាអ្នកប្រកបដោយអង្គ ៦ យ៉ាងនេះឯង****) សេចក្ដីថា រមែង*

ជាអ្នកប្រកបដោយធម្មវិក្ខេបក្ខា ។ សួរថា អ្វីឈ្មោះថា ធម្មវិក្ខេបក្ខា ។ ឆ្លើយថា ធម៌ទាំងឡាយ មានញាណជាដើម ។ កាលពោលថា ញាណ រមែងបានកិរិយាចិត្តដែលសម្បយុត្តដោយញាណ ៤ ដួង ។ កាលពោល ថា ធម៌ជាគ្រឿងនៅជាប់តគ្នា ក៏បានមហាចិត្ត ៨ ដួង ។ កាលពោលថា សេចក្តីស្រឡាញ់ សេចក្តីក្រោធមិនមាន ក៏រមែងបានចិត្ត ១០ ដួង សោម-នស្សញ្ញាណ ក៏បានដោយអំណាចអាសេវនប្បច្ច័យ ។

បទថា **សតារក្ខេន ចេតសា** (ចិត្តដែលរក្សាដោយសតិ) សេចក្តី ថា ក៏សតិរបស់ព្រះខីណាស្រព រមែងឲ្យសម្រេច គឺ មាននាទីរក្សាក្នុង ទ្វារទាំង ៣ គ្រប់វេលា ព្រោះហេតុនោះឯង ញាណទស្សនៈរបស់ព្រះ-ខីណាស្រពនោះ សូម្បីដើរ ឈរ ដេក និងភ្ញាក់ លោកទើបហៅថា រមែង ប្រាកដជាប់តគ្នា ប្រាកដព្រមហើយ ។ បទថា **បុថុសមណព្រាហ្មណានំ** **(របស់សមណព្រាហ្មណ៍ដ៏ច្រើន)** បានដល់ របស់សមណៈ និងព្រាហ្មណ៍ ជាច្រើន ។ ក៏ក្នុងបទថា **របស់សមណព្រាហ្មណ៍ដ៏ច្រើន** នេះ ឈ្មោះថា សមណៈ បានដល់ អ្នកបព្វជ្ជា ។ ដែលឈ្មោះថា ព្រាហ្មណ៍ បានដល់

អ្នកពោលថា លោកដ៏ចម្រើន ។

បទថា **បុថុប្បច្ចេកសច្ចានិ** (បច្ចេកសច្ចៈដ៏ច្រើន) បានដល់ សច្ចៈតែមួយផ្នែកជាច្រើន ។ អធិប្បាយថា សច្ចៈជាច្រើន ដែលប្រកាន់ជាផ្នែកៗ យ៉ាងនេះថា ការឃើញនេះប៉ុណ្ណោះជាសច្ចៈ ការឃើញនេះប៉ុណ្ណោះជាសច្ចៈ ។ បទថា **នុណ្ណានិ** (ជារបស់ដែល... បន្ទោបង់បាន) បានដល់ត្រូវនាំចេញហើយ ។ បទថា **បនុណ្ណានិ** (ដែល... កម្ចាត់ចេញហើយ) បានដល់ ត្រូវនាំចេញដោយល្អហើយ ។ បទថា **ចត្តានិ** ប្រែថា ដែលគេលះបង់ហើយ ។ បទថា **វន្តានិ** ប្រែថា វិនាសហើយ ។ បទថា **មុត្តានិ** **(បានផុតហើយ)** បានដល់ កាត់គ្រឿងចងបានហើយ ។ បទថា **បហីនានិ** ប្រែថា ដែលលះចេញហើយ ។ បទថា **បដិនិស្សដ្ឋានិ (រលាស់បានចំពោះហើយ)** បានដល់ លះបង់ដោយទស្សនៈប៉ុណ្ណោះ នឹងមិនឡើងកាន់ចិត្តទៀត ។ ក៏គ្រប់បទទាំងនោះ ជាវេវចនៈរបស់បុគ្គលលះបង់សេចក្តីប្រកាន់ដែលខ្លួនប្រកាន់ បានហើយ ។

បទថា **សមវយសដ្ឋេសនោ** (ជាអ្នកស្វែងរកមិនធូរថយ ដែលលះ

បានហើយដោយល្អ) សេចក្តីថា អវយា ប្រែថា មិនបន្ធូរបន្ថយ សង្គា ប្រែថា លះបានហើយ ។ ការស្វែងរកមិនធូរថយ ដែលលះបានហើយ របស់ភិក្ខុនោះមានហើយ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា មានការស្វែងរកមិនធូរថយដែលលះបានហើយដោយល្អ អធិប្បាយថា អ្នកស្វែងរកសច្ចៈដែលខ្លួនលះបង់ហើយបានដោយល្អ ។ ដោយបទថា រាគា ចិត្តំ វិមុត្តំ (ចិត្តផុតចាករាគៈ) ជាដើម ត្រាស់មគ្គធ្វើកិច្ច គឺ នាទីសម្រេច ។ បទថា រាគោ មេ បហីនោ (រាគៈរបស់យើងលះបានហើយ) ជាដើម ត្រាស់ផលដោយបច្ចវេក្ខណញ្ញាណ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែងងាយហើយ ។

ចប់អដ្ឋកថា ទុតិយអរិយាវាសសូត្រទី ១០

## ចប់នាថករណវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# មហាវគ្គវណ្ណនាទី ៣

## អដ្ឋកថា សីហសូត្រទី ១

### *កម្លាំងព្រះតថាគត ១០ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សីហសូត្រទី ១ ដូចតទៅនេះ ៖*

[២១] *បទថា **វិសមគតេ (ទៅក្នុងទីរកអាហារដែលមិនស្មើ)** បាន ដល់ អ្នកទៅក្នុងទីរកចំណីដែលមិនរៀបរយ ។ បទថា **សង្ឃាដំ អាបាទេសិ (ឲ្យដល់ការត្រូវសម្លាប់)** ប្រែថា ឲ្យដល់ការធ្វើឃាត គឺ ការត្រូវសម្លាប់ ។ ពិតហើយ រាជសីហ៍នោះ មានសេចក្តីអាណិតក្នុងពួកសត្វតូចៗ ព្រោះខ្លួន មានអំណាចច្រើន ។ ព្រោះដូច្នោះ ទើបគិតថា សត្វពួកណាអាចតាំងនៅ ក្នុងឋានៈជាសត្រូវ ទើបត្រូវសម្លាប់ពួកសត្វទាំងនោះចេញ សត្វពួកណា ខ្សោយកម្លាំង បំណងនឹងគេច ពួកសត្វទាំងនោះក៏គប្បីគេចចេញទៅ ទើប បន្លឺសីហនាទ ហើយចេញទៅរកចំណី ។ បទថា **តថាគតស្សេតំ អធិវចនំ** សេចក្តីថា ព្រះតថាគតឈ្មោះថា សីហៈ ព្រោះទ្រង់អត់ធន់ម្យ៉ាង ព្រោះ*

ទ្រង់សម្លាប់ម្យ៉ាង ទើបទ្រង់អត់ធន់ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍គ្រប់យ៉ាង និងទ្រង់សម្លាប់ ដោយទ្រង់ញាំញីនូវវាទៈរបស់ពួកអ្នកមានវាទៈជាសត្រូវគ្រប់គ្នា ។ បទថា **ឥទមស្ស ហោតិ សីហនាទស្មឹ** (នេះជាសីហនាទរបស់តថាគត) បានដល់ នេះជាសីហនាទ គឺ ការបន្លឺដែលមិនមានសេចក្តីភ័យខ្លាចរបស់ព្រះតថាគតនោះ ។

បទថា **តថាគតស្ស តថាគតពលានិ** (កម្លាំងរបស់តថាគត) បានដល់ ជាកម្លាំងរបស់ព្រះតថាគតប៉ុណ្ណោះ មិនទូទៅដល់បុគ្គលដទៃៗ ។ អធិប្បាយថា ពលៈរបស់ព្រះពុទ្ធទាំងឡាយអំពីកាលមុន មកហើយដោយសម្បត្តិ គឺ បុណ្យ និងយសយ៉ាងណា សូម្បីពលៈរបស់ព្រះតថាគតក៏ដូច្នោះ ។ ក្នុងបទថា **កម្លាំងរបស់តថាគត** នេះ មានកំលាំង ២ យ៉ាង គឺ កម្លាំងព្រះវរកាយ ១ កម្លាំងព្រះញាណ ១ ។ ក្នុងកម្លាំង ២ យ៉ាងនោះ កម្លាំងព្រះវរកាយ គប្បីជ្រាបដោយការប្រៀបធៀបនឹងត្រកូលដំរី ។ សមដូចព្រះបុរាណាចារ្យទាំងឡាយពោលទុកថា ៖

ត្រកូលដំរីទាំងនេះ គឺ កាឡាវកៈ ១ គង្គេយ្យៈ ១

បណ្ឌរៈ ១ តម្ពៈ ១ បិង្គលៈ ១ គន្ធៈ ១ មង្គលៈ ១

ហេមៈ ១ ឧបោសថៈ ១ ឆទ្ទន្តៈ ១ ។

រួមដំរី ១០ ត្រកូលទាំងនេះ ។ បណ្ដាត្រកូលដំរីទាំងនោះ ត្រកូលដំរីកាឡាវកៈ គប្បីឃើញថា ជាត្រកូលដំរីធម្មតាៗ ។ កម្លាំងកាយបុរស ១០ នាក់ ស្មើនឹងកម្លាំងដំរីត្រកូលកាឡាវកៈ ១ ។ កម្លាំងកាយរបស់ដំរីត្រកូលកាឡាវកៈ ១០ ស្មើនឹងកម្លាំងកាយដំរីត្រកូលគង្គេយ្យៈ ១ ។ កម្លាំងកាយរបស់ដំរីត្រកូលគង្គេយ្យៈ ១០ ស្មើនឹងកម្លាំងកាយរបស់ដំរីត្រកូលបណ្ឌរៈ ១ ។ កម្លាំងកាយរបស់ដំរីត្រកូលបណ្ឌរៈ ១០ ស្មើនឹងកម្លាំងកាយរបស់ដំរីត្រកូលតម្ពៈ ១ ។ កម្លាំងកាយរបស់ដំរីត្រកូលតម្ពៈ ១០ ស្មើនឹងកម្លាំងកាយរបស់ដំរីត្រកូលបិង្គលៈ ១ ។ កម្លាំងកាយរបស់ដំរីត្រកូលបិង្គលៈ ១០ ស្មើនឹងកម្លាំងកាយរបស់ដំរីត្រកូលគន្ធៈ ១ ។ កម្លាំងរបស់ដំរីត្រកូលគន្ធៈ ១០ ស្មើនឹងកម្លាំងកាយដំរីត្រកូលមង្គលៈ ១ ។ កម្លាំងកាយរបស់ដំរីត្រកូលមង្គលៈ ១០ ស្មើនឹងកម្លាំងកាយរបស់ដំរីត្រកូលហេមៈ ១ ។ កម្លាំកាយរបស់ដំរីត្រកូលហេមៈ ១០ ស្មើនឹងកម្លាំងកាយ

របស់ដំរីត្រកូលឧបោសថៈ ១ ។ កម្លាំងកាយរបស់ដំរីត្រកូលឧបោសថៈ ១០ ស្មើនឹងកម្លាំងកាយរបស់ដំរីត្រកូលឆទ្ទន្តៈ ១ ។ កម្លាំងកាយរបស់ដំរីត្រកូលឆទ្ទន្តៈ ១០ ទើបស្មើនឹងកម្លាំងព្រះវរកាយរបស់ព្រះតថាគតមួយព្រះអង្គ កម្លាំងព្រះវរកាយរបស់ព្រះតថាគតនេះ ហៅថា **កម្លាំងនរាយណ៍** ដូច្នេះក៏មាន កម្លាំងព្រះវរកាយរបស់ព្រះតថាគតនេះ កាលប្រៀបជាមួយដំរីធម្មតាៗ ក៏ស្មើនឹងកម្លាំងដំរី ១ ពាន់កោដិ ។ កាលប្រៀបជាមួយបុរស ក៏ស្មើនឹងកម្លាំងបុរស ១ ម៉ឺនកោដិ នេះជាកម្លាំងព្រះវរកាយរបស់ព្រះតថាគត ។

គប្បីជ្រាបកម្លាំងព្រះញាណដែលមកក្នុងបាលីជាមុន ព្រះទសពលញាណ មកក្នុងគម្ពីរមជ្ឈិមនិកាយ ចតុវេសារជ្ជញាណ អកម្បនញ្ញាណក្នុងបរិស័ទ ៨ ចតុយោនិបរិច្ឆេទញ្ញាណ បញ្ចគតិបរិច្ឆេទញ្ញាណ ញាណ ៧៣ ញាណ ៧៧ ដែលមកក្នុងគម្ពីរសំយុត្តនិកាយ រួមញាណដូចពោលមកនេះ និងញាណច្រើនពាន់ដទៃទៀត ។ នេះឈ្មោះថា កម្លាំងព្រះញាណ ។ សូម្បីក្នុងសូត្រនេះ លោកក៏បំណងយកកម្លាំងព្រះញាណប៉ុណ្ណោះ ។ ពិត

ណាស់ ព្រះញាណ លោកហៅថា ពលៈ ព្រោះអត្ថថា មិនញាប់ញ័រ និងព្រោះអត្ថថា ឧបត្ថម្ភ ។

បទថា **អាសភណ្ឋានំ (ឋានៈដែលអង់អាច)** បានដល់ ឋានៈដ៏ប្រសើរបំផុត គឺ ឋានៈដែលខ្ពស់បំផុត ។ ម្យ៉ាងទៀត ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ឈ្មោះថា **អាសភៈ** អធិប្បាយថា ឋានៈអាសភៈ របស់ព្រះពុទ្ធក្នុងកាលមុននោះឯង ។ ន័យមួយទៀត គោមេហ្វូង ១០០ ក្បាល ឈ្មោះថា **ឧសភៈ** , គោមេហ្វូង ១.០០០ ក្បាល ឈ្មោះថា **អាសភៈ** ឬថា គោមេហ្វូង ១០០ ក្រោល ឈ្មោះថា **ឧសភៈ** , គោមេហ្វូង ១.០០០ ក្រោល ឈ្មោះថា **អាសភៈ** ។ គោដែលប្រសើរបំផុតនៃគោទាំងឡាយ អត់ទ្រាំដល់អន្តរាយគ្រប់យ៉ាងបាន ពណ៌ស គួរស្រឡាញ់ អូសទាញរបស់ធ្ងន់បានច្រើន សូម្បីត្រូវសំឡេងរន្ទះ ១០០ ដង ក៏មិនតក់ស្លុត ឈ្មោះថា **និសភៈ** គោនិសភៈនោះ លោកប្រាថ្នាយកថា **គោឧសភៈ** ក្នុងសូត្រនេះ ។ ក៏ពាក្យនេះ ជាពាក្យបរិយាយរបស់ពាក្យថា ឧសភៈនោះ ។ បទថា **នេះ... របស់ឧសភៈ** បានដល់ **អាសភៈ** ។ បទថា **ឋានំ (ឋានៈ)** បានដល់ ទី

ដែលគោអាសភៈឈរ យកជើងទាំង ៤ ឈូសផែនដី ។ ក៏ទីនេះ ដូចជា អាសភៈ ព្រោះហេតុនោះ ទើបឈ្មោះថា អាសភៈ (ដែលឈរយ៉ាងអង់អាច) ។ ព្រោះប្រៀបដូចគោឧសភៈ ដែលរាប់បានថា គោនិសភៈ ប្រកបដោយកម្លាំងរបស់គោឧសភៈ យកជើងទាំង ៤ ឈូសត្រង់ទីដែលឈរ ដោយមិនញាប់ញ័រ យ៉ាងណា សូម្បីព្រះតថាគត ទ្រង់ប្រកបដោយកម្លាំងរបស់ព្រះតថាគត ១០ ប្រការ ទ្រង់ប្រថាប់ផែនដី គឺ បរិស័ទ ៨ ដែលពួកបច្ចាមិត្តណាៗ ធ្វើឲ្យញាប់ញ័រមិនបាន ក៏ទ្រង់ប្រថាប់ឈរក្នុងទីដ៏មាំដូច្នោះ កាលទ្រង់ប្រថាប់ឈរយ៉ាងនោះ ទ្រង់ក៏ប្ដេជ្ញា ចូលដល់ មិនត្រាស់ គឺ ឋានៈដ៏ខ្ពង់ខ្ពស់ដែលមានក្នុងព្រះអង្គ ព្រោះហេតុនោះ ទើបត្រាស់ថា **អាសភណ្ឋានំ បដិជានាតិ** (ប្ដេជ្ញាឋានៈដែលអង់អាច) ។

បទថា **បរិសាសុ** (ក្នុងបរិស័ទ) បានដល់ ក្នុងបរិស័ទ ៨ គឺ ខត្តិយបរិស័ទ ព្រាហ្មណបរិស័ទ គហបតិបរិស័ទ សមណបរិស័ទ ចាតុម្មហារាជិកបរិស័ទ តាវត្តិង្សបរិស័ទ មារបរិស័ទ និងព្រហ្មបរិស័ទ ។ បទថា **សីហនាទំ នទតិ** (បន្លឺសីហនាទ) ប្រែថា បន្លឺ ការបន្លឺដ៏ប្រសើរបំផុត

បន្លឺការបន្លឺរបស់បុគ្គលដែលមិនមានសេចក្តីខ្លាច ឬបន្លឺការបន្លឺ ដូចការបន្លឺរបស់រាជសីហ៍ ។ ក្នុងសេចក្តីនោះ មានឧបមាដូច្នេះ រាជសីហ៍ប្រកបដោយកម្លាំងរបស់រាជសីហ៍ ក្លៀវក្លាក្នុងទីគ្រប់កន្លែង ប្រាសចាកការព្រឺរោម រមែងបន្លឺសីហនាទ យ៉ាងណា សូម្បីរាជសីហ៍ គឺ ព្រះតថាគត ទ្រង់ប្រកបដោយកម្លាំងរបស់ព្រះតថាគត ទ្រង់ក្លៀវក្លាក្នុងបរិស័ទទាំង ៨ ប្រាសចាកការព្រឺរោម ទ្រង់បន្លឺសីហនាទ ដែលព្រមដោយលំអនៃទេសនានានាវិធីដោយន័យដូច្នេះថា សក្កាយៈជាដើមក៏ដូច្នោះ ដោយហេតុនោះ ទើបត្រាស់ថា "បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ" ។

ក៏ក្នុងបទថា *ព្រហ្មចក្កំ បវត្តេតិ (ប្រកាសព្រហ្មចក្ក)* នេះ បទថា *ព្រហ្មំ* ប្រែថា ប្រសើរបំផុត ខ្ពស់បំផុត វិសេសបំផុត ។ បទថា *ចក្កំ* បានដល់ ធម្មចក្ក ។ ក៏ធម្មចក្កនេះ មាន ២ យ៉ាង គឺ បដិវេធញ្ញាណ ១ ទេសនាញ្ញាណ ១ ។ ក្នុង ២ យ៉ាងនោះ ធម្មចក្ក ដែលព្រះបញ្ញាអប់រំនាំអរិយផលមកឲ្យព្រះអង្គ ឈ្មោះថា បដិវេធញ្ញាណ , ធម្មចក្កដែលព្រះករុណាអប់រំ នាំអរិយផលមកឲ្យព្រះសាវកទាំងឡាយ ឈ្មោះថា ទេសនា-

ញាណ ។ ក្នុងញាណទាំងពីរនោះ បដិវេធញាណ មាន ២ គឺ ដែលកំពុងកើត និងកើតហើយ ។ ពិតហើយ បដិវេធញាណនោះ ឈ្មោះថា **កំពុងកើត** គឺ តាំងពីស្តេចចេញទ្រង់ព្រះផ្នួសរហូតដល់ព្រះអរហត្តមគ្គ ។ ឈ្មោះថា **កើតហើយ** ក្នុងខណៈនៃផលចិត្ត , ឬថា ឈ្មោះថា **កំពុងកើត** តាំងពីតុសិតពិភពរហូតដល់ព្រះអរហត្តមគ្គត្រង់ពោធិបល្ល័ង្ក ឈ្មោះថា **កើតហើយ** គឺ ក្នុងខណៈនៃផលចិត្ត , ឬថា ឈ្មោះថា **កំពុងកើត** ផ្តើមតាំងពីសេចក្តីប្រាថ្នាទៀបព្រះបាទនៃព្រះពុទ្ធព្រះនាមថា ទីបង្ករ រហូតដល់ទ្រង់សម្រេចព្រះអរហត្តមគ្គ ឈ្មោះថា **កើតហើយ** ក្នុងខណៈនៃផលចិត្ត ។ ចំណែកទេសនាញាណ ក៏មាន ២ គឺ ដែលកំពុងប្រព្រឹត្តទៅ និងប្រព្រឹត្តទៅហើយ ។ ពិតហើយ ទេសនាញាណនោះ ឈ្មោះថា **កំពុងប្រព្រឹត្តទៅ** រហូតដល់សោតាបត្តិមគ្គរបស់ព្រះអញ្ញាកោណ្ឌញ្ញៈ ឈ្មោះថា **ប្រព្រឹត្តទៅហើយ** ក្នុងខណៈនៃផលចិត្ត (សោតាបត្តិផល) ។ ក៏ក្នុងញាណទាំង ២ នោះ បដិវេធញាណដែលកើតហើយ ជាលោកុត្តរៈ ទេសនាញាណដែលប្រព្រឹត្តទៅហើយ ជាលោកិយៈ ។ សូម្បីញាណទាំង ២ នោះ មិនទូទៅដល់សាវក

ដទៃៗ ជាញាណដែលកើតហើយក្នុងព្រះអង្គ របស់ព្រះសម្ពុទ្ធទាំងឡាយ ប៉ុណ្ណោះ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងដោយពិស្តារដល់ព្រះពលៈ ដែលព្រះតថាគតទ្រង់ប្រកបហើយ ទ្រង់ប្តេជ្ញាឋានៈដែលខ្ពស់បំផុត ទើបត្រាស់ថា **កតមានិ ទស ឥធ ភិក្ខវេ តថាគតោ ឋានញ្ច ឋានតោ** (១០ ប្រការដូចម្តេច គឺ ១ ។ តថាគត... **ឋានៈដោយជាឋានៈ...** ក្នុងលោកនេះ) ជាអាទិ៍ ។ បណ្តាបទទាំងនោះ បទថា **ឋានញ្ច ឋានតោ** (ឋានៈដោយឋានៈ) បានដល់ ហេតុដោយសភាពជាហេតុ ។ ពិតណាស់ ព្រោះហេតុដែលផលតាំងនៅ កើត និងប្រព្រឹត្តទៅក្នុងហេតុនោះ ព្រោះប្រព្រឹត្តទៅជាប់ដោយហេតុនោះ ដូច្នោះ ហេតុ លោកទើបហៅថា ឋានៈ ។ ព្រះដ៏មានព្រះភាគកាលទ្រង់ជ្រាបហេតុនោះៗ ថា ឋានៈ ព្រោះធម៌ដែលជាហេតុ ជាបច្ច័យនៃធម៌កើតឡើង ទ្រង់ជ្រាបហេតុនោះៗ ថា អឋានៈ ព្រោះធម៌ដែលមិនមែនជាហេតុ មិនមែនជាបច្ច័យនៃធម៌កើតឡើង ឈ្មោះថា ទ្រង់ជ្រាបឋានៈដោយជាឋានៈ អឋានៈដោយជាអឋានៈ តាមសេចក្តីពិត ។ តែក្នុងអភិធម្ម

ពាក្យនេះ លោកពោលទុកពិស្តារហើយ ដោយន័យជាដើមថា មគ្គញ្ញាណទាំងនោះ ញាណដែលដឹងឋានៈថាជាឋានៈ និងដឹងអឋានៈថាជាអឋានៈ តាមសេចក្តីពិតរបស់ព្រះតថាគត ដូចម្តេច ដូច្នេះ ។ បទថា **យម្បិ** ប្រែថា ដោយញាណណា ។ បទថា **ឥទម្បិ ភិក្ខវេ តថាគតស្ស (ម្នាលភិក្ខុទាំងឡាយ នេះជា... របស់តថាគត)** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ឋានាឋានញ្ញាណសូម្បីនេះ រមែងឈ្មោះថា តថាគតពលៈរបស់តថាគត ។ គប្បីជ្រាបការប្រកបសេចក្តីក្នុងបទទាំងពួង ដោយប្រការយ៉ាងនេះ ។

បទថា **កម្មសមាទានានំ (នៃការកាន់យកការធ្វើ)**បានដល់ របស់កុសលកម្ម និងអកុសលកម្ម ដែលបុគ្គលធ្វើហើយ ម្យ៉ាងទៀត កម្មនោះឯង ឈ្មោះថា កម្មសមាទាន ។ បទថា **ឋានសោ ហេតុសោ (ដោយឋានៈ ដោយហេតុ)** សេចក្តីថា ព្រោះជាបច្ច័យ និងព្រោះជាហេតុ ។ ក៏ក្នុងកម្មសមាទាននោះ កថាពោលដល់ញាណនេះ ដោយពិស្តារថា កម្មជាហេតុនៃវិបាក ព្រោះគតិ ឧបធិ កាល និងបយោគៈ ។ មកហើយក្នុងអភិធម្ម ដោយន័យជាដើមថា កម្មសមាទានចំណែកអកុសលពួកខ្លះ មាន

ហើយ ហាមគតិសម្បត្តិ ទើបមិនឲ្យវិបាក ។

បទថា **សព្វត្ថគាមិនី** (ជាហេតុឲ្យដល់ប្រយោជន៍ទាំងពួង) បានដល់ ដែលឲ្យដល់គតិទាំងពួង និងដែលមិនឲ្យដល់គតិ ។ បទថា **បដិបទំ** (បដិ-បទា) បានដល់ មគ្គ ។ បទថា **យថាភូតំ បជានាតិ** (រមែងដឹងច្បាស់... **តាមសេចក្ដីពិត**) សេចក្ដីថា កាលមនុស្សស្រូម្បីដ៏ច្រើន សម្លាប់សត្វតែមួយប៉ុណ្ណោះ គេរមែងដឹងច្បាស់ដល់សភាពនៃការបដិបត្តិទាំងឡាយ ពោលគឺកុសលចេតនា និងអកុសលចេតនា ក្នុងវត្ថុតែមួយ ដោយមិនខុស តាមន័យនេះថា បុគ្គលនេះនឹងមានចេតនាទៅនរក បុគ្គលនេះនឹងមានចេតនាទៅកាន់កំណើតសត្វតិរច្ឆាន ។ មួយទៀត កថាពោលដល់ញាណនេះ ដោយពិស្ដារ មកហើយក្នុងអភិធម្មដូចគ្នា ដោយន័យជាដើមថា បណ្ដាញាណទាំងនោះ ញាណដែលដឹងបដិបទាទៅកាន់គតិទាំងពួង តាមសេចក្ដីពិតរបស់ព្រះតថាគត ដូចម្ដេច ព្រះតថាគតក្នុងលោកនេះ ទ្រង់រមែងដឹងច្បាស់ថា នេះមគ្គ នេះមិនមែនមគ្គ នេះបដិបទាដែលឲ្យទៅនរក ។

បទថា **អនេកធាតុំ** (មានធាតុជាអនេក) បានដល់ ធាតុជាច្រើន

ដោយចក្ខុធាតុជាដើម ឬដោយកាមធាតុជាដើម ។ បទថា **នានាធាតុំ (មានធាតុផ្សេងៗ)** បានដល់ ធាតុមានប្រការផ្សេងៗ ព្រោះធាតុទាំងនោះមានលក្ខណៈដោយចំពោះផ្សេងគ្នា ។ បទថា **លោកំ (លោក)** បានដល់ លោក គឺ ខន្ធ អាយតនៈ និងធាតុ ។ បទថា **យថាភូតំ បជានាតិ (រមែងដឹងច្បាស់...តាមសេចក្តីពិត)** បានដល់ ទ្រង់ត្រាស់ដឹងសភាពរបស់ធាតុទាំងនោះដោយមិនខុស ។ សូម្បីញាណនេះ លោកក៏ពោលទុកពិស្តារហើយ ក្នុងអភិធម្ម ដោយន័យជាដើមថា បណ្តាញាណទាំងនោះ ញាណដែលដឹងធាតុដ៏ច្រើន ធាតុផ្សេងៗ លោក តាមសេចក្តីពិតរបស់ព្រះតថាគត ដូចម្តេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់រមែងដឹងច្បាស់សេចក្តីផ្សេងៗ នៃខន្ធ ។

បទថា **នានាធិមុត្តិកតំ (សភាពនៃសត្វទាំងឡាយមានអធ្យាស្រ័យផ្សេងៗ គ្នា)** បានដល់ សភាពដែលសត្វទាំងឡាយមានអធ្យាស្រ័យផ្សេងៗគ្នា ដោយអធ្យាស្រ័យទាំងឡាយ មានអធ្យាស្រ័យអាក្រក់ជាដើម ។ ញាណសូម្បីនេះ លោកពោលទុកពិស្តារហើយក្នុងអភិធម្ម ដោយន័យជាដើមថា បណ្តាញាណទាំងនោះ ញាណដែលដឹងសត្វទាំងឡាយមានអធ្យាស្រ័យផ្សេងៗ

*គ្នា តាមសេចក្តីពិតរបស់ព្រះតថាគត ដូចម្តេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់រមែងដឹងច្បាស់ថា សត្វទាំងឡាយមានអធ្យាស្រ័យអាក្រក់ ក៏មាន ។*

*បទថា **បរសត្តានំ (របស់សត្វដទៃ)** បានដល់ សត្វដែលមានឥន្ទ្រិយល្អ ។ បទថា **បរបុគ្គលានំ (របស់បុគ្គលដទៃ)** បានដល់ សត្វដែលមានឥន្ទ្រិយអាក្រក់ដទៃពីនោះ ។ម្យ៉ាងទៀត ពីរបទនេះ មានសេចក្តីតែម្យ៉ាងដូចគ្នា ត្រាស់ជា ២ ចំណែក ក៏ដោយអំណាចវេនេយ្យសត្វ ។ បទថា **ឥន្ទ្រិយបរោបរិយត្តំ (នូវភាពចាស់ក្លា និងទន់ខ្សោយនៃឥន្ទ្រិយ)** សេចក្តីថា ភាពចាស់ក្លា និងទន់ខ្សោយ សេចក្តីចម្រើន និងសេចក្តីសាបសូន្យ នៃឥន្ទ្រិយទាំងឡាយ មានសទ្ធិន្ទ្រិយជាដើម ។ កថាពោលដល់ញាណសូម្បីនេះ ដោយពិស្តារ ក៏មកក្នុងអភិធម្មដូចគ្នា ដោយន័យជាដើមថា បណ្តាញាណទាំងនោះ ញាណដែលដឹងសត្វដទៃ បុគ្គលដទៃ មានឥន្ទ្រិយចាស់ក្លា និងទន់ខ្សោយតាមសេចក្តីពិតរបស់ព្រះតថាគតនោះ ដូចម្តេច ។ ព្រះតថាគតក្នុងលោកនេះ រមែងទ្រង់ដឹងអាសយៈ (អធ្យាស្រ័យល្អ) ទ្រង់ដឹងអនុសយៈ (អធ្យាស្រ័យអាក្រក់) របស់សត្វទាំងឡាយ ។*

បទថា ***ឈានវិមោក្ខសមាធិសមាបត្តីនំ (នៃឈាន វិមោក្ខ សមាធិ និងសមាបត្តិ)*** បានដល់ នៃឈាន ៤ មានបឋមឈានជាដើម វិមោក្ខ ៨ មាន "បុគ្គលដែលចម្រើនរូបឈានឃើញរូបទាំងឡាយ" ដូច្នេះជាដើម ។ សមាធិ ៣ មានសមាធិដែលមានវិតក្កៈ ដែលមានវិចារៈជាដើម និងអនុ-បុព្វវិហារសមាបត្តិ ៩ មានបឋមឈានសមាបត្តិជាដើម ។ បទថា ***សង្កិលេសំ (សេចក្ដីសៅហ្មង)*** បានដល់ ធម៌ចំណែកសាបសូន្យ ។ បទថា ***វោទានំ (សេចក្ដីផូរផង់)*** បានដល់ ធម៌ចំណែកវិសេស ។ បទថា ***វុដ្ឋានំ (ការចេញ)*** បានដល់ សូម្បីការចេញចាកសមាបត្តិនោះៗ ក៏ឈ្មោះថា វុដ្ឋានៈ ឈានដែលជំនាញ ភវង្គចិត្ត និងផលសមាបត្តិ លោកក៏ហៅដូច្នោះ ។ ពិតហើយ ឈានដែលជំនាញថ្នាក់ក្រោមៗ រមែងជាបទដ្ឋានរបស់ឈានថ្នាក់ខ្ពស់ៗ ព្រោះដូច្នោះ សូម្បីវោទានៈ លោកក៏ហៅថា វុដ្ឋានៈ ។ ការចេញចាកឈានទាំងពួង រមែងមានដោយភវង្គចិត្ត ។ ការចេញចាកនិរោធ-សមាបត្តិ រមែងមានដោយផលសមាបត្តិ ។ ខ្ញុំសំដៅយកប្រការនោះ ទើបពោលថា សូម្បីការចេញចាកសមាធិនោះៗ ឈ្មោះថា វុដ្ឋានៈ ។ សូម្បីញាណ

នេះ លោកក៏ពោលទុកពិស្តារហើយក្នុងអភិធម្ម ដោយន័យជាដើមថា បណ្ដាញាណទាំងនោះ ញាណដែលដឹងសេចក្ដីសៅហ្មង សេចក្ដីផូរផង់ ការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិ តាមសេចក្ដីពិតរបស់ព្រះតថាគតដូចម្ដេច ។ បទថា **ឈាយី** បានដល់ អ្នកមានឈាន ៤ អ្នកមានឈាន ៥ៈ ជិតស្និទ្ធនឹងសមាបត្តិដែលមានហើយនោះឯង ។ ការវិនិច្ឆ័យក្នុងកថាពោលដល់ញាណទាំងឡាយដោយពិស្តារថា **សព្វវិបត្តិ** ជាដើម ក៏ពោលទុកហើយក្នុងអដ្ឋកថាគម្ពីរវិភង្គ (អភិធម្ម) ឈ្មោះថា សម្មោហវិនោទនី ។ កថាដែលពោលដោយបុព្វេនិវាសានុស្សតិញ្ញាណ និងទិព្វចក្ខុញ្ញាណ ក៏ពោលទុកពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ កថាពោលដោយអាសវក្ខយញ្ញាណ ក៏ពោលទុកហើយក្នុងខាងក្រោយនោះឯង ។

ក្នុងរឿងព្រះញាណរបស់ព្រះតថាគតនោះ មានពាក្យឆ្លើយរបស់ព្រះបរវាទីថា ញាណមួយផ្នែកដែលឈ្មោះថា ទសពលញ្ញាណ មិនមាន ។ នេះក៏ជាប្រភេទនៃព្រះសព្វញ្ញុតញ្ញាណនុ៎ះឯង ។ ពាក្យនោះ មិនគួរឃើញយ៉ាងនោះ ។ ព្រោះថា ទសពលញ្ញាណក៏ញាណមួយ ព្រះសព្វញ្ញុតញ្ញាណ

ក៏ញាណមួយ ៗ ពិតណាស់ ព្រះទសពលញាណ ក៏ដឹងចំពោះកិច្ចរបស់ខ្លួនប៉ុណ្ណោះ ៗ ព្រះសព្វញ្ញុតញ្ញាណ រមែងដឹងទាំងកិច្ចរបស់ខ្លួនផង ទាំងកិច្ចដ៏សេសក្រៅចាកពីរបស់ខ្លួនផង ។ ការពិត ក្នុងព្រះទសពលញាណទាំងឡាយ ព្រះញាណទី ១ ដឹងហេតុ និងមិនមែនហេតុ ព្រះញាណទី ២ ដឹងកម្មជវៃ និងវិបាកជវៃ ព្រះញាណទី ៣ ដឹងការកំណត់កម្ម ព្រះញាណទី ៤ រមែងដឹងហេតុនៃធាតុដែលផ្សេងៗ គ្នា ព្រះញាណទី ៥ រមែងដឹងអធិមុត្តិ គឺ អធ្យាស្រ័យរបស់សត្វទាំងឡាយ ព្រះញាណទី ៦ រមែងដឹងឥន្ទ្រិយរបស់សត្វទាំងឡាយថា ចាស់ក្លា និងទន់ខ្សោយ ព្រះញាណទី ៧ រមែងដឹងសេចក្តីសៅហ្មងជាដើមរបស់ធម៌ទាំងនោះ ព្រមទាំងញាណជាអាទិ៍ ព្រះញាណទី ៨ រមែងដឹងសន្តតិ (ការបន្តនៃខន្ធដែលអាស្រ័យក្នុងជាតិមុនៗ) ព្រះញាណទី ៩ រមែងដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ព្រះញាណទី ១០ រមែងដឹងសច្ចៈ ៗ ចំណែកព្រះសព្វញ្ញុតញ្ញាណ រមែងដឹងប្រការដែលព្រះញាណទាំងនោះគួរដឹង និងប្រការដែលច្រើនជាងព្រះញាណទាំងនោះ ៗ ក៏ព្រះសព្វញ្ញុតញ្ញាណ មិនធ្វើកិច្ចរបស់ព្រះញាណគ្រប់យ៉ាងទាំង

នោះទេ ។ ពិតណាស់ ព្រះសព្វញ្ញុតញ្ញាណនោះ មិនមែនជាឈានដែលជិតស្និទ្ធ មិនមែនជាឥទ្ធិសម្តែងឫទ្ធិផ្សេងៗ ទេ មិនមែនជាមគ្គធ្វើកិលេសទាំងឡាយឲ្យអស់ទៅទេ ។

មួយទៀត បរវាទីត្រូវសួរយ៉ាងនេះថា "ធម្មតាព្រះទសពលញ្ញាណនេះ មានវិតក្កមានវិចារៈ មិនមានវិតក្កមានវិចារៈ ឬមិនមានវិតក្កមិនមានវិចារៈ ជាកាមាវចរៈ រូបាវចរៈ ឬអរូបាវចរៈ ជាលោកិយៈ ឬលោកុត្តរៈ" កាលដឹង ក៏នឹងឆ្លើយថា "ព្រះញាណ ៧ តាមលំដាប់ មានវិតក្កមានវិចារៈ" នឹងឆ្លើយថា "ព្រះញាណ ២ ក្រៅពីព្រះញាណ ៧ នោះ មិនមានវិតក្កមិនមានវិចារៈ" ។ នឹងឆ្លើយថា "អាសវក្ខយញ្ញាណ មានវិតក្កមានវិចារៈ ក៏មាន មិនមានវិតក្កមានត្រឹមតែវិចារៈ ក៏មាន មិនមានវិតក្កមិនមានវិចារៈ ក៏មាន" នឹងឆ្លើយថា "ព្រះញាណ ៧ តាមលំដាប់ក៏ដូចគ្នា ជាកាមាវចរៈ ព្រះញាណ ២ ក្រៅពីព្រះញាណ ៧ នោះ ជារូបាវចរៈ ព្រះញាណចុងក្រោយជាលោកុត្តរៈ" នឹងឆ្លើយថា "ព្រះសព្វញ្ញុតញ្ញាណ មានវិតក្កមានវិចារៈ ជាកាមាវចរៈ ជាលោកិយៈនោះឯង" ។ លុះដឹងការពណ៌នាតាមបទ ក្នុង

ព្រះញាណរបស់ព្រះតថាគតនោះ យ៉ាងនេះហើយ ឥឡូវនេះ ព្រោះហេតុដែលព្រះតថាគតទ្រង់ឃើញការមិនមានកិលេសជាគ្រឿងរាំងចិត្ត ដែលជាឋានៈ និងអឋានៈ នៃការសម្រេចធម៌ជាទីអស់អាសវៈ និងមិនសម្រេចរបស់វេនេយ្យសត្វទាំងឡាយ ដោយឋានាឋានញ្ញាណមុន ព្រោះទ្រង់ឃើញសម្មាទិដ្ឋិជាដើម ដែលជាលោកិយៈ និងព្រោះទ្រង់បានឃើញការមិនមាននិយតមិច្ឆាទិដ្ឋិ លំដាប់នោះ ទើបទ្រង់ឃើញការមិនមានវិបាកជាគ្រឿងរាំងដោយកម្មវិបាកញ្ញាណ ព្រោះទ្រង់ឃើញបដិសន្ធិរបស់សត្វ ដែលមានត្រៃហេតុ ទ្រង់ឃើញការមិនមានកម្មជាគ្រឿងរាំង ដោយសព្វត្ថគាមិនីបដិបទាញាណ ព្រោះទ្រង់ឃើញការមិនមានអនន្តរិយកម្ម ដូច្នោះ ទើបទ្រង់ឃើញសេចក្ដីវិសេសនៃចរិយារបស់ពួកសត្វដែលមិនមានគ្រឿងរាំង ដោយអនេកធាតុនានាធាតុញ្ញាណ ដើម្បីទ្រង់សម្ដែងធម៌អនុកូល ព្រោះទ្រង់ឃើញធាតុផ្សេងគ្នា ៗ តពីនោះ ក៏ទ្រង់ឃើញអធិមុត្តិ (អធ្យាស្រ័យ) របស់សត្វទាំងនោះ ដោយនានាធិមុត្តិកញ្ញាណ សូម្បីទ្រង់មិនកាន់យកប្រយោគ ក៏ទ្រង់សម្ដែងធម៌ដោយអំណាចអធិមុត្តិ ទ្រង់ឃើញសត្វមានឥន្ទ្រិយចាស់ក្លា

និងទន់ខ្សោយ ដោយឥន្ទ្រិយបរោបរិយត្តិញ្ញាណ ដើម្បីទ្រង់សម្តែងធម៌តាមការ អាច និងតាមកម្លាំង ដោយអំណាចពួកសត្វដែលទ្រង់ឃើញអធិមុត្តិហើយ នោះឯង ព្រោះទ្រង់ឃើញឥន្ទ្រិយរបស់សត្វទាំងឡាយ មានសទ្ធាជាដើម ចាស់ក្លា និងទន់ខ្សោយ តែសត្វទាំងនោះ ក៏ទ្រង់កំណត់ដឹងថា មានឥន្ទ្រិយចាស់ក្លា និងទន់ខ្សោយយ៉ាងនោះ បើនៅឆ្ងាយពីទីនោះ ក៏ស្តេចទឹងចូលទៅជិតសត្វទាំងនោះយ៉ាងឆាប់រហ័ស ដោយសេចក្តីវិសេសនៃឫទ្ធិ ព្រោះទ្រង់ជំនាញក្នុងឈានជាដើម ដោយឈានាទិញ្ញាណ លុះស្តេចចូលទៅជិតហើយ កាលទ្រង់ឃើញការៈរបស់សត្វទាំងនោះក្នុងជាតិមុនៗ ដោយបុព្វេនិវាសានុស្សតិញ្ញាណ កាលទ្រង់ឃើញសេចក្តីវិសេសនៃសម្បត្តិដែលសត្វសម្រេចហើយ ដោយចេតោបរិយញ្ញាណដែលគប្បីសម្រេច ព្រោះអានុភាពនៃទិព្វចក្ខុញ្ញាណ ទើបទ្រង់សម្តែងធម៌ ដល់បដិបទាដែលនឹងឲ្យដល់ធម៌ជាទីអស់អាសវៈ ដើម្បីការអស់ទៅនៃអាសវៈ ព្រោះជាអ្នកប្រាសចាកសេចក្តីវង្វេងហើយ ដោយអានុភាពនៃអាសវក្ខយញ្ញាណ ដូច្នោះ គប្បីជ្រាបតាមលំដាប់នេះថា ត្រាស់ពលៈទាំងឡាយ ដោយលំដាប់នេះ ។

ចប់អដ្ឋកថា សីហសូត្រទី ១

# អដ្ឋកថា អធិមុត្តិសូត្រទី ២

## កម្លាំងព្រះតថាគត ១០ ប្រការ

គប្បីជ្រាបវិនិច្ឆ័យក្នុង អធិមុត្តិសូត្រទី ២ ដូចតទៅនេះ ៖

[២២] បទថា *យេ តេ ធម្មា* (ធម៌ពួកណា) បានដល់ ធម៌ គឺ ព្រះទសពលញ្ញាណ និងព្រះសព្វញ្ញុតញ្ញាណនោះឯង ។ បទថា *អធិមុត្តិបទានំ* (អធិមុត្តិបទ) បានដល់ បទ គឺ *ឈ្មោះ* អធិប្បាយថា ធម៌ គឺ ខន្ធ អាយតនៈ ធាតុ ។ ពិតណាស់ *ឈ្មោះ* លោកហៅថា អធិមុត្តិ ព្រោះជាបទដ្ឋាននៃទេសនា ដែលជាបទនៃធម៌ទាំងនោះ ។ ពិតហើយ សូម្បីព្រះពុទ្ធទាំងឡាយដែលកន្លងទៅហើយ (អតីត) ក៏ត្រាស់ធម៌ទាំងនោះដូចគ្នា សូម្បីព្រះពុទ្ធដែលមិនទាន់មក (អនាគត) ក៏ត្រាស់ធម៌ទាំងនោះដូចគ្នា ព្រោះដូច្នោះ ធម៌ទាំងឡាយ មានខន្ធជាដើម ទើបឈ្មោះថា អធិមុត្តិបទ ។ នៃអធិមុត្តិបទនោះ ។ ម្យ៉ាងទៀត ទិដ្ឋិទាំងឡាយ លោកហៅថា អធិមុត្តិ ព្រោះគ្របសង្កត់ការពិត មិនកាន់យកតាមសេចក្តីពិតប្រព្រឹត្តទៅ ។ បទនៃទិដ្ឋិទាំងឡាយ ឈ្មោះថា អធិមុត្តិបទ អធិប្បាយថា ពាក្យដែលសម្តែង

ទិដ្ឋិ នៃអធិមុត្តិបទ គឺ ពាក្យនៃទិដ្ឋិទាំងនោះ ។

បទថា **អភិញ្ញាសច្ឆិកិរិយាយ** (ដើម្បីធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ក្រៃលែង) សេចក្ដីថា ដើម្បីប្រយោជន៍ដល់ការដឹងហើយ ធ្វើឲ្យប្រច័ក្ស ។ បទថា **វិសារទោ** (ជាអ្នកក្លៀវក្លា) បានដល់ ដល់សោមនស្សដែលប្រកបដោយញាណ ។ បទថា **តត្ថ** ប្រែថា ក្នុងធម៌ទាំងនោះ ។ បទថា **តេសំ តេសំ តថា តថា ធម្មំ ទេសេតុំ** (ដើម្បីសេចក្ដីដឹងដែលអាស្រ័យធម៌ទាំងនោះ ហើយសម្ដែងធម៌ដោយប្រការដែល) សេចក្ដីថា ទ្រង់ដឹងអាសយៈ (អធ្យាស្រ័យដែលល្អ) របស់ពួកសត្វនោះៗ ដែលមានទិដ្ឋិ ឬក្រៅពីនេះ ហើយទ្រង់សម្ដែងធម៌ដោយប្រការនោះៗ ។ បទថា **ហីនំ វា ហីនន្តិ ញស្សតិ** (នឹងដឹងនូវធម៌អាក្រក់ថា អាក្រក់ខ្វះ) សេចក្ដីថា ឬនឹងដឹងធម៌អាក្រក់ថា ជាធម៌អាក្រក់ ។ បទថា **ញាតយ្យំ** ប្រែថា គប្បីដឹង ។ បទថា **ទិដ្ឋយ្យំ** ប្រែថា គប្បីឃើញ ។ បទថា **សច្ឆិកតយ្យំ** ប្រែថា គប្បីធ្វើឲ្យច្បាស់ ។ បទថា **តត្ថ តត្ថ យថាភូតញាណំ** (យថាភូតញាណក្នុងធម៌ទាំងនោះ) បានដល់ ញាណដែលដឹងតាមសេចក្ដីពិតក្នុងធម៌ទាំងនោះ

ទ្រង់សម្តែងព្រះសព្វញ្ញុតញ្ញាណយ៉ាងនេះហើយ កាលទ្រង់សម្តែងព្រះទស-ពលញ្ញាណទៀត ទើបត្រាស់ថា "១០ ប្រការ" ជាដើម ។ ពិតណាស់ សូម្បីព្រះទសពលញ្ញាណ ក៏គឺ ព្រះញាណដែលដឹងតាមសេចក្តីពិតក្នុងធម៌នោះៗ ទុំះឯង ។

ចប់អដ្ឋកថា អធិមុត្តិសូត្រទី ២

# អដ្ឋកថា កាយសូត្រទី ៣

## ធម៌ដែលលះដោយកាយវាចាមិនបាន តែលះបានដោយបញ្ញា

គប្បីជ្រាបវិនិច្ឆ័យក្នុង កាយសូត្រទី ៣ ដូចតទៅនេះ ៖

[២៣] បទថា **អាបន្នោ ហោតិ កញ្ចិទេវ ទេសំ** (ជាអ្នកត្រូវអាបត្តិចំណែកខ្លះដែលជាអកុសល) សេចក្តីថា ជាអ្នកត្រូវចំណែកនៃអាបត្តិយ៉ាងខ្លះ ។ បទថា **អនុវិច្ច** (ពិចារណាហើយ) បានដល់ ចូលទៅពិចារណា គឺ ដៀងមើលរឿយៗ ។ បទថា **កាយទុច្ចរិតំ** (កាយទុច្ចរិត) បានដល់ កាយទុច្ចរិត ៣ យ៉ាង ។ បទថា **វចីទុច្ចរិតំ** (វចីទុច្ចរិត) បានដល់ វចីទុច្ចរិត ៤ យ៉ាង ។ បទថា **បាបិកា ឥស្សា** (សេចក្តីប្រណែនដ៏លាមក) បានដល់ សេចក្តីឫស្យាដ៏ថោកទាប ។ បទថា **បញ្ញាយ ទិស្វា ទិស្វា** (ឃើញច្បាស់ដោយបញ្ញា) បានដល់ មើលឃើញហើយ គប្បីលះចេញដោយមគ្គប្បញ្ញាព្រមដោយវិបស្សនា ។ បទថា **ឥជ្ឈតិ** (រមែងសម្បូរ) បានដល់ រមែងសម្រេចព្រម គឺ ដល់ព្រម ។ បទថា **ឧបវាសស្ស** (អ្នកចូលទៅអាស្រ័យ) បានដល់ អ្នកចូលទៅអាស្រ័យហើយ ។ បទថា **អភិកុយ្យ**

*(គ្របសន្ត់) បានដល់ គ្របសន្ត់ គឺ ញាំញី ។ បទថា **ឥរិយតិ** ប្រែថា ប្រព្រឹត្តទៅ ។ ក្នុងព្រះសូត្រនេះ ត្រាស់មគ្គព្រមដោយវិបស្សនា ។*

ចប់អដ្ឋកថា កាយសូត្រទី ៣

# អដ្ឋកថា ចុន្ទសូត្រទី ៤

## *ព្រះមហាចុន្ទៈទូន្មានភិក្ខុ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចុន្ទសូត្រទី ៤ ដូចតទៅនេះ ៖*

[២៤] *ព្រះមហាចុន្ទៈ ពោលអាការនៃញាណទស្សនៈ ដោយបទថា* ***ជានាមិមំ ធម្មំ (យើងរមែងដឹងធម៌នេះ)*** *។ លោកពោលវាទៈសូម្បីទាំង ២ រួមគ្នាក្នុងវារៈទី ៣ នៃការនាវារៈ ដោយបទថា* ***ភាវិតក្កាយោម្ហិ (យើងជាអ្នកមានកាយអប់រំហើយ)*** *ជាដើម ។ ក៏វាទៈសូម្បីទាំង ៣ នោះ រមែងប្រព្រឹត្តទៅជាព្រះអរហត្តដូចគ្នា ។ បទថា* ***អឡ្ហវាទំ វទេយ្យ (គប្បីពោលអួតថាជាអ្នកស្តុកស្តម្ភ)*** *សេចក្តីថា គប្បីពោលអួតថា ខ្ញុំជាអ្នកមានស្តុកស្តម្ភ ។ បទថា* ***ឧបនីហាតុំ (ដើម្បីនាំ)*** *បានដល់ ដើម្បីនាំចេញឲ្យ ។*

ចប់អដ្ឋកថា ចុន្ទសូត្រទី ៤

# អដ្ឋកថា កសិណសូត្រទី ៥

## *ពោលដោយកសិណ ១០*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កសិណសូត្រទី ៥ ដូចតទៅនេះ ៖*

*[២៥] ឈ្មោះថា កសិណ ព្រោះអត្ថថា ទាំងអស់ ។ ឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាខេត្តនៃធម៌ទាំងឡាយ ដែលមានកសិណនោះជាអារម្មណ៍ ឬព្រោះអត្ថថា តាំងទុក ហេតុនោះ ទើបឈ្មោះថា កសិណាយតនៈ អណ្តូងកើតនៃអារម្មណ៍ដែលជាកសិណ ។ បទថា* ***ឧទ្ធំ*** *(ក្នុងខាងលើ) បានដល់ ងើយមើលផ្ទៃអាកាសខាងលើ ។ បទថា* ***អធោ*** *(ខាងក្រោម) បានដល់ មើលផែនដីខាងក្រោម ។ បទថា* ***តិរិយំ*** *(ខាងទទឹង) បានដល់ កំណត់ដោយជុំវិញវាលស្រែ ។ ពិតហើយ ព្រះយោគាវចររូបខ្លះ ចម្រើនកសិណខាងលើប៉ុណ្ណោះ រូបខ្លះក៏ខាងក្រោម រូបខ្លះក៏ទាំងអស់ ដោយអាការនោះៗ ទៅដោយជុំវិញ ដូចត្រូវការនឹងមើលរូបដែលមានពន្លឺ ព្រោះហេតុនោះ ព្រះថេរៈទើបពោលថា* ***បុគ្គលខ្លះ រមែងដឹងបរិកសិណក្នុងខាងលើ ខាងក្រោម ខាងទទឹង*** *។ ក៏បទថា* ***អទ្វយំ*** *(មិនមានពីរ) នេះ*

លោកពោលដល់កសិណណាមួយមិនប្រែប្រួលជាយ៉ាងដទៃ ដូចជាថា កាលព្រះយោគាវចរចូលទៅកាន់ទឹក (អាបោកសិណ) គ្រប់ទិសក៏មានទឹកតែម្យ៉ាង មិនមានអ្វីយ៉ាងដទៃ យ៉ាងណា បឋវីកសិណ ក៏ដូច្នោះ រមែងជាបឋវីកសិណតែម្យ៉ាង មិនលាយឡំកសិណដទៃ ។ ក្នុងកសិណទាំងពួងក៏ន័យនេះដូចគ្នា ។ បទថា **អប្បមាណំ (រកប្រមាណមិនបាន)** នេះ លោកពោលដោយអំណាចផ្សាយកសិណនោះៗ ទៅ មិនមានប្រមាណ ។ ពិតហើយ ព្រះយោគាវចរកាលផ្សាយកសិណនោះដោយចិត្ត រមែងផ្សាយទូទៅនោះឯង មិនប្រមាណថា នេះជាផ្នែកខាងដើមរបស់កសិណនោះ នេះជាផ្នែកកណ្ដាល ។ ក៏ក្នុងបទថា **វិញ្ញាណកសិណំ (វិញ្ញាណកសិណ)** នេះ វិញ្ញាណប្រព្រឹត្តទៅក្នុងអាកាសដែលបើកជាកសិណ ។ ពិតហើយ វិញ្ញាណនោះលោកហៅថា វិញ្ញាណ ។ គប្បីជ្រាបសេចក្ដីជាខាងលើ ខាងក្រោម ខាងទទឹង ក្នុងវិញ្ញាណដែលប្រព្រឹត្តទៅក្នុងវិញ្ញាណកសិណនោះ ក៏ដោយអំណាចអាកាសដែលបើកជាកសិណ ។ នេះជាសេចក្ដីសង្ខេបក្នុងវិញ្ញាណកសិណនោះ ។ ចំណែកកកសិណ មានបឋវីកសិណជាដើមនោះ ក៏ពោលទុកពិស្ដារ

*ហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ដោយន័យនៃកម្មដ្ឋានភាវនានោះឯង ។*

ចប់អដ្ឋកថា កសិណសូត្រទី ៥

# អដ្ឋកថា កាលីសូត្រទី ៦

## *កាលីឧបាសិកាសួរបញ្ហាដល់ព្រះមហាកច្ចាយនៈ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កាលីសូត្រទី ៦ ដូចតទៅនេះ ៖*

[២៦] *បទថា* ***កុមារិបញ្ហេសុ (កុមារីបញ្ហា)*** *បានដល់ ក្នុងពាក្យសួររបស់ធីតាមារដែលនៅក្រមុំ ។ ត្រាស់ព្រះអរហត្តតែម្យ៉ាង ដោយបទទាំងពីរថា* ***អត្ថស្ស បត្តិ ហទយស្ស សន្តិ (ការសម្រេចប្រយោជន៍ជាសេចក្តីស្ងប់នៃព្រះហឫទ័យ)*** *។ បទថា* ***សេនំ (សេនា)*** *បានដល់ កងទ័ពកិលេស មានរាគៈជាដើម ។ បទថា* ***បិយសាតរូបំ (ដែលមានរូបជាទីស្រឡាញ់ ជាទីពេញចិត្ត)*** *បានឈ្មោះយ៉ាងនេះ ក៏ព្រោះកិលេសកើតក្នុងវត្ថុទាំងឡាយដែលគួរស្រឡាញ់ និងគួររីករាយ ។ បទថា* ***ឯកោហំ ឈាយី សុខមានុពោធឹ (តថាគត... តែម្នាក់សម្លឹងហើយ បានដឹងដោយលំដាប់នូវសេចក្តីសុខ)*** *សេចក្តីថា តថាគតតែម្នាក់ប៉ុណ្ណោះ ស្គាល់កងទ័ពកិលេសនេះ ទើបចូលឈានត្រាស់ដឹងបានដោយងាយ ។ បទថា* ***សក្ខី (មិត្តធម៌)*** *សេចក្តីថា បានដល់ ជាមិត្តធម៌ដែលដល់ភាពជាសាក្សី ។ បទថា* ***សក្ខី***

ន សម្បជ្ជតិ កេនចីមេ (ភាពជាមិត្ត ព្រោះនរណាៗ រមែងមិនសម្រេចដល់តថាគតឡើយ) សេចក្ដីថា តថាគតមិនមានមិត្តជាមួយនរណាៗ ។

បទថា បឋវីកសិណសមាបត្តិបរមា ខោ ភគិនិ ឯកេ សមណព្រាហ្មណា អត្ថាភិនិព្វត្តេសុំ (ប្អូនស្រី សមណព្រាហ្មណ៍ពួកមួយ ញុំាងប្រយោជន៍ទាំងឡាយ ដែលមានបឋវីកសិណសមាបត្តិដ៏យ៉ាងក្រៃលែងឲ្យកើតចំពោះហើយ) សេចក្ដីថា សមណព្រាហ្មណ៍ពួកមួយ ប្រកាន់ថា បឋវីកសិណសមាបត្តិ ជាប្រយោជន៍យ៉ាងក្រៃលែងបំផុត ទើបធ្វើឲ្យកើត ។ បទថា យាវតា ខោ ភគិនិ បឋវីកសិណសមាបត្តិបរមតា (ប្រយោជន៍មានបឋវីកសិណសមាបត្តិជាយ៉ាងក្រៃលែង) សេចក្ដីថា ប្រយោជន៍ មានបឋវីកសិណសមាបត្តិដ៏ខ្ពស់បំផុត ប្រមាណត្រឹមណា ។ បទថា តទភិញ្ញាសិ ភគវា (ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងហើយនូវប្រយោជន៍ មានបឋវីកសិណសមាបត្តិដ៏យ៉ាងក្រៃលែងនោះ) បានដល់ ព្រះដ៏មានព្រះភាគទ្រង់បានដឹងច្បាស់នូវបឋវីកសិណសមាបត្តិនោះ ដោយការដឹងដ៏ក្រៃលែងនូវប្រយោជន៍នោះ ដោយព្រះបញ្ញា ។ បទថា អាទិមទ្ទស្ស (ទ្រង់បាន

*ឃើញខាងដើម) បានដល់ ទ្រង់បានឃើញសមុទ័យសច្ចៈ ។ បទថា* **អាទី-នវមទ្ទស្ស** *(ទ្រង់បានឃើញទោស) បានដល់ ទ្រង់ឃើញទុក្ខសច្ចៈ ។ បទថា* **និស្សរណមទ្ទស្ស** *(ទ្រង់បានឃើញធម៌ជាគ្រឿងរលាស់ចេញ) បានដល់ ទ្រង់ឃើញនិរោធសច្ចៈ ។ បទថា* **មគ្គាមគ្គញ្ញាណទស្សនមទ្ទស្ស** *(ទ្រង់បានឃើញញាណទស្សនៈថា ជាផ្លូវ និងមិនមែនផ្លូវ) បានដល់ ទ្រង់បានឃើញមគ្គសច្ចៈ ។ បទថា* **អត្ថស្ស បត្តិ** *(ការសម្រេចប្រយោជន៍) បានដល់ ការសេពប្រយោជន៍ ពោលគឺ ព្រះអរហត្ត ព្រោះឃើញសច្ចៈទាំង ៤ នេះ ជាសេចក្ដីស្ងប់នៃព្រះហឫទ័យ ព្រោះសេចក្ដីខ្វល់ខ្វាយ និងសេចក្ដីក្ដៅក្រហាយស្ងប់ម្ងាប់អស់ហើយ ។*

ចប់អដ្ឋកថា កាលីសូត្រទី ៦

# អដ្ឋកថា បឋមមហាបញ្ហាសូត្រទី ៧

## បញ្ហា ឧទ្ទេស វេយ្យាករណ៍ តែមួយ មាន ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមមហាបញ្ហាសូត្រទី ៧ ដូចតទៅនេះ ៖*

*[២៧] បទថា **អភិជានាថ** (ចូរដឹងដ៏ក្រៃលែង) បានដល់ ចូរដឹងក្រៃលែង ធ្វើឲ្យប្រចក្ស ។ បទថា **អភិញ្ញាយ** ប្រែថា ដឹងក្រៃលែង ។ បទថា **ឥធ** (ក្នុង...នេះ) បានដល់ ក្នុងធម៌ទេសនា ឬអនុសាសនីនេះ ។ បទថា **ធម្មទេសនាយ វា ធម្មទេសនំ** (ធម៌ទេសនា និងធម៌ទេសនា) សេចក្តីថា ពួកតិរ្ថិយពោលថា ពួកលោកប្រារព្ធធម៌ទេសនារបស់យើងជាមួយព្រះធម៌ទេសនារបស់ព្រះសមណគោតម ឬព្រះធម៌ទេសនារបស់ព្រះសម-ណគោតមជាមួយធម៌ទេសនារបស់យើង ហើយពោលថាផ្សេងគ្នា ក៏ផ្សេងគ្នាយ៉ាងណា ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ ដូច្នោះ ពួកតិរ្ថិយទាំងនោះ ទើបតាំងលទ្ធិរបស់ខ្លួនប្រៀបជាមួយព្រះសាសនាថា មានធុរៈស្មើគ្នាត្រឹមតែដោយពាក្យនិយាយ ដូចតាំងជុំមាសទុកត្រង់កណ្តាល ដូច្នោះ បទថា **នេវ អភិនន្ទឹសុ** (មិនត្រេកអរ) បានដល់ មិនយល់ព្រមថា ប្រការ*

នោះ យ៉ាងនោះឯង ។ បទថា **ន បដិក្កោសីសុ (មិនជំទាស់)** បានដល់ មិនបដិសេធថា ប្រការនេះមិនដូច្នោះទេ ។ ព្រោះហេតុអ្វី ។ បានឮថា ពួកភិក្ខុទាំងនោះ មិនយល់ព្រម ដោយគិតថា ដែលឈ្មោះថា ពួកតិរ្ថិយ ជាពួកមនុស្សខ្វាក់ ដឹង ឬមិនដឹង ក៏ចេះតែនិយាយទៅ ។ បទថា **នេវ សម្បាយិស្សន្តិ (មិនអាចព្យាករណ៍ឲ្យដល់ព្រមបាន)** បានដល់ នឹងមិនអាចញ៉ាំងពាក្យព្យាករណ៍ឲ្យដល់ព្រម ហើយពោលបាន ។

បទថា **ឧត្តរឹបិ វិឃាតំ (សេចក្តីលំបាកខ្លាំងឡើង)** បានដល់ នឹងប្រសព្វទុក្ខក្រៃលែងឡើង ព្រោះតបមិនបាន ។ កាលពួកតិរ្ថិយតបមិនបាន ក៏កើតទុក្ខ ។ ក៏បទថា **តំ** ក្នុងបាលីថា **យថាតំ ភិក្ខវេ វិសយស្មឹ** នេះ ត្រឹមតែជានិបាត ។ បទថា **យថា** ជាពាក្យពោលដល់ហេតុ ។ អធិប្បាយថា ពួកតិរ្ថិយ ត្រូវសួរបញ្ហាក្នុងវត្ថុដែលមិនមែនវិស័យ ព្រោះហេតុណា ។ បទថា **ឥតោ វា បន សុត្វា (ឬអ្នកដែលស្តាប់ពីសាវករបស់តថាគត នេះ)** បានដល់ ក៏ឬថា ស្តាប់ពីសាសនារបស់តថាគតនេះ ។ ពិតហើយ គេស្តាប់ចាកពីសាសនានេះ គឺ ពីព្រះតថាគតខ្លះ ពីសាវករបស់ព្រះតថាគត

ខ្ទះ ហើយញ៉ាំងចិត្តឲ្យត្រេកអរ ព្រោះហេតុនោះ ទើបឈ្មោះថា ញ៉ាំងចិត្តឲ្យត្រេកអរ ព្រះមានព្រះភាគទ្រង់សម្តែងថា ឈ្មោះថា សេចក្តីត្រេកអរដោយប្រការដទៃ មិនមាន ។ បទថា **ឯកធម្មេ** ប្រែថា ក្នុងធម៌មួយ ។ ទ្រង់សម្តែងឧទ្ទេសដោយបទនេះ ។

ដោយបរន័យ ទ្រង់សម្តែងបញ្ហាដោយបទនេះថា **កតមស្មឹ ឯកធម្មេ** (ក្នុងធម៌មួយ ដូចម្តេច) ។ ក៏បទថា **សព្វេ សត្តា អាហារដ្ឋិតិកា (សត្វទាំងពួងមានអាហារជាទីតាំង)** នេះ ជាពាក្យវេយ្យាករណ៍ឆ្លើយក្នុងសេចក្តីនេះ ។ សូម្បីក្នុងបញ្ហាដ៏សេស ក៏ន័យនេះដូចគ្នា ។ ក៏ក្នុងបទថា **សម្មា និព្វិន្ទមានោ (កាលនឿយណាយដោយល្អ)** ជាដើម សេចក្តីថា កាលបើនឿយណាយ គឺ នឿយណាយដោយនិព្វិទាវិបស្សនាញាណ ប្រាសចាកតម្រេកដោយវិរាគានុបស្សនាញាណ ដឹងឧបាយនៃការរួចផុតហើយ រួចផុតដោយបដិសង្ខានុបស្សនាញាណ ឬរួចផុតដោយអំណាចអធិមោក្ខ ធ្វើទុកក្នុងចិត្តដោយប្រពៃ គឺ ដោយហេតុ ដោយន័យ ។ ឈ្មោះថា **មានប្រក្រតីឃើញទីបំផុតដោយល្អ** ព្រោះកំណត់ដោយការកើត និងសេចក្តីរលត់ហើយ

ឃើញខាងដើមខាងចុង ។ បទថា **សម្មត្តាភិសមេច្ច** (សម្រេចប្រយោជន៍ដោយល្អ) បានដល់ ត្រាស់ដឹងប្រយោជន៍នៃសភាវៈដោយល្អ ដោយញាណ ។ បទថា **ទុក្ខស្សន្តករោ ហោតិ** (រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន) បានដល់ធ្វើទីបំផុតនៃវដ្តទុក្ខទាំងអស់ ។ បទថា **សព្វេ សត្តា** (សត្វទាំងពួង) បានដល់ សត្វគ្រប់ប្រភេទ គ្រប់ភព មានកាមភពជាដើម មានសញ្ញាភពជាដើម និងមានឯកវោការភពជាដើម ។ បទថា **អាហារដ្ឋិតិកា** (ជាអ្នកមានអាហារជាទីតាំង) បានដល់ សត្វទាំងពួងឈ្មោះថា អាហារដ្ឋិតិកា ព្រោះចិញ្ចឹមជីវិតបានដោយអាហារ ។ ធម៌មួយ ឈ្មោះថា អាហារ ព្រោះជាហេតុតាំងនៅនៃសត្វទាំងពួង ដោយប្រការដូច្នេះ ។ ក្នុងធម៌មួយនោះ ។ សួរថា បើដូច្នោះ ពាក្យណាត្រាស់ថា អសញ្ញីទេវៈ មិនមានហេតុ មិនមានអាហារ មិនមានផស្សៈ ដូច្នេះជាដើម ពាក្យនោះ ក៏នឹងខុសឬ ។ ឆ្លើយថា មិនខុស ។ ព្រោះឈានរបស់អសញ្ញីសត្វនោះ រមែងជាអាហារ ។ សួរថា បើដូច្នោះ សូម្បីពាក្យថា ម្នាលភិក្ខុទាំងឡាយ អាហារ ៤ សូម្បីនេះ ក៏ខុសឬ ។ ឆ្លើយថា មិនខុស ។ ព្រោះក្នុងព្រះសូត្រនោះ ធម៌ទាំងឡាយ

ដែលមានលក្ខណៈជាអាហារ ត្រាស់ថា "អាហារដោយត្រង់" ។ ចំណែកក្នុងព្រះសូត្រនេះ បច្ច័យទាំងឡាយត្រាស់ថា "អាហារដោយអម" ។ ពិតហើយ បច្ច័យនៃធម៌ទាំងអស់គួរបានឈ្មោះថា អាហារ ព្រោះថា បច្ច័យនោះញុំាងផលណាៗ ឲ្យកើត ក៏ឈ្មោះថា រមែងនាំផលនោះៗ មក ព្រោះដូច្នោះ បច្ច័យលោកហៅថា អាហារ ។ ដោយហេតុនោះឯង ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សូម្បីអវិជ្ជាក៏មានអាហារ មិនពោលថា មិនមានអាហារ ម្នាលភិក្ខុទាំងឡាយ អ្វីជាអាហាររបស់អវិជ្ជា គប្បីពោលថា នីវរណៈ ៥ ។ ក្នុងព្រះសូត្រនេះ ទ្រង់បំណងយកបច្ចយាហារនេះ ។ ក៏កាលទ្រង់កាន់យកបច្ចយាហារមួយហើយ ទាំងអាហារដោយអម ទាំងអាហារដោយត្រង់ ក៏ទ្រង់កាន់យកទាំងអស់នោះឯង ។

ក្នុងអសញ្ញីភពនោះ ក៏រមែងបានបច្ចយាហារ ។ កាលព្រះពុទ្ធទ្រង់មិនទាន់ឧបត្តិ សត្វទាំងឡាយបួសក្នុងលទ្ធិតិរ្ថិយ ធ្វើបរិកម្មក្នុងវាយោកសិណ ធ្វើឈានឲ្យកើត ចេញចាកឈាននោះហើយ កើតសេចក្ដីពេញចិត្តថា ចិត្ត

នេះ បើមិនមានចិត្តទើបមិនទោមនស្ស ព្រោះអាស្រ័យចិត្ត ទើបកើតទុក្ខ មានការសម្លាប់ ការចាប់ចងជើមជាបច្ច័យ កាលមិនមានចិត្ត ទុក្ខនោះក៏មិនមាន ដូច្នេះ កាលឈានមិនវិនាស ធ្វើកាល (ស្លាប់) ក៏កើតក្នុងអសញ្ញីភព ។ ឥរិយាបថណា ដែលតាំងទុកហើយក្នុងមនុស្សលោក បុគ្គលនោះកើតតាមឥរិយាបថនោះ ដូចជារូបចិត្រកម្ម តាំងនៅ ៥០០ កប្ប ។ ដូចជាដេកលក់ដូច្នោះ ។ ពួកសត្វបែបនេះ ក៏បានបច្ច័យជាអាហារ ។ ពិតហើយ សត្វទាំងនោះ ចម្រើនឈានណាៗ កើតហើយ ឈាននោះឯងជាបច្ច័យរបស់សត្វទាំងនោះ ។ កូនសរដែលបាញ់ទៅ ព្រោះកម្លាំងនៃខ្សែធ្នូណា កម្លាំងនៃខ្សែធ្នូនៅមាន កូនសរក៏នៅសុះទៅបានដរាបនោះ យ៉ាងណា កាលបច្ច័យនៃឈាននៅមាន ដរាបនោះសត្វទាំងឡាយក៏តាំងនៅបាន ដូច្នោះ ។ កាលបច្ច័យនៃឈាននោះអស់ហើយ សត្វទាំងនោះក៏ធ្លាក់ទៅ (គឺត្រូវចុតិ) ដូចកូនសរដែលអស់កម្លាំងដូច្នោះ ។ សួរថា សត្វនរកពួកណា លោកពោលថា មិនមែនអាស្រ័យផលនៃសេចក្តីប្រឹងប្រែងរស់នៅ មិនមែនអាស្រ័យផលនៃបុណ្យរស់នៅ សត្វនរកទាំងនោះ មានអ្វីជាអាហារ ។ ឆ្លើយថា

សត្វនរកទាំងនោះ មានកម្មតែម្យ៉ាងជាអាហារ ។ សួរថា អាហារមាន ៥ ឬ ។ ឆ្លើយថា មិនគួរពោលថា អាហារមាន ៥ អាហារមានមិនសូម្បី ៥ ។ សួរថា បច្ច័យជាអាហារមិនមែនឬ ។ ឆ្លើយថា លោកពោលទុកយ៉ាងនេះថា ព្រោះដូច្នោះ សត្វទាំងឡាយកើតក្នុងនរកព្រោះកម្មណា កម្មនោះឯងជាអាហារ ព្រោះជាបច្ច័យនៃការតាំងនៅបាននៃសត្វទាំងនោះ ព្រោះហេតុនោះ លោកសំដៅយកកម្មណា ទើបពោលពាក្យនេះថា សត្វនរកនឹងមិនធ្វើកាលៈ ដរាបណាដែលបាបកម្មនោះមិនទាន់អស់ ។

សូម្បីប្រារព្ធកវឡិង្ការាហារ (អាហារ គឺ ដុំបាយ) ក៏មិនគួរជំទាស់គ្នាក្នុងរឿងអាហារនេះ ។ ការពិត សូម្បីទឹកមាត់ដែលកើតឡើងក្នុងមាត់ក៏សម្រេចកិច្ចជាអាហារសម្រាប់សត្វទាំងនោះ ព្រោះថា ទឹកមាត់ក៏ជាទុក្ខវេទនីយប្បច្ច័យ (បច្ច័យដែលឲ្យសោយទុក្ខ) ក្នុងនរក ជាសុខវេទនីយប្បច្ច័យ (បច្ច័យដែលឲ្យសោយសុខ) ក្នុងសួគ៌ ។ ព្រោះហេតុនេះ ក្នុងកាមភព ទើបមានអាហារ ៤ ដោយត្រង់ ។ ក្នុងបណ្ដារូបភព និងអរូបភព វៀរអសញ្ញភព អាហារ ៣ រមែងមានដល់ព្រហ្មដ៏សេស , បច្ចយាហារ

រមែងមានដល់អសញ្ញសត្វ និងសត្វដ៏សេស ព្រោះហេតុនោះ ទើបគួរជ្រាប ថា សត្វទាំងអស់តាំងនៅបានដោយអាហារ ដោយទំនងនេះ ។ ក្នុងរឿង អាហារនោះ គប្បីធ្វើការប្រកបសេចក្ដីក្នុងទីគ្រប់កន្លែង ដោយអំណាចសច្ចៈ ៤ យ៉ាងនេះថា អាហារ ៤ ឬបច្ចយាហារណាមួយ ជាទុក្ខសច្ចៈ ។ តណ្ហា មុនៗ ដែលមានអាហារជាសមុដ្ឋាន ជាសមុទយសច្ចៈ ។ ការមិនប្រព្រឹត្ត ទៅនៃសច្ចៈទាំង ២ ជានិរោធសច្ចៈ ។ បញ្ញាដឹងនិរោធសច្ចៈ ជាមគ្គសច្ចៈ ។

ចប់អដ្ឋកថា បឋមមហាបញ្ហាសូត្រទី ៧

# អដ្ឋកថា ទុតិយមហាបញ្ហាសូត្រទី ៨

## ឧបាសកអ្នកក្រុងកជង្គលៈសួរបញ្ហានឹងកជង្គលាភិក្ខុនី

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយមហាបញ្ហាសូត្រទី ៨ ដូចតទៅនេះ ៖*

*[២៨] បទថា **កជង្គលាយំ (ជិតកជង្គលៈ)** បានដល់ ជិតនគរមាន ឈ្មោះយ៉ាងនេះ ។ បទថា **កជង្គលា** ប្រែថា អ្នកក្រុងកជង្គលៈ ។ បទថា **មហាបញ្ហេសុ (ក្នុងមហាបញ្ហាទាំងឡាយ)** បានដល់ ក្នុងបញ្ហាដែលកំណត់ សេចក្តីធំៗ ។ បទថា **យថាមេត្ថ ជាយតិ (ក្នុងព្រះពុទ្ធភាសិតនេះ រមែង ប្រាកដដល់យើងដូចម្តេច)** សេចក្តីថា រមែងប្រាកដដល់ខ្ញុំក្នុងសេចក្តីនេះ ដោយប្រការណា ។ បទថា **សម្មាសុភាវិតចិត្តោ (អ្នកមានចិត្តដែលអប់រំ ហើយដោយល្អ)** បានដល់ អ្នកមានចិត្តដែលអប់រំដោយល្អ ដោយហេតុ ដោយន័យ ។ បទថា **ឯសោ ចេវ តស្ស អត្ថោ (និងអត្ថនៃពាក្យនោះ យ៉ាងនេះឯង)** សេចក្តីថា បញ្ហាជាដើមថា "ធម៌ ៤ ប្រការ" ដូច្នេះ ព្រះ មានព្រះភាគ ទ្រង់វិសជ្ជនាដោយន័យជាដើមថា "អាហារ ៤ យ៉ាង" ដូច្នេះ ជាដើមក៏ពិត តែព្រោះហេតុកាលកំណត់ដឹងអាហារ ៤ ហើយ សតិប្បដ្ឋាន*

៤ ក៏ជាការអប់រំហើយ និងកាលអប់រំសតិប្បដ្ឋាន ៤ ហើយ អាហារ ៤ ក៏ជាការកំណត់ដឹងហើយ ដូច្នោះ ក្នុងបញ្ហាប្រការនេះ ទើបផ្សេងគ្នាត្រឹមតែព្យញ្ជនៈ ព្រោះជាលំអរនៃទេសនាប៉ុណ្ណោះ ចំណែកអត្ថក៏ដូចគ្នានោះឯង ៗ ក្នុងធម៌មានឥន្ទ្រិយជាដើម ក៏ន័យនេះដូចគ្នា ៗ ព្រោះហេតុនោះទើបត្រាស់ថា នោះឯងជាខ្លឹមសារនៃកាសិតសង្ខេបរបស់តថាគតនោះ ៗ ពិតហើយ បើពោលដោយអត្ថ សូម្បីទាំង ២ ពាក្យនោះ ក៏ដូចជាមាសដែលប្រហោងខាងក្នុង ដូច្នោះ ៗ

ចប់អដ្ឋកថា ទុតិយមហាបញ្ហាសូត្រទី ៨

# អដ្ឋកថា បឋមកោសលសូត្រទី ៩

## *ព្រះមានព្រះភាគដោះស្រាយពាក្យពោល*

## *របស់សមណព្រាហ្មណ៍ក្រៅសាសនា*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមកោសលសូត្រទី ៩ ដូចតទៅនេះ ៖*

[២៩] *បទថា* ***យាវតា*** *ប្រែថា មានប្រមាណប៉ុនណា ។ បទថា* ***កាសីកោសលា (អ្នកដែនកាសី និងកោសល)*** *បានដល់ អ្នកដែនកាសី និងកោសលជនបទ ។ បទថា* ***អត្ថេវ អញ្ញថត្តំ*** *ប្រែថា ភាពជាយ៉ាងដទៃមានពិត ។ បទថា* ***អត្ថិ វិបរិណាមោ*** *ប្រែថា សូម្បីសេចក្តីប្រែប្រួលក៏មាន ។ បទថា* ***តស្មឹបិ និព្វិន្ទតិ (រមែងនឿយណាយសូម្បីការតាំងនៅក្នុងសមាបត្តិនោះ)*** *បានដល់ រមែងធុញទ្រាន់ក្នុងភាវៈនោះ ដែលតាំងនៅដោយសម្បត្តិ ។ បទថា* ***អគ្គេ វិរជ្ជតិ (រមែងមិនត្រេកអរក្នុងភាពនៃខ្លួនជាអ្នកប្រសើរ)*** *បានដល់ រមែងប្រាសចាកតម្រេក សូម្បីក្នុងភាវៈជាព្រះរាជាកោសលដែលប្រសើរដោយសម្បត្តិ ។ បទថា* ***បគេវ ហីនស្មឹ (នឹងចាំបាច់ពោលថ្វីក្នុងវត្ថុដ៏ថោកទាប)*** *សេចក្តីថា នឹងចាំបាច់ពោលទៅថ្វីក្នុង*

កាមគុណ ៥ របស់ពួកមនុស្សដ៏សេសដែលថោកទាបជាងនោះ ។ បទថា **មនោមយា (ជាអ្នកសម្រេចដោយចិត្ត)** សេចក្តីថា ដែលបង្កើតដោយចិត្ត ដែលសម្បយុត្តដោយឈាន ។

បទថា **ពារាណសេយ្យកំ** ប្រែថា ដែលកើតឡើងក្នុងក្រុងពារាណសី ។ ពិតហើយ ក្នុងក្រុងពារាណសីនោះ សូម្បីកប្បាសក៏ទន់ល្អ ជុំសរសៃអំបោះក្តី ការត្បាញក្តី ក៏ធ្វើដោយសេចក្តីឆ្លាត សូម្បីទឹកក៏ស្អាតស្អាបល្អ ។ បទថា **ឧភតោភាគវិមដ្ឋំ (មានសាច់មដ្ឋទាំងពីរខាង)** បានដល់ ប្រាកដជាមដ្ឋល្អទាំង ២ ខាង ទន់ល្មែ សាច់ផូរផង់ ។ ទ្រង់ត្រាស់បដិបទា ៤ លាយគ្នា ទាំងលោកិយៈ និងលោកុត្តរៈ ។

បណ្តាសញ្ញាទាំងឡាយ សញ្ញាទី ១ គឺ កាមាវចរសញ្ញា សញ្ញាទី ២ គឺ រូបាវចរសញ្ញា សញ្ញាទី ៣ គឺ លោកុត្តរសញ្ញា សញ្ញាទី ៤ គឺ អាកិញ្ចញ្ញាយតនសញ្ញា ។ តែព្រោះហេតុដែលសញ្ញានោះ នាំមកថាជាកំពូល ដូច្នេះ ទ្រង់មិនបានបញ្ញត្តិសញ្ញាដទៃក្រៅពីនោះ ដូច្នោះ ទើបត្រាស់ថាជាកំពូល ។ បទថា **ពាហិរកានំ (ក្រៅព្រះសាសនា)** បានដល់

ទិដ្ឋិដែលប្រព្រឹត្តទៅខាងក្រៅព្រះសាសនា ។ បទថា នោ ចស្សំ នោ ច មេ សិយា (ប្រសិនបើយើងមិនមាន អត្តភាពនេះក៏មិនគប្បីមានដល់យើង) សេចក្តីថា យើងមិនធ្លាប់មានក្នុងអតីត សូម្បីបច្ចុប្បន្នអត្តភាពនេះរបស់យើងក៏មិនគប្បីមាន ។ បទថា ន ភវិស្សាមិ ន មេ ភវិស្សតិ (បើយើងនឹងមាន សេចក្តីប្រាថ្នាក្នុងអ្វី នឹងមិនមានដល់យើង) សេចក្តីថា សូម្បីក្នុងអនាគត យើងនឹងមិនមាន សេចក្តីកង្វល់អ្វីរបស់យើងក៏នឹងមិនមាន ។

បទថា អគ្គេ វិរជ្ជតិ (រមែងមិនត្រេកអរក្នុងវត្ថុដ៏ប្រសើរ) បានដល់ រមែងមិនត្រេកអរក្នុងឧច្ឆេទទិដ្ឋិ ។ ពិតណាស់ ឧច្ឆេទទិដ្ឋិ ឈ្មោះថា ជាកំពូល ព្រោះជាគ្រឿងរារាំងព្រះនិព្វានក្នុងព្រះសាសនានេះ ។ បទថា បរមយក្ខវិសុទ្ធី ប្រែថា សេចក្តីបរិសុទ្ធក្នុងសត្វដ៏ប្រសើរ ។ ពាក្យនេះជាឈ្មោះរបស់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ ពិតហើយ អាកិញ្ចញ្ញាយតនៈ ឈ្មោះថា ប្រសើរ ព្រោះជាបទដ្ឋាននៃវិបស្សនា នេវសញ្ញានាសញ្ញាយតនៈឈ្មោះថា ប្រសើរ ព្រោះមានអាយុវែងនោះឯង ។

បទថា បរមទិដ្ឋធម្មនិព្វានំ (និព្វានដែលប្រសើរក្រៃលែងក្នុងបច្ចុប្បន្ន)

បានដល់ និព្វានជាកំពូលក្នុងអត្តភាពនេះឯង ។ បទថា **អនុបាទាវិមោក្ខោ (ការរួចផុតព្រោះមិនប្រកាន់មាំ)** បានដល់ ការរួចផុតនៃចិត្ត ព្រោះមិនប្រកាន់ដោយឧបាទាន ៤ ។ ពាក្យនេះ ជាឈ្មោះរបស់ព្រះអរហត្ត ។ បទថា **បរិញ្ញំ (ការកំណត់ដឹង)** បានដល់ ការឈានកន្លង ។ ក្នុងពាក្យនោះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តិការកំណត់ដឹងកាមទាំងឡាយ ដោយបឋម-ឈាន ទ្រង់បញ្ញត្តិការកំណត់ដឹងរូបទាំងឡាយ ដោយអរូបាវចរឈានទាំងឡាយ ទ្រង់បញ្ញត្តិការកំណត់ដឹងវេទនាទាំងឡាយ ដោយអនុបាទាបរិនិព្វាន ។ ក៏ព្រះនិព្វាន ឈ្មោះថា កំណត់ដឹងវេទនាទាំងឡាយ ព្រោះលះបង់វេទនានោះឯង ។ បទថា **អនុបាទាបរិនិព្វានំ (អនុបាទាបរិនិព្វាន)** បានដល់ អបច្ចយបរិនិព្វាន (និព្វានដែលរកបច្ច័យមិនបាន) ។ តែព្រះមានព្រះភាគកាលត្រាស់ព្រះសូត្រនេះ ទ្រង់ឃើញភិក្ខុ ៥០០ រូប ត្រូវសេចក្តីមិនត្រេកអរបៀតបៀន ទើបត្រាស់ដើម្បីបន្ទោបង់សេចក្តីមិនត្រេកអររបស់ពួកភិក្ខុនោះ ។ សូម្បីភិក្ខុទាំងនោះ បន្ទោបង់ការមិនត្រេកអរបានហើយ ជម្រះញាណតាមក្រសែទេសនា ក៏ជាសោតាបន្ន ក្រោយមកចម្រើនវិបស្សនា ក៏សម្រេចជា

*ព្រះអរហត្តឯង ។*

ចប់អដ្ឋកថា បឋមកោសលសូត្រទី ៩

# អដ្ឋកថា ទុតិយកោសលសូត្រទី ១០

## (ព្រះបាទបសេនទិកោសលទ្រង់នមស្ការព្រះមានព្រះភាគ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយកោសលសូត្រទី ១០ ដូចតទៅនេះ ៖*

[៣០] បទថា **ឧយ្យោធិកាយ និវត្តោ ហោតិ** ប្រែថា ស្តេចត្រឡប់មកពីការច្បាំង ។ បទថា **លទ្ធាធិប្បាយោ** (សមតាមព្រះរាជបំណងហើយ) សេចក្តីថា បានឮថា ព្រះបាទមហាកោសល កាលថ្វាយព្រះធីតាដល់ព្រះបាទពិម្ពិសារ ក៏ព្រះរាជទានកាសីជនបទ ដែលមានតម្លៃមួយសែន ចន្លោះដែនរបស់ព្រះរាជាទាំងពីរ ដល់ព្រះធីតា ។ កាលព្រះបាទអជាតសត្តុផ្តាច់ព្រះជន្មព្រះជនកហើយ សូម្បីព្រះមាតារបស់ព្រះអង្គ មិនយូរប៉ុន្មានក៏ទិវង្គតដោយសេចក្តីសោកសៅ ហេតុវិបយោគដល់ព្រះរាជស្វាមី ។ គ្រានោះព្រះបាទបសេនទិកោសល ទ្រង់ត្រិះរិះថា ព្រះបាទអជាតសត្តុផ្តាច់ព្រះជន្មព្រះជនកព្រះជននី កាសីជនបទក៏គួរធ្លាក់មកជាសម្បត្តិរបស់ព្រះបិតាយើង ទើបទ្រង់សាងរោងច្បាំង ដើម្បីត្រូវការកាសីជនបទនោះ ។ ដើម្បីប្រាថ្នាដល់ជនបទនោះ ស្តេចអាំ និងស្តេចក្មួយ ទាំងពីរព្រះអង្គ ទ្រង់ទើបលើកចតុ-

វង្គគិរីសេនាច្បាំងគ្នា ។ ក្នុងសង្គ្រាមនោះ ព្រះបាទបសេនទិកោសលទ្រង់ចាញ់ ២ ដង ទើបស្តេចត្រឡប់ចូលព្រះនគរ លើកទី ៣ ទ្រង់ត្រិះរិះថា យើងគប្បីឈ្នះបានយ៉ាងណាហ្ន៎ ទ្រង់បានដឹងអាការដែលគួរច្បាំងដោយវិធីស៊ើបការណ៍ ។ ទើបទ្រង់សម្តែងកងទ័ពលោមព័ទ្ធទាំងពីរខាង ចាប់ព្រះបាទអជាតសត្រូវបានដោយរហ័ស ទើបទ្រង់បានឈ្មោះថា ទ្រង់បានសមតាមព្រះបំណង ព្រោះទ្រង់បានជ័យជំនះសមតាមប្រាថ្នា ។

បទថា យេនារាមោ តេន បាយាសិ (ស្តេចបានទៅកាន់អារាម) សេចក្តីថា ទ្រង់ឲ្យតាំងបន្ទាយឆ្លងជ័យក្រៅព្រះនគរ ទ្រង់ត្រិះរិះថា អ្នកព្រះនគរតាក់តែងព្រះនគរហើយត្រឹមណា យើងនឹងថ្វាយបង្គំព្រះសាស្តាត្រឹមនោះ ព្រោះថា វេលាដែលចូលព្រះនគរហើយក៏នឹងយឺតយូរ ទ្រង់មានពួកអាមាត្យហែហមហើយ ស្តេចក៏ទ្រង់យាងទៅព្រះអារាម ហើយស្តេចចូលទៅកាន់ព្រះអារាម ។ សួរថា ស្តេចចូលទៅវេលាណា ។ ឆ្លើយថា កាលព្រះសម្មាសម្ពុទ្ធប្រទានឱវាទដល់ពួកភិក្ខុដែលត្រឡប់មកពីបិណ្ឌបាត ស្តេចចូលព្រះគន្ធកុដិ និងកាលភិក្ខុសង្ឃទទួលព្រះឱវាទហើយ ចូលទៅកាន់ទី

សម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃរបស់ខ្លួនៗ ។

បទថា **ចង្កមន្តិ (ដើរចង្ក្រម)** សួរថា ភិក្ខុទាំងឡាយកំពុងចង្ក្រម ក្នុងវេលានោះ ព្រោះហេតុអ្វី ។ ឆ្លើយថា ភិក្ខុទាំងនោះចង្ក្រមវេលាថ្ងៃ ដើម្បីបន្ទោបង់ថីនមិទ្ធៈ (សេចក្ដីងងុយងោកងក់) ព្រោះការឆាន់ភោជន ដែលប្រណីតជាបច្ច័យ ។ ពិតហើយ ពួកភិក្ខុទាំងនោះចង្ក្រមខាងក្រោយ ឆាន់អាហារ ផឹកទឹកជម្រះខ្លួនហើយ អង្គុយធ្វើសមណធម៌ ទើបចិត្តនឹងមាន អារម្មណ៍តែមួយ ។ បទថា **យេន តេ ភិក្ខូ (ភិក្ខុទាំងនោះ)** សេចក្ដីថា ន័យថា ព្រះបាទបសេនទិកោសលនោះ ទ្រង់ត្រិះរិះថា ព្រះសុគតប្រថាប់ នៅទីណា ដូច្នេះ ស្ដេចយាងមើលទូទាំងបរិវេណ ដោយមានព្រះបំណង នឹងចូលទៅទូលសួរ ទ្រង់ទតឃើញពួកភិក្ខុដែលសមាទានបង្សុកូលិកង្គ-ធុតង្គកំពុងចង្ក្រមក្នុងទីចង្ក្រមធំ ដូចដំរីក្នុងព្រៃ ទើបស្ដេចចូលទៅរកភិក្ខុ ទាំងនោះ ។ លោកសំដៅយកសេចក្ដីនោះ ទើបពោលពាក្យនេះ ។

បទថា **ទស្សនកាមា** ប្រែថា បំណងនឹងគាល់ ។ ភិក្ខុទាំងឡាយ សំដៅយកព្រះគន្ធកុដិ ទើបពោលថា **ព្រះវិហារ** ។ បទថា **អតរមានោ**

ប្រែថា មិនប្រញាប់ប្រញាល់ អធិប្បាយថា សន្សឹមៗ ដាក់ព្រះបាទចុះលើទីដ៏សមគួរដល់ព្រះបាទ មិនឲ្យខ្សាច់ដែលប្រៀបដូចជាកែវមុក្តា ឬឈើកៀខ្សាច់ដែលរាបស្មើល្អ ត្រូវវិនាស ។ បទថា **អាឡិន្ទំ** ប្រែថា របៀង ។ បទថា **អគ្គឡំ** (ទ្វា) បានដល់ សន្ទះទ្វារ ។ បទថា **ឧក្កាសិត្វា** (ទ្រង់គ្រហែម) បានដល់ **ធ្វើសំឡេងក្រហែម** ។ បទថា **អាកោដេហិ** (ទ្រង់គោះ) លោកអធិប្បាយថា យកចុងក្រចកគោះតិចៗ ជិតប្រហោងរន្ទុក ។ គេថា ពួកអមនុស្ស គោះទ្វារខ្ពស់ ពួកទីឃជាតិ គោះខាងក្រោម ព្រះបាទបសេនទិកោសលគោះ គប្បីទ្រង់គោះត្រង់កណ្តាលជិតប្រហោងរន្ទុក ព្រោះដូច្នោះ អាចារ្យពួកខ្លះសម្តែងថា នេះជាធម្មទំនៀមនៃការគោះទ្វារ ។

បទថា **វិវរិ ភគវា ទ្វារំ** (ព្រះមានព្រះភាគទ្រង់បើកទ្វារ) សេចក្តីថា ព្រះមានព្រះភាគស្តេចមិនក្រោកឡើងទៅបើកទ្វារ តែទ្រង់លាព្រះហស្តត្រាស់ថា បើកចុះ ។ អំពីនោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះថា កាលព្រះអង្គឲ្យទានមកច្រើនកោដិកប្ប មិនធ្លាប់ធ្វើការបើកទ្វារដោយដៃខ្លួនឯង ដូច្នេះ ទ្វារក៏បើកឯង ។ តែព្រោះហេតុដែលទ្វារនោះបើកដោយព្រះហឫទ័យ

របស់ព្រះមានព្រះភាគ ដូច្នោះ ទើបគួរពោលថា ព្រះមានព្រះភាគ (ទ្រង់មិនបានក្រោកឡើង) ទៅបើកទ្វារ ។ បទថា មេត្តូបហារំ (ថ្វាយសេចក្ដីរាប់អានដែលប្រកបដោយមេត្តា) បានដល់ ការបង្អោនចូលទៅផ្លូវកាយ និងវាចាប្រកបដោយមេត្តា ។ បទថា កតញ្ញុតំ (កតញ្ញូ) សេចក្ដីថា ក៏ព្រះរាជាព្រះអង្គនេះ ពីមុន ទ្រង់មានព្រះសរីរៈធាត់ សោយបាយមួយនាឡិ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ប្រទានឱវាទដល់ស្ដេច យ៉ាងនេះថា ៖

បុគ្គលអ្នកមានសតិគ្រប់កាល ស្គាល់ប្រមាណក្នុងភោជន

ដែលបានហើយ គេក៏មានវេទនាស្រាលខ្លះ អាហារដែល

បរិភោគក៏រលួយល្អ រមែងរក្សាអាយុទុកបាន ។

ស្ដេចតាំងនៅក្នុងព្រះឱវាទនេះ បន្ថយអាហារម្ដងបន្តិចៗ រាល់ៗ ថ្ងៃ មកនៅត្រឹមល្មម ដែលមានបាយមួយនាឡិជាយ៉ាងខ្ពស់ មកដោយលំដាប់ សូម្បីព្រះសរីរកាយរបស់ស្ដេច ក៏ស្រាលរឹងមាំ ។ ស្ដេចទ្រង់សំដៅយកឧបការៈដែលព្រះមានព្រះភាគទ្រង់ធ្វើហើយនោះ ទើបក្រាបទូលថា ខ្ញុំព្រះអង្គ

ឃើញកតញ្ញូកតវេទីនោះឯង ។ បទថា **អរិយញ្ញាយេ** (អរិយញ្ញាយធម៌) បានដល់ មគ្គព្រមទាំងវិបស្សនា ។ បទថា **ពុទ្ធសីលោ** ប្រែថា អ្នកមានសីលដ៏ចម្រើន ។ បទថា **អរិយសីលោ** (អ្នកមានសីលដ៏ប្រសើរ) បានដល់ អ្នកប្រកបដោយសីលដែលមិនមែនរបស់បុថុជ្ជន ។ បទថា **កុសល-សីលោ** (មានសីលជាកុសល) បានដល់ អ្នកប្រកបដោយសីលទាំងឡាយដែលមិនមានទោស ។ បទថា **អារញ្ញកោ** (ទ្រង់កាន់យកការនៅព្រៃជាវត្ត) សេចក្តីថា ស្តេចកាលទ្រង់សម្តែងថា ព្រះមានព្រះភាគសូម្បីកើតក៏កើតក្នុងព្រៃ សូម្បីត្រាស់ដឹងក៏ត្រាស់ដឹងក្នុងព្រៃ សូម្បីនៅក្នុងព្រះគន្ធកុដិដែលដូចទេវវិមាន ក៏ប្រថាប់នៅក្នុងព្រៃដូចគ្នា ទើបក្រាបទូលយ៉ាងនេះ ។ ពាក្យដ៏សេសក្នុងគ្រប់ៗ បទ មានសេចក្តីងាយហើយនោះឯង ។

ចប់អដ្ឋកថា ឧតិយកោសលសូត្រទី ១០

## ចប់មហាវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# ឧបាលិវគ្គវណ្ណនាទី ៤

## អដ្ឋកថា បឋមឧបាលិសូត្រទី ១

### *ព្រះតថាគតទ្រង់អាស្រ័យប្រយោជន៍ ១០ ប្រការ*

### *ទ្រង់បញ្ញត្តិសិក្ខាបទ និងសម្តែងបាតិមោក្ខ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមឧបាលិសូត្រទី ១ ដូចតទៅនេះ ៖*

[៣១] *ឈ្មោះថា សង្ឃសុដ្ឋុតាយ (ដើម្បីសេចក្តីល្អនៃសង្ឃ) បាន ដល់ សេចក្តីល្អនៃសង្ឃ គឺ ដែលសង្ឃព្រមព្រៀងដោយពាក្យដែលគួរ ស្រឡាញ់ថា "ករុណា ព្រះអង្គ" ដូចក្នុងអនាគតស្ថានថា ករុណា ទេវៈ ។ ក៏សង្ឃណាទទួលព្រះតម្រាស់របស់ព្រះតថាគតយ៉ាងនោះ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់សង្ឃរហូតអស់កាល ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់បញ្ញត្តិសិក្ខាបទ ក៏ដើម្បីសង្ឃទទួលដោយពាក្យដែល គួរស្រឡាញ់ថា "ព្រះករុណា ព្រះអង្គ" ព្រះមានព្រះភាគត្រាទ្រង់សម្តែង ទោសក្នុងការមិនទទួល និងអានិសង្សក្នុងការទទួល កាលទ្រង់ធ្វើឲ្យជាក់ ច្បាស់ក្នុងសេចក្តីនេះថា ទ្រង់មិនបានកាន់អំណាចដោយពលការ ទើបត្រាស់*

ថា "ដើម្បីសេចក្តីល្អនៃសង្ឃ" ។ បទថា **សង្ឃផាសុតាយ** (ដើម្បីការនៅជាសុខនៃសង្ឃ) បានដល់ ដើម្បីសេចក្តីសុខ ដើម្បីការមានជីវិតរួមគ្នានៃសង្ឃ អធិប្បាយថា ដើម្បីប្រយោជន៍ដល់ការនៅជាសុខ ។

បទថា **ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ** (ដើម្បីគ្របសង្កត់បុគ្គលអ្នកមិនអៀនខ្មាស) សេចក្តីថា បុគ្គលដែលទ្រុស្តសីល ឈ្មោះថាអ្នកមិនអៀនខ្មាស ។ បុគ្គលពួកណា សូម្បីត្រូវគេធ្វើឲ្យដល់សេចក្តីអៀនខ្មាស ក៏មិនទោមនស្ស កាលប្រព្រឹត្តកន្លងសិក្ខាបទ ឬធ្វើហើយ ក៏មិនខ្មាសបាប , ដើម្បីប្រយោជន៍ដល់ការគ្របសង្កត់បុគ្គលទាំងនោះ ។ ពិតហើយ ភិក្ខុទាំងនោះ កាលសិក្ខាបទមិនមាន ក៏នឹងបៀតបៀនសង្ឃថា ពួកលោកឃើញអ្វី បានឮអ្វី ពួកខ្ញុំធ្វើអ្វី ទើបពួកលោកលើកអាបត្តិ ក្នុងវត្ថុដែលណាមកគ្របសង្កត់ពួកខ្ញុំ តែកាលសិក្ខាបទមានហើយ សង្ឃនឹងសម្តែងសិក្ខាបទដល់ភិក្ខុទាំងនោះ គ្របសង្កត់ដោយសហធម៌ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ដើម្បីគ្របសង្កត់បុគ្គលដែលមិនអៀនខ្មាស ។

បទថា **បេសលានំ** (អ្នកមានសីលជាទីស្រឡាញ់) បានដល់ ដើម្បី

ប្រយោជន៍ដល់ការនៅជាសុខរបស់ពួកភិក្ខុ ដែលមានសីលជាទីស្រឡាញ់ ។ ពិតណាស់ ភិក្ខុដែលមានសីលជាទីស្រឡាញ់ ដឹងប្រការទីគួរធ្វើ និងមិនគួរធ្វើ ប្រការដែលមានទោស និងមិនមានទោស បន្ទាត់ និងព្រំដែន ព្យាយាមធ្វើត្រៃសិក្ខាឲ្យបរិបូរណ៍ រមែងមិនលំបាក ព្រោះហេតុនោះ ការបញ្ញត្តិសិក្ខាបទ ទើបប្រព្រឹត្តទៅដើម្បីនៅជាសុខនៃភិក្ខុទាំងនោះ ឬការគ្របសង្កត់បុគ្គលដែលមិនអៀនខ្មាសនោះឯង ជាការនៅជាសុខនៃភិក្ខុទាំងនោះ ។ អាស្រ័យបុគ្គលដែលទ្រុស្តសីល ឧបោសថ និងបវារណាក៏តាំងនៅមិនបាន សង្ឃកម្មក៏ប្រព្រឹត្តទៅមិនបាន មិនមានការសាមគ្គីគ្នា ភិក្ខុទាំងឡាយមានអារម្មណ៍ច្រើន ក៏ប្រកបឧទ្ទេសជាដើមមិនបាន តែកាលបុគ្គលដែលទ្រុស្ត-សីលត្រូវគ្របសង្កត់ហើយ ឧបទ្រវៈសូម្បីទាំងអស់ក៏មិនមាន តពីនោះ ភិក្ខុដែលមានសីលជាទីស្រឡាញ់ រមែងនៅជាសុខ ។ ក្នុងពាក្យថា ***បេសលានំ ភិក្ខូនំ ផាសុវិហារាយ*** (ដើម្បីការនៅសប្បាយនៃភិក្ខុទាំងឡាយអ្នកមានសីលជាទីស្រឡាញ់) នេះ គប្បីជ្រាបអត្ថពីរចំណែក ដោយប្រការដូច្នេះ ។

បទថា ***ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ*** (ដើម្បីរាំងអាសវៈទាំង

ឡាយដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន) សេចក្តីថា ទុក្ខពិសេសមានការប្រហារដោយបាតដៃ ប្រហារដោយកំណាត់ឈើ ប្រហារដោយសស្ត្រា កាត់ដៃ កាត់ជើង វិនាសកិត្តិយស និងសេចក្តីក្តៅក្រហាយចិត្ត ជាអ្នកតាំងនៅក្នុងការមិនសង្រួម គប្បីមានក្នុងអត្តភាពនោះប៉ុណ្ណោះ ឈ្មោះថា អាសវៈដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ដើម្បីរាំងការពារ គឺ បិទផ្លូវមកនៃអាសវៈដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននោះ ។ បទថា **សម្បរាយិកានំ (ដែលប្រព្រឹត្តទៅក្នុងភពខាងមុខ)** សេចក្តីថា ទុក្ខពិសេសមានបាបកម្មដែលធ្វើហើយជាមូលដែលបុគ្គលតាំងនៅក្នុងការមិនសង្រួម គប្បីដល់អបាយ មាននរកជាដើមក្នុងភពខាងមុខ ឈ្មោះថា អាសវៈដែលប្រព្រឹត្តទៅក្នុងខាងមុខ ដើម្បីជាប្រយោជន៍ដល់ការរម្ងាប់អាសវៈដែលប្រព្រឹត្តទៅក្នុងចំណែកខាងមុខនោះ ។

បទថា **អប្បសន្នានំ (នៃបុគ្គលទាំងឡាយដែលនៅមិនទាន់ជ្រះថ្លា)** សេចក្តីថា កាលមានការបញ្ញត្តិសិក្ខាបទ មនុស្សស្លូតបូតពួកណាជាបណ្ឌិតដែលមិនទាន់ជ្រះថ្លា ដឹងការបញ្ញត្តិសិក្ខាបទ ឬឃើញភិក្ខុបដិបត្តិសិក្ខាបទតាមដែលទ្រង់បញ្ញត្តិ មនុស្សទាំងនោះ រមែងដល់សេចក្តីជ្រះថ្លាថា សមណៈ

ទាំងនេះ វៀរចាកឋានៈជាទីតាំងនៃសេចក្តីស្រឡាញ់ សេចក្តីក្រោធ សេចក្តីវង្វេងនៃមហាជនក្នុងលោក ឈ្មោះថា ធ្វើកិច្ចដែលធ្វើបានលំបាកហ្ន៎ ឃើញគម្ពីរក្នុងព្រះវិន័យបិដកក៏ជ្រះថ្លា ដូចកតវេទិព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ***ដើម្បីសេចក្តីជ្រះថ្លានៃបុគ្គលដែលមិនទាន់ជ្រះថ្លា*** ។

បទថា ***បសន្នានំ*** ***(នៃបុគ្គលទាំងឡាយដែលជ្រះថ្លាហើយ)*** សេចក្តីថា កុលបុត្រពួកណាជ្រះថ្លាក្នុងព្រះសាសនាហើយ កុលបុត្រពួកនោះដឹងការបញ្ញត្តិសិក្ខាបទ ឬឃើញភិក្ខុបដិបត្តិតាមសិក្ខាបទដែលទ្រង់បញ្ញត្តិ រមែងជ្រះថ្លាក្រៃលែងឡើងៗ ថា ឱ! លោកម្ចាស់របស់ខ្ញុំតែមួយ រក្សាព្រហ្មចរិយៈសង្រួមដរាបអស់ជីវិត ឈ្មោះថា ធ្វើកិច្ចដែលធ្វើបានលំបាកហ្ន៎ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ដើម្បីសេចក្តីជ្រះថ្លាក្រៃលែងឡើងៗរបស់អ្នកដែលជ្រះថ្លាហើយ ។

បទថា ***សទ្ធម្មដ្ឋិតិយា*** ***(ដើម្បីការតាំងមាំនៃព្រះសទ្ធម្ម)*** សេចក្តីថា សទ្ធម្ម មាន ៣ យ៉ាង គឺ បរិយត្តិសទ្ធម្ម បដិបត្តិសទ្ធម្ម អធិគមសទ្ធម្ម ។

បណ្ដាសទ្ធម្ម ៣ យ៉ាងនោះ ព្រះពុទ្ធវចនៈទាំងអស់ ឈ្មោះថា **បរិយត្តិ-សទ្ធម្ម** , សទ្ធម្មនេះ គឺ ធុតង្គគុណ ១៣ ចារិតសីល វារិតសីល សមាធិ វិបស្សនា ឈ្មោះថា **បដិបត្តិសទ្ធម្ម** ។ លោកុត្តរធម៌ ៩ ឈ្មោះថា **អធិ-គមសទ្ធម្ម** ។ ព្រះសទ្ធម្មសូម្បីទាំងអស់នោះ ព្រោះហេតុមានការបញ្ញត្តិសិក្ខាបទ ភិក្ខុទាំងឡាយ រមែងរៀនសិក្ខាបទ វិភង្គនៃសិក្ខាបទនោះ និងព្រះពុទ្ធវចនៈដទៃ ដើម្បីបំភ្លឺសេចក្ដីនៃសិក្ខាបទ និងវិភង្គនោះ និងកាលបដិបត្តិសិក្ខាបទតាមដែលទ្រង់បញ្ញត្តិ បំពេញវត្តបដិបត្តិ រមែងបានសម្រេចលោកុត្តរធម៌ដែលគប្បីសម្រេចដោយវត្តបដិបត្តិ ដូច្នោះ ព្រះសទ្ធម្មទើបតាំងនៅយឺនយូរព្រោះការបញ្ញត្តិសិក្ខាបទ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ដើម្បីសេចក្ដីតាំងមាំនៃព្រះសទ្ធម្ម** ។

បទថា **វិនយានុគ្គហាយ (ដើម្បីអនុគ្រោះព្រះវិន័យ)** សេចក្ដីថា កាលមានការបញ្ញត្តិសិក្ខាបទ ក៏ជាការអនុគ្រោះ ឧបត្ថម្ភគាំទ្រព្រះវិន័យសូម្បីទាំង ៤ យ៉ាង គឺ សំវរវិន័យ បហានវិន័យ សមថវិន័យ បញ្ញត្តិ-វិន័យ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ដើម្បីអនុគ្រោះដល់**

ព្រះវិន័យ ៗ

ចប់អដ្ឋកថា បឋមឧបាលិសូត្រទី ១

# អដ្ឋកថា ទុតិយឧបាលិសូត្រទី ២[១]

## ការបញ្ជាប់ការសូត្របាតិមោក្ខ ១០ ប្រការ

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយឧបាលិសូត្រទី ២ ដូចតទៅនេះ ៖

[៣១] បទថា *បារាជិកោ* (ភិក្ខុត្រូវបារាជិក) បានដល់ អ្នកត្រូវអាបត្តិបារាជិក ។ បទថា *បារាជិកកថា វិប្បកតា ហោតិ* (កថាប្រារព្ធបារាជិក ជារឿងធ្វើមិនស្រេច) សេចក្តីថា រឿងយ៉ាងនេះថា បុគ្គលឈ្មោះឯណោះ ត្រូវអាបត្តិបារាជិកឬហ្ន៎ ជាការផ្តើមទុកហើយនៅមិនទាន់ចប់ ក្នុងបទទាំងពួង ក៏ន័យនេះដូចគ្នា ។

ចប់អដ្ឋកថា ទុតិយឧចាលិសូត្រទី ២

(១) សូត្រនេះ បិដកសម្តែងរួមជាមួយសូត្រទី ១ តែអដ្ឋកថា ជាសូត្រទី ២ ដូច្នេះហើយ ចានជាលេខឃ្លាបរក្សានៅដដែល ។

# អដ្ឋកថា ឧព្វាហសូត្រទី ៣

## ភិក្ខុប្រកបដោយធម៌ ១០ ប្រការ សង្ឃសន្មតឲ្យសើរើអធិករណ៍

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧព្វាហសូត្រទី ៣ ដូចតទៅនេះ ៖

[៣២] បទថា **ឧព្វាហិកាយ** (ដើម្បីឲ្យជាអ្នកសើរើអធិករណ៍) បានដល់ ដើម្បីប្រយោជន៍ដល់ការសើរើលើកឡើងដោយសង្ឃ ក្នុងការរម្ងាប់អធិករណ៍ដែលមកដល់ហើយ ។ បទថា **វិនយេ ខោ បន ឋិតោ ហោតិ** (ភិក្ខុនោះជាអ្នកខ្ជាប់ខ្ជួនក្នុងព្រះវិន័យ) បានដល់ ជាអ្នកតាំងនៅក្នុងលក្ខណៈនៃវិន័យ ។ បទថា **អសំហីរោ** (មិនញាប់ញ័រ) បានដល់ មិនលះបោលលទ្ធិរបស់ខ្លួន ដោយហេតុត្រឹមតែពាក្យនិយាយរបស់បុគ្គលដទៃ ។ បទថា **បដិពលោ** (ជាអ្នកអង់អាច) បានដល់ ប្រកបដោយកម្លាំងកាយខ្លះ កម្លាំងប្រាជ្ញាខ្លះ ។ បទថា **សញ្ញាបេតុំ** ប្រែថា ឲ្យព្រមព្រៀង ។ បទថា **និជ្ឈាបេតុំ** (ឲ្យសម្លឹងមើល) បានដល់ ឲ្យសម្លឹងមើល ។ បទថា **បេក្ខាតុំ** ប្រែថា ឲ្យឃើញ ។ បទថា **បសាទេតុំ** (ឲ្យជ្រះថ្លា) បានដល់ ធ្វើឲ្យកើតសេចក្តីជ្រះថ្លា ។ បទថា **អធិករណំ** (អធិករណ៍) បានដល់

អធិករណ៍ ៤ មានវិវាទាធិករណ៍ជាដើម ។ បទថា **អធិករណសមុទយំ** (ហេតុជាទីកើតឡើងនៃអធិករណ៍) បានដល់ ហេតុកើតនៃអធិករណ៍ មានមូលវិវាទជាដើម ។ បទថា **អធិករណនិរោធំ (ការរលត់នៃអធិករណ៍)** បានដល់ ការរម្ងាប់អធិករណ៍ ។ បទថា **អធិករណនិរោធគាមិនីបដិបទំ** (ផ្លូវបដិបត្តិជាគ្រឿងដល់ការរលត់អធិករណ៍) បានដល់ អធិករណសមថៈ ៧ យ៉ាង ។

ចប់អដ្ឋកថា ឧព្វាហសូត្រទី ៣

# អដ្ឋកថា ឧបសម្បទាសូត្រទី ៤

*ភិក្ខុប្រកបដោយធម៌ ១០ ប្រការ គប្បីឲ្យកុលបុត្តឧបសម្បទា*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបសម្បទាសូត្រទី ៤ ដូចតទៅនេះ ៖*

[៣៣] *បទថា **អនភិរតិំ** (ការមិនត្រេកអរ) បានដល់ ភាពជាអ្នកអផ្សុក ។ បទថា **វូបកាសេតុំ** (ដើម្បីរំងាប់ឯង) បានដល់ កម្ចាត់ ។ បទថា **អធិសីលេ** (ក្នុងអធិសីល) បានដល់ ក្នុងសីលដ៏ក្រៃលែង ។ សូម្បីក្នុងចិត្ត និងបញ្ញា ក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា ឧបសម្បទាសូត្រទី ៤

# អដ្ឋកថា និស្សយសូត្រទី ៥

## *ភិក្ខុប្រកបដោយធម៌ ១០ ប្រការ គប្បីឲ្យនិស្ស័យ*

[៣៤] *ក្នុងសូត្រនេះ មិនមានសេចក្តីកែរបស់ព្រះអដ្ឋកថាទេ ។*

ចប់អដ្ឋកថា និស្សយសូត្រទី ៥

# អដ្ឋកថា សាមណេរសូត្រទី ៦[១]

*ភិក្ខុប្រកបដោយធម៌ ១០ ប្រការ គប្បីឲ្យសាមណេរឧបដ្ឋាក*

[៣៤] *ក្នុងសូត្រនេះ មិនមានសេចក្តីកែរបស់ព្រះអដ្ឋកថាទេ ។*

ចប់អដ្ឋកថា និស្សយសូត្រទី ៥

---

(១) សូត្រនេះក៏រាប់បញ្ចូលក្នុងសូត្រទី ៥ ដែរ ទើបលេខឃ្នាបរាប់យកដូចគ្នា ។

# អដ្ឋកថា ឧបាលិសង្ឃភេទសូត្រទី ៧

## *វត្ថុ ១០ ប្រការ ធ្វើឲ្យភិក្ខុបែកគ្នា*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបាលិសង្ឃភេទសូត្រទី ៧ ដូចតទៅនេះ ៖*

[៣៤] *បទថា* ***វត្ថូហិ*** *ប្រែថា ហេតុទាំងឡាយ ។ បទថា* ***អវក-ស្សន្តិ*** *(លះបង់គ្នា) បានដល់ ឃ្លាតចេញ ប្រាសទៅ លះបង់ នូវបរិស័ទទុកមួយឡែក ។ បទថា* ***បវកស្សន្តិ*** *(បែកពីគ្នា) បានដល់ ទីបំផុតរមែងឃ្លាតចេញទៅ គឺ រមែងធ្វើដោយប្រការដែលនឹងបែកពីគ្នា ។ បទថា* ***អាវេ-និកកម្មានិ ករោន្តិ*** *ប្រែថា ធ្វើសង្ឃកម្មផ្សេងគ្នា ។*

ចប់អដ្ឋកថា ឧទាលិសង្ឃភេទសូត្រទី ៧

# អដ្ឋកថា ឧបាលិសាមគ្គីសូត្រទី ៨

## *វត្ថុ ១០ ប្រការ ដែលធ្វើឲ្យសង្ឃព្រមព្រៀងគ្នា*

[៣៦] *ក្នុងសូត្រនេះ មិនមានសេចក្តីកែរបស់ព្រះអដ្ឋកថាទេ ។*

ចប់អដ្ឋកថា ឧបាលិសាមគ្គីសូត្រទី ៨

# អដ្ឋកថា អានន្ទសង្ឃភេទសូត្រទី ៩

## អ្នកព្រមព្រៀងគ្នាបំបែកសង្ឃ រមែងសោយផលក្នុងនរកមួយកប្ប

*គប្បីជ្រាបវិនិច្ឆ័យក្នុង អានន្ទសង្ឃភេទសូត្រទី ៩ ដូចតទៅនេះ ៖*

*[៣៧-៣៨] បទថា **កប្បដ្ឋិយំ** (តាំងនៅអស់កប្ប) បានដល់ ហេតុនៃការតាំងនៅក្នុងនរករហូតអស់អាយុកប្ប ។ បទថា **កិព្វិសំ បសវតិ** (ទើងប្រសព្វផលដ៏ក្តៅ) សេចក្តីថា រមែងបានវិបាកនៃបាប ។ បទថា **អាបាយិកោ** (ជាអ្នកចូលដល់អបាយ) បានដល់ ទៅកាន់អបាយ ។ បទថា **នេរយិកោ** (ចូលដល់នរក) បានដល់ កើតក្នុងនរក ។ បទថា **វគ្គរតោ** (ត្រេកអរហើយក្នុងការបែកគ្នា) បានដល់ ពេញចិត្តក្នុងការបែកគ្នា ។ បទថា **យោគក្ខេមតោ ធំសតិ** (រមែងឃ្លាតចាកធម៌ជាដែនក្សេមចាកយោគៈ) បានដល់ ឃ្លាតចាកព្រះអរហត្ត ដែលជាដែនក្សេមចាកយោគៈ ។*

ចប់អដ្ឋកថា អានន្ទសង្ឃភេទសូត្រទី ៩

# អដ្ឋកថា អានន្ទសាមគ្គីសូត្រទី ១០

## បុគ្គលធ្វើសមានក្នុងសង្ឃដែលបែកគ្នា រមែងរីករាយ

## ក្នុងសួគ៌អស់នៃកប្ប

*គប្បីជ្រាបវិនិច្ឆ័យក្នុង អានន្ទសាមគ្គីសូត្រទី ១០ ដូចតទៅនេះ ៖*

*[៣៩-៤០] បទថា **អនុគ្គហោ** (សេចក្ដីអនុគ្រោះ) បានដល់ សេចក្ដីសង្គ្រោះ អនុគ្រោះដល់គ្នានិងគ្នា ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា អានន្ទសង្ឃសាមគ្គីសូត្រទី ១០

### ចប់ឧបាលិវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៧ សូត្រ

# អក្កោសវគ្គវណ្ណនាទី ៥

## អដ្ឋកថា វិវាទសូត្រទី ១

### *ហេតុបច្ច័យឲ្យសង្ឃវិវាទគ្នា*

[៤១] *ក្នុងសូត្រនេះ មិនមានអដ្ឋកថាកែទេ ។*

ចប់អដ្ឋកថា វិវាទសូត្រទី ១

# អដ្ឋកថា បឋមវិវាទមូលសូត្រទី ២

## *មូលហេតុនៃការវិវាទ ១០ ប្រការ*

[៤២] *ក្នុងសូត្រនេះ មិនមានអដ្ឋកថាកែទេ ។*

ចប់អដ្ឋកថា បឋមវិវាទមូលសូត្រទី ២

# អដ្ឋកថា ទុតិយវិវាទមូលសូត្រទី ៣

## *មូលហេតុនៃការវិវាទ ១០ ប្រការ*

[៤៣] *ក្នុងសូត្រនេះ មិនមានអដ្ឋកថាកែទេ ។*

ចប់អដ្ឋកថា ទុតិយវិវាទមូលសូត្រទី ៣

# អដ្ឋកថា កុសិនារាសូត្រទី ៤

## ភិក្ខុបំណងនឹងចោទអ្នកដទៃ គប្បីពិចារណា

## ធម៌ ៥ ប្រការក្នុងខ្លួន

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុសិនារាសូត្រទី ៤ ដូចតទៅនេះ ៖*

[៤៤] *បទថា* ***កុសិនារាយំ*** *(ជិតក្រុងកុសិនារា) បានដល់ នគរមានឈ្មោះយ៉ាងនេះ ជនទាំងឡាយរមែងនាំពលីទៅបួងសួង ដើម្បីប្រយោជន៍ដល់ទេវតាទាំងឡាយក្នុងទីនោះ ហេតុនោះ ទីនោះទើបឈ្មោះថា ពលិ-ហរណៈ (ជាទីនាំពលីទៅសែន) ។ ក្នុងទីនាំពលីទៅដូច្នោះ ។ ក្នុងបទថា* ***អច្ឆិទ្ទេន អប្បដិមំសេន (មិនដាច់ មិនខ្វះ)*** *ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ សេចក្តីប្រមាទ ឬអនេសនាកម្ម មានវេជ្ជកម្មជាដើម ដែលភិក្ខុរូបណាមួយធ្វើហើយ កាយសមាចាររបស់ភិក្ខុនោះ រមែងដូចជាស្លឹកត្នោតដែលពួកសត្វកណ្តៀរជាដើមកាត់ហើយ និងឈ្មោះថា ខ្វះខាត ព្រោះអាចនឹងចាប់កំហុសបាន គឺ ចាប់ត្រង់ទីណាមួយបាន ។ កាយសមាចារដែលផ្ទុយគ្នា ឈ្មោះថា មិនមានចន្លោះ មិនខ្វះខាត ។ ចំណែកវចីសមាចារ*

ឈ្មោះថា ជាចន្លោះ និងខ្វះខាត ព្រោះនិយាយកុហក និយាយចាក់ដោត និយាយស៊ិកសៀត ចោទដោយអាបត្តិដែលមិនមានមូលជាដើម ។ វចី-សមាចារផ្ទុយគ្នា ឈ្មោះថា មិនមានចន្លោះ មិនខ្វះខាត ។ បទថា **មេត្តំ នុ ខោ មេ ចិត្តំ (យើង... មេត្តាចិត្ត...ឬហ្ន៎)** បានដល់ មេត្តាចិត្តដែលភិក្ខុកាត់កន្លងបានមកដោយការប្រកបរឿយៗ នូវកម្មដ្ឋានការនា ។ បទថា **អនាឃាតំ (មិនអាឃាត)** បានដល់ វៀរអាឃាត អធិប្បាយថា កម្ចាត់អាឃាតដោយការគ្របសង្កត់ ។ បទថា **កត្ថ វុត្តំ (ត្រាស់ហើយក្នុងទីណា)** សេចក្តីថា សិក្ខាបទនេះ ទ្រង់ត្រាស់ទុកក្នុងនគរណា ។

ក្នុងបទថា **កាលេន វក្ខាមិ (នឹងពោលតាមកាលដែលគួរ)** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ភិក្ខុឲ្យភិក្ខុដទៃធ្វើឱកាសមួយហើយចោទ ឈ្មោះថា ពោលដោយកាល ។ ចោទកណ្តាលសង្ឃ កណ្តាលគណៈ ត្រង់រោងស្លាក រោងយាគូ រោងកត្ត រោងពិចារណា តាមផ្លូវភិក្ខាចារ និងសាលាឆាន់ ត្រង់សាលារក្សា (ទំនុកបម្រុង) ឬក្នុងខណៈដែលពួកឧបដ្ឋាកបវារណា ឈ្មោះថា ពោលមិនតាមកាល ។ ពោលដោយរឿងដែលពិត

ឈ្មោះថា ពោលដោយរឿងពិត ។ កាលពោលថា លោកឱដ៏ចម្រើន តាចាស់ លោកឱទម្លាយបរិស័ទ លោកឱអ្នកកាន់បង្សុកូល លោកឱអ្នកទេសក៍នេះសមគួរដល់លោកឱឬ ឈ្មោះថា ពោលដោយពាក្យគ្រោតគ្រាត ។ កាលពោលថា លោកដ៏ចម្រើន លោកដែលមានវ័យចាស់ លោកជាអ្នកអនុ-គ្រោះបរិស័ទ លោកជាអ្នកទ្រង់សំពត់បង្សុកូល លោកធម្មកថិក នេះសមគួរដល់លោកឬ ឈ្មោះថា ពោលដោយពាក្យពីរោះ ។ កាលពោលអាស្រ័យហេតុ ឈ្មោះថា ពោលដោយពាក្យអាងប្រយោជន៍ ។ បទថា **មេត្តចិត្តោ វក្ខាមិ នោ ទោសន្តរោ** (ពោលដោយមេត្តាចិត្ត ពោលដោយមិនសម្ងំទោស) សេចក្តីថា យើងនឹងតាំងមេត្តាចិត្តហើយពោល មិនមានចិត្តប្រទុស្តហើយពោល ។

ចប់អដ្ឋកថា កុសិនារាសូត្រទី ៤

# អដ្ឋកថា បវេសនសូត្រទី ៥

## ទោសការចូលទៅក្នុងព្រះរាជវាំង ១០ ប្រការ

គប្បីជ្រាបវិនិច្ឆ័យក្នុង បវេសនសូត្រទី ៥ ដូចតទៅនេះ ៖

[៤៥] បទថា កតំ វា ករិស្សន្តិ វា (ធ្វើហើយ ឬនឹងធ្វើ) បានដល់ ធ្វើការល្មើសក្នុងមេថុនហើយ ឬនឹងធ្វើការល្មើសក្នុងមេថុននោះ ។ បទថា រតនំ (រតនៈ) បានដល់ បណ្ដារតនៈ មានមណីរតនៈជាដើមណាមួយ ។ បទថា បត្ថេតិ (រមែងប្រាថ្នា) បានដល់ ប្រាថ្នានឹងឲ្យស្លាប់ ។ បទថា ហត្ថិសម្ពាធំ (ឃាត់ឃាំងដោយដំរី) បានដល់ ដែលបៀតបៀនដោយដំរី ។ បាឋៈថា ហត្ថិសមទ្ទំ ក៏មាន ។ ពាក្យនោះមានសេចក្ដីថា ឈ្មោះថា ហត្ថិសម្មទ្ទៈ ព្រោះជាទីដែលមានដំរីជាន់ ។ ក្នុងពាក្យដ៏សេសក៏ន័យនេះដូចគ្នា ។ បទថា រជនីយានិ រូបសទ្ទគន្ធរសផោដ្ឋព្វានិ សេចក្ដីថា អារម្មណ៍ទាំងឡាយ មានរូបជាដើម ដែលធ្វើឲ្យរាគៈកើតនោះ រមែងជារបស់ធ្លាញ់ក្នុងសេចក្ដីនោះ ។

ចប់អដ្ឋកថា បវេសនសូត្រទី ៥

# អដ្ឋកថា សក្កសូត្រទី ៦

## ព្រះមានព្រះភាគទ្រង់ដាស់តឿនឧបាសក

## អ្នកដែនសក្កៈឲ្យរក្សាឧបោសថជានិច្ច

គប្បីជ្រាបវិនិច្ឆ័យក្នុង សក្កសូត្រទី ៦ ដូចតទៅនេះ ៖

[៤៦] បទថា ***សោកសភយេ*** ប្រែថា មានភ័យព្រោះសេចក្តីសោក ។ បាឋៈថា ***សោកភយេ*** ដូច្នេះខ្លះ ។ មានអត្ថតែមួយដូចគ្នា ។ ក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ បទថា ***យេន កម្មដ្ឋានេន (ដោយការងារ)*** សេចក្តីថា បណ្តាការងារទាំងឡាយ មានការក្ខរកស់ ការធ្វើជំនួញជាដើម ការងារណាមួយ ។ បទថា ***អនាបជ្ជ អកុសលំ (មិនប៉ះពាល់អកុសល)*** សេចក្តីថា មិនចូលដល់អកុសលណាៗ ។ បទថា ***និព្វិសេយ្យ (គប្បី... ឲ្យកើតឡើង)*** បានដល់ គប្បីឲ្យកើតឡើង គឺ មិនគប្បីឲ្យវិនាសទៅ ។ បទថា ***ទក្ខោ*** ប្រែថា អ្នកឈ្លាស ។ បទថា ***ឧដ្ឋានសម្បន្នោ (បរិបូរដោយសេចក្តីព្យាយាម)*** បានដល់ ជាអ្នកប្រកបដោយសេចក្តីប្រឹងប្រែងព្យាយាម ។ បទថា ***អលំ វចនាយ*** ប្រែថា សមគួរនឹងពោល ។

បទថា ឯកន្តសុខបដិសំវេទី វិហរេយ្យ (នឹងគប្បីសោយដោយចំណែកមួយ) សេចក្ដីថា ទទួលការសោយសុខតាមផ្លូវកាយ និងផ្លូវចិត្ត តែម្យ៉ាងដោយញាណ ។

បទថា **អនិច្ចា (ជារបស់មិនទៀង)** បានដល់ មានហើយក៏មិនមាន ។ បទថា **តុច្ឆា (ជារបស់ទទេ)** បានដល់ វៀរចាកសេចក្ដីរឹងរាយ ។ បទថា **មុសា (ជារបស់កុហក)** បានដល់ កាម សូម្បីនឹងប្រាកដជាទៀង ស្អាត និងសុខ ក៏មិនដូច្នោះ ហេតុនោះ ទើបឈ្មោះថា មុសា ។ **មោសធម្មា (ជារបស់មានការវិនាសជាធម្មតា)** បានដល់ មានការវិនាសទៅជាសភាវៈ ។ ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា អាស្រ័យកាមទាំងនោះ ទើបកើតទុក្ខ ។ ពាក្យថា **វោ** ក្នុងបទថា **ឥធ ខោ បន វោ** នេះ ជានិបាត ។ បទថា **អបណ្ណកំ វា សោតាបន្នោ (ជាសោតាបន្នបដិបត្តិមិនខុសក៏មាន)** សេចក្ដីថា ឬថា ជាសោតាបន្នបដិបត្តិមិនខុសតែម្យ៉ាង ។ សូម្បីបុគ្គលនោះ ធ្វើឈានឲ្យកើតហើយ ក៏ទៅព្រហ្មលោក ឬសោយសុខតែម្យ៉ាងក្នុងកាមាវ-ចរសួគ៌ ៦ ជាន់ ។ ក្នុងព្រះសូត្រនេះ ព្រះសាស្ដាត្រាស់គុណរបស់ឧបោ-

សថ ប្រកបដោយអង្គ ៨ ។

ចប់អដ្ឋកថា សក្ខសូត្រទី ៦

# អដ្ឋកថា មហាលិសូត្រទី ៧

## ហេតុនៃការធ្វើបាបកម្ម និងកល្យាណកម្ម

គប្បីជ្រាបវិនិច្ឆ័យក្នុង មហាលិសូត្រទី ៧ ដូចតទៅនេះ ៖

[៤៧] បទថា **មិច្ឆាបណិហិតំ** ប្រែថា ដែលបុគ្គលតម្កល់ទុកខុស ។ បទថា **អធម្មចរិយាវិសមចរិយា** (ឈ្មោះថា ការប្រព្រឹត្តមិនស្មើ គឺ ការប្រព្រឹត្តអធម៌) សេចក្តីថា គប្បីជ្រាបវិសមចរិយា (ការប្រព្រឹត្តមិនរៀបរយ) ពោលគឺ អធម្មចរិយា (ការប្រព្រឹត្តអធម៌) បាន ក៏ដោយអំណាចអកុសលកម្មបថ ចរិយាក្រៅពីនេះក៏គប្បីជ្រាបដោយអំណាចកុសលកម្មបថ ។ ក្នុងព្រះសូត្រនេះ ត្រាស់ចំពោះវដ្តៈប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា មហាលិសូត្រទី ៧

# អដ្ឋកថា អភិណ្ហប្បច្ចវេក្ខណធម្មសូត្រទី ៨

## ធម៌ដែលបព្វជិតគប្បីពិចារណារឿយៗ ១០ ប្រការ

គប្បីជ្រាបវិនិច្ឆ័យក្នុង អភិណ្ហប្បច្ចវេក្ខណធម្មសូត្រទី ៦ ដូចតទៅនេះ ៖

[៤៨] បទថា **បព្វជិតេន** (ដែលបព្វជិត) បានដល់ អ្នកលះបង់យកវាស (ការគ្រប់គ្រងផ្ទះ) ចូលដល់ការបួសក្នុងព្រះសាសនា ។ បទថា **អភិណ្ហំ** (រឿយៗ) ប្រែថា រឿយៗ គឺ ញយៗ ។ បទថា **បច្ចវេក្ខិតព្វា** (គប្បីពិចារណា) ប្រែថា គប្បីពិចារណាមើល គឺ គប្បីកំណត់មើល ។

បទថា **វេវណ្ណិយំ** (ការមានភេទផ្សេង) សេចក្តីថា ការមានភេទផ្សេង គឺ មានរូបផ្សេងៗ ។ ក៏ការមានភេទផ្សេងនោះ មាន ២ យ៉ាង គឺ ការមានភេទផ្សេងដោយសរីរៈ ១ ការមានភេទផ្សេងដោយបរិក្ខារ ១ ។ បណ្តាការមានភេទផ្សេង ២ យ៉ាងនោះ ការមានភេទផ្សេងដោយសរីរៈ គប្បីជ្រាបបានដោយការកោរសក់ និងពុកមាត់ ។ ក៏មុនបួស សូម្បីស្លៀកសំពត់ ក៏ត្រូវប្រើសំពត់ល្អ សាច់ល្អិត ជ្រលក់ពណ៌ផ្សេងៗ សូម្បីបរិភោគ ក៏ត្រូវបរិភោគអាហារមានរសឆ្ងាញ់ផ្សេងៗ ដាក់ក្នុងភាជនៈមាស និងប្រាក់

សូម្បីដេក អង្គុយ ក៏ត្រូវដេកក្នុងទីដេក ទីអង្គុយយ៉ាងល្អ ក្នុងបន្ទប់ស្អាត សូម្បីប្រកបថ្នាំ ក៏ត្រូវប្រើទឹកដោះថ្លា ទឹកដោះខាប់ជាដើម តែតាំងពីបួស ហើយ ចាំបាច់ត្រូវស្លៀកដណ្តប់សំពត់កាត់ដាច់ សំពត់ប៉ះ សំពត់ជ្រលក់ទឹកចត់ ចាំបាច់ត្រូវធាន់តែបាយក្នុងបាត្រដែក ឬបាត្រដី ចាំបាច់ត្រូវដេកតែលើគ្រែក្រាលដោយស្មៅជាដើម ក្នុងសេនាសនៈ មានគល់ឈើជាអាទិ៍ ចាំបាច់ត្រូវអង្គុយលើកំណាត់ស្បែក និងកន្ទេលផែងជាដើម ចាំបាច់ត្រូវប្រកបថ្នាំដោយទឹកមូត្រស្អុយជាដើម ។ គប្បីជ្រាបការមានភេទផ្សេងដោយបរិក្ខារក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។ ក៏បព្វជិតពិចារណាយ៉ាងនេះ រមែងលះសេចក្តីទាស់ចិត្ត (កោធៈ) និងមានះ ការប្រកាន់ខ្លួនបាន ។

បទថា **បរបដិពទ្ធា មេ ជីវិកា (ការចិញ្ចឹមជីវិតរបស់យើង ជាប់ទាក់ទងនឹងអ្នកដទៃ)** សេចក្តីថា បព្វជិតពិចារណាយ៉ាងនេះថា ការរស់នៅដោយបច្ច័យ ៤ របស់យើង ទាក់ទងក្នុងអ្នកដទៃ គឺ ទាក់ទងជាមួយអ្នកដទៃ ដូច្នេះ ឥរិយាបថក៏សមគួរ អាជីវៈ (ការចិញ្ចឹមជីវិត) ក៏បរិសុទ្ធ ទាំងជាការគោរពកោតក្រែងក្នុងបិណ្ឌបាត្រ ឈ្មោះថា ជាអ្នកបរិភោគមិនពិចា-

រណាក្នុងបច្ច័យ ៤ ក៏មិនមែន ។

បទថា **អញ្ញោ មេ អាកប្បោ ករណីយោ** (អាកប្បកិរិយាដទៃដែលយើងគួរធ្វើ) សេចក្ដីថា បព្វជិតគប្បីពិចារណាថា អាកប្បកិរិយាដើរណា របស់ពួកគ្រហស្ថ គឺ ឈានដើរមិនកំណត់ ដោយអាការអើត.កយ៉ាងសង្ហា យើងគប្បីធ្វើអាកប្បកិរិយាផ្សេងពីអាកប្បកិរិយារបស់គ្រហស្ថនោះ យើងគប្បីមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ មើលមួយជួរនឹម ឈានដើរកំណត់ឲ្យល្មម (មិនឈានវែងពេក) គប្បីដើរទៅ ដូចរទេះផ្ទុកទឹកបរក្នុងទីរលាក់ ព្រោះថា បព្វជិតពិចារណាយ៉ាងនេះ រមែងមានអាកប្បកិរិយាសមគួរ សិក្ខា ៣ រមែងបរិបូរណ៍ ។

សព្ទថា **កច្ចិ នុ ខោ** រួមនិបាតចុះក្នុងសេចក្ដីកំណត់ ។ បទថា **អត្តា** (ខ្លួនឯង) បានដល់ ចិត្ត ។ បទថា **សីលតោ ន ឧបវទតិ** (រមែងតិះដៀល... ដោយសីលបានឬទេ) បានដល់ មិនតិះដៀលខ្លួនឯង ព្រោះសីលជាបច្ច័យយ៉ាងនេះថា សីលរបស់យើងមិនបរិបូរណ៍ ។ ព្រោះថា ហិរិ (ការខ្មាសបាប) រមែងតាំងឡើងខាងក្នុងបព្វជិតអ្នកពិចារណាយ៉ាងនេះ

ហិរិនោះ ក៏ឲ្យសម្រេចការសង្រួមក្នុងទ្វារទាំង ៣ ។ ការសង្រួមក្នុងទ្វារទាំង ៣ រមែងជាចតុប្បារិសុទ្ធិសីល ។ បព្វជិតអ្នកតាំងនៅក្នុងចតុប្បារិសុទ្ធិសីល ចម្រើនវិបស្សនាហើយ រមែងកាន់យកព្រះអរហត្តបាន ។

បទថា **អនុវិច្ច វិញ្ញូ សព្រហ្មចារី** (សព្រហ្មចារីទាំងឡាយ ដែលជាវិញ្ញូជនពិចារណាហើយ) សេចក្តីថា ពួកសព្រហ្មចារីដែលប្រព្រឹត្តព្រហ្មចរិយៈ បុគ្គលជាបណ្ឌិតពិចារណាហើយ ។ ព្រោះថា បព្វជិតពិចារណាហើយយ៉ាងនេះ ឱត្តប្បៈ (សេចក្តីខ្លាចបាប) ខាងក្រៅរមែងតាំងឡើង ។ ឱត្តប្បៈនោះ រមែងឲ្យសម្រេចការសង្រួមក្នុងទ្វារទាំង ៣ ដូច្នោះ ទើបគួរជ្រាបដោយន័យក្នុងលំដាប់បន្ទាប់មកនោះឯង ។

បទថា **នានាភាវោ វិនាភាវោ** (មានការព្រាត់ប្រាស) សេចក្តីថា សភាពផ្សេងៗ ព្រោះកើតមក សេចក្តីព្រាត់ប្រាសព្រោះមរណៈ ។ ព្រោះថា បព្វជិតពិចារណាហើយយ៉ាងនេះ ឈ្មោះថា មិនមានអាការ គឺ ប្រមាទក្នុងទ្វារទាំង ៣ ។ មរណស្សតិ (ការរលឹកដល់សេចក្តីស្លាប់) ក៏រមែងតាំងចុះដោយល្អ ។

ក្នុងបទថា **កម្មស្សកោម្ហិ** (ជាអ្នកមានកម្មជារបស់ខ្លួន) ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ កម្មជារបស់យើង គឺ ជាសម្បត្តិរបស់ខ្លួន ហេតុនោះ យើងទើបជាអ្នកមានកម្មជារបស់របស់ខ្លួន ។ ផលដែលកម្មគប្បីឲ្យ ឈ្មោះថា ទាយៈ ផលនៃកម្ម ឈ្មោះថា កម្មទាយៈ (ផលនៃកម្ម) យើងរមែងទទួលផលនៃកម្មនោះ ហេតុនោះ យើងទើបជាអ្នកទទួលផលនៃកម្ម ។ កម្មជាកំណើត គឺ ហេតុរបស់យើង ហេតុនោះ យើងទើបជាអ្នកមានកម្មជាកំណើត ។ កម្មជាផៅពង្ស ជាញាតិរបស់យើង ហេតុនោះ យើងទើបជាអ្នកមានកម្មជាផៅពង្ស ។ កម្មជាទីពឹងអាស្រ័យរបស់យើង ហេតុនោះ យើងទើបជាអ្នកមានកម្មជាទីពឹង គឺ ទីអាស្រ័យ ។ បទថា **តស្ស ទាយាទោ ភវិស្សាមិ** (យើងនឹងជាអ្នកទទួលផលរបស់កម្មនោះ) បានដល់ យើងនឹងជាទាយាទនៃកម្មនោះ គឺ ជាអ្នកទទួលផលដែលកម្មនោះឲ្យហើយ ។ ព្រោះថា បព្វជិតកាលពិចារណាដល់ភាពដែលខ្លួនមានកម្មជារបស់របស់ខ្លួនហើយយ៉ាងនេះ រមែងមិនឈ្មោះថាធ្វើបាប ។

បទថា **កថម្ភូតស្ស មេ រត្តិន្ទិវា វីតិបតន្តិ** (ថ្ងៃយប់កន្លងទៅៗ

ឥឡូវនេះយើងធ្វើអ្វី) សេចក្តីថា យប់ថ្ងៃកន្លងទៅ ប្រែប្រួលទៅ យើងជាអ្វី គឺ យើងកំពុងធ្វើវត្តបដិបត្តិហើយឬ ឬថាមិនទាន់ធ្វើ ទន្ទេញព្រះពុទ្ធវចនៈហើយឬ ឬថាមិនទន្ទេញ កំពុងធ្វើកិច្ចកម្មក្នុងយោនិសោមនសិការហើយឬ ឬថាមិនទាន់ធ្វើ ។ ព្រោះថា បព្វជិតពិចារណាយ៉ាងនេះ សេចក្តីមិនប្រមាទ រមែងបរិបូរណ៍ ។

បទថា *សុញ្ញាគារេ អភិរមាមិ* (រមែងត្រេកអរក្នុងផ្ទះស្ងាត់) សេចក្តីថា យើងតែម្នាក់នៅគ្រប់ឥរិយាបថ ក្នុងឱកាសដែលស្ងាត់ ញ៉ាំងសេចក្តីត្រេកអរហើយឬហ្ន៎ ។ ព្រោះថា បព្វជិតពិចារណាយ៉ាងនេះ កាយវិវេករមែងបរិបូរណ៍ ។

បទថា *ឧត្តរិមនុស្សធម្មា* (ឧត្តរិមនុស្សធម៌) សេចក្តីថា ធម៌ទាំងឡាយមានឈានជាដើម របស់លោកអ្នកបានឈាន និងរបស់ព្រះអរិយៈ ដែលជាមនុស្សដ៏ប្រសើរ ជាមនុស្សថ្នាក់ឧក្រិដ្ឋ ឬធម៌ទាំងឡាយក្រៃលែងជាងដែលប្រសើរជាងមនុស្សធម៌ ពោលគឺ កុសលកម្មបថ ១០ គឺ មាននៅក្នុងសន្តានយើងឬ ។ បទថា *អលមរិយញ្ញាណទស្សនវិសេសោ* (ញាណ-

ទស្សនៈវិសេសដែលអាចកម្ចាត់កិលេសជាអរិយៈ) សេចក្តីថា ឈ្មោះថា ញាណ ព្រោះអត្ថថា ឲ្យកើតមហគ្គតប្បញ្ញា និងលោកុត្តរប្បញ្ញា ឈ្មោះថា **ទស្សនៈ** ព្រោះអត្ថថា ឃើញធម៌ដោយធ្វើឲ្យប្រចក្សដូចឃើញដោយចក្ខុ ហេតុនោះ ទើបឈ្មោះថា **ញាណទស្សនៈ** ។ ញាណទស្សនៈដែលជាអរិយៈ គឺ បរិសុទ្ធខ្ពង់ខ្ពស់ ហេតុនោះ ទើបឈ្មោះថា **អរិយញ្ញាណទស្សនៈ** ។ អរិយញ្ញាទស្សនៈដែលអាច គឺ ជាអរិយៈអាចកម្ចាត់កិលេសមានហើយក្នុងធម៌នោះ ឬដល់ធម៌នោះ ហេតុនោះ ធម៌នោះ ទើបឈ្មោះថា **អលមរិយញ្ញាណទស្សនៈ** បានដល់ ធម៌របស់មនុស្សអ្នកក្រៃលែងមានឈានជាដើម ។ អលមរិយញ្ញាណទស្សនៈនោះផង វិសេសផង ហេតុនោះ ទើបឈ្មោះថា **អលមរិយញ្ញាណទស្សនវិសេស** ។ ន័យមួយទៀត គុណវិសេស គឺ ញាណទស្សនៈដែលបរិសុទ្ធ អាចកម្ចាត់កិលេសបាននោះឯង ហេតុនោះ ទើបឈ្មោះថា **អលមរិយញ្ញាណទស្សនវិសេស** ក៏បាន ។ បទថា **អធិគតោ (ដែលយើងបានសម្រេច)** បានដល់ សេចក្តីវិសេសដែលយើងតម្កល់ទុកហើយ មានហើយឬហ្ន៎ ។ បទថា **សោហំ (យើងនោះ)**

បានដល់ យើងមានគុណវិសេសបានតម្កល់ទុកហើយ ។ បទថា **បច្ឆិមេ កាលេ** (ក្នុងកាលខាងក្រោយ) បានដល់ ក្នុងវេលាដេកលើគ្រែសម្រាប់ស្លាប់ ។ បទថា **បុដ្ឋោ** (អ្នក... សួរហើយ) បានដល់ ត្រូវសព្រហ្មចារីសួរដល់គុណវិសេសដែលសម្រេច ។ បទថា **ន មង្កុ ភវិស្សាមិ** បានដល់ យើងនឹងមិនជាអ្នកសំយុង.ក អស់អំណាច ។ ព្រោះថា បព្វជិតពិចារណាយ៉ាងនេះ រមែងមិនឈ្មោះថា ស្លាប់ទទេ ។

ចប់អដ្ឋកថា អភិណ្ហប្បច្ចវេក្ខណធម្មសូត្រទី ៨

# អដ្ឋកថា សរីរដ្ឋធម្មសូត្រទី ៩

## ធម៌ដែលតាំងនៅក្នុងសរីរៈ ១០ ប្រការ

*គប្បីជ្រាបវិនិច្ឆ័យក្នុង សរីរដ្ឋធម្មសូត្រទី ៩ ដូចតទៅនេះ ៖*

[៤៩] *បទថា **បោនោព្ភវិកោ** (ដែលជាហេតុឲ្យកើតក្នុងភពថ្មី) បាន ដល់ ដែលជាហេតុឲ្យកើតក្នុងភពថ្មីទៀត ។ បទថា **ភវសង្ខារោ** (កម្មដែល ជាគ្រឿងតាក់តែងភព) បានដល់ កម្មជាគ្រឿងតាក់តែងភព ។ ក្នុងព្រះសូត្រ នេះ ត្រាស់ចំពោះវដ្តៈប៉ុណ្ណោះ ។*

ចប់អដ្ឋកថា សរីរដ្ឋធម្មសូត្រទី ៩

# អដ្ឋកថា កណ្ហសូត្រទី ១០

*ធម៌ ១០ ប្រការ ដែលជាហេតុមិនឲ្យវិវាទគ្នា*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កណ្ហសូត្រទី ១០ ដូចតទៅនេះ ៖*

[៥០] *ព្រះមានព្រះភាគត្រាស់ សីល ពហុសច្ចៈ វីរិយៈ សតិ និង បញ្ញា លាយគ្នាទាំងលោកិយៈ ទាំងលោកុត្តរៈ ។ បទដ៏សេសក្នុងទីគ្រប់កន្លែង មានសេចក្តីងាយហើយនោះឯង ។*

ចប់អដ្ឋកថា កណ្ហសូត្រទី ១០

## ចប់អក្កោសវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៧ សូត្រ

## ចប់បឋមបណ្ណាសកៈ

# ទុតិយបណ្ណាសកៈ

## សចិត្តវគ្គវណ្ណនាទី ១

### អដ្ឋកថា សចិត្តសូត្រទី ១

*ភិក្ខុគប្បីជាអ្នកឈ្លាសក្នុងវារៈចិត្តរបស់ខ្លួន*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សចិត្តសូត្រទី ១ ដូចតទៅនេះ ៖*

[៥១] *បទថា* ***សចិត្តបរិយាយកុសលា*** *ប្រែថា ជាអ្នកឈ្លាសក្នុងវារៈចិត្តរបស់ខ្លួន ។ បទថា* ***រជំ*** *(ធូលី) បានដល់ ឧបក្កិលេសដែលចរមក ។ បទថា* ***អង្គណំ*** *(ចំណុចខ្មៅ) បានដល់ មានចំណុចខ្មៅជាប់ខ្លួនជាដើម ដែលកើតត្រង់ស្រមោលមុខនោះ ។ បទថា* ***អាសវានំ ខយាយ*** *(ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ) បានដល់ ដើម្បីប្រយោជន៍ដល់ព្រះអរហត្ត ។*

ចប់អដ្ឋកថា ចិត្តសូត្រទី ១

# អដ្ឋកថា សារីបុត្តសូត្រទី ២

## ភិក្ខុគប្បីជាអ្នកឈ្លាសក្នុងវារៈចិត្តរបស់ខ្លួន

[៥២] *ក្នុងសារីបុត្តសូត្រទី ២ នេះ មិនមានអដ្ឋកថាទេ ។*

ចប់អដ្ឋកថា សារីបុត្តសូត្រទី ២

# អដ្ឋកថា ឋិតិសូត្រទី ៣

## ព្រះមានព្រះភាគទ្រង់សរសើរការតាំងនៅក្នុងកុសលធម៌

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឋិតិសូត្រទី ៣ ដូចតទៅនេះ ៖*

[៥៣] *បទថា បដិភាណេន (បដិភាណ) បានដល់ ដោយការតាំងពាក្យសំដីទុក ។*

ចប់អដ្ឋកថា ឋិតិសូត្រទី ៣

# អដ្ឋកថា សមថសូត្រទី ៤

## វត្ថុដែលគួរសេព និងមិនគួរសេព

គប្បីជ្រាបវិនិច្ឆ័យក្នុង សមថសូត្រទី ៤ ដូចតទៅនេះ ៖

[៥៤] បទថា អធិប្បញ្ញាធម្មវិបស្សនាយ (ការឃើញធម៌ដោយបញ្ញាដ៏ក្រៃលែង) បានដល់ វិបស្សនាដែលកំណត់សង្ខារជាអារម្មណ៍ ។

ចប់អដ្ឋកថា សមថសូត្រទី ៤

# អដ្ឋកថា បរិហានសូត្រទី ៥

*ភិក្ខុគប្បីជាអ្នកឈ្លាសក្នុងវារៈចិត្តរបស់ខ្លួន*

[៥៤] *ក្នុងសមថសូត្រនេះ មិនមានអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា បរិហានសូត្រទី ៥

# អដ្ឋកថា បឋមសញ្ញាសូត្រទី ៦

## *ការចម្រើនសញ្ញា ១០ ប្រការ មានផលច្រើន មានអានិសង្សច្រើន*

[៥៦] *ក្នុងសូត្រនេះ មិនមានអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា បឋមសញ្ញាសូត្រទី ៦

## អដ្ឋកថា ទុតិយសញ្ញាសូត្រទី ៧

*ការចម្រើនសញ្ញា ១០ ប្រការ មានផលច្រើន*

*មានអានិសង្សច្រើន ន័យម្យ៉ាងទៀត*

[៥៧] *ក្នុងសូត្រនេះ មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា ទុតិយសញ្ញាសូត្រទី ៧

# អដ្ឋកថា មូលសូត្រទី ៨

## ធម៌ទាំងពួង មានឆន្ទៈជាមូល មាននិព្វានជាទីបំផុត

គប្បីជ្រាបវិនិច្ឆ័យក្នុង មូលសូត្រទី ៨ ដូចតទៅនេះ ៖

[៥៨] ក្នុងបទថា *អមតោគធា (ឈានចុះកាន់អមតៈ)* នេះ ទ្រង់ត្រាស់ដល់ សឧបាទិសេសនិព្វានធាតុ ។ ក្នុងបទថា *និព្វានបរិយោសានា (មាននិព្វានជាទីបំផុត)* នេះ ទ្រង់ត្រាស់ដល់ អនុបាទិសេសនិព្វានធាតុ ។ ព្រោះថា ភិក្ខុសម្រេចអនុបាទិសេសនិព្វានហើយ រមែងឈ្មោះថា សម្រេចទីបំផុតនៃធម៌គ្រប់យ៉ាង ។ បទដ៏សេស មានសេចក្តីពោលទុកហើយក្នុងខាងក្រោយ ។

ចប់អដ្ឋកថា មូលសូត្រទី ៨

# អដ្ឋកថា បព្វជិតសូត្រទី ៩

## ចិត្តរបស់បព្វជិតដែលបានទទួលការអប់រំល្អហើយ រមែងបានទទួលផល ២ យ៉ាង

គប្បីជ្រាបវិនិច្ឆ័យក្នុង បព្វជិតសូត្រទី ៩ ដូចតទៅនេះ ៖

[៥៩] បទថា **តស្មា** (ព្រោះដូច្នោះ) បានដល់ ព្រោះហេតុប្រយោជន៍នៃសាមញ្ញផល (គុណរបស់សមណៈ) មិនដល់ព្រមដល់អ្នកដែលមានចិត្តមិនបានសន្សំយ៉ាងនេះ ដូច្នោះ ។ បទថា **យថាបព្វជ្ជាបរិចិត្តញ្ច នោ ចិត្តំ ភវិស្សតិ** (ចិត្តរបស់ពួកយើង ជាចិត្តបានអប់រំហើយតាមសមគួរដល់បព្វជា) សេចក្តីថា បានសន្សំមកតាមសមគួរដល់ការបួស ។ ពិតហើយ បុគ្គលពួកណាមួយ ឈ្មោះថា បួស បុគ្គលពួកនោះ ក៏ប្រាថ្នាព្រះអរហត្ត ព្រោះដូច្នោះ ចិត្តណាដែលគេសន្សំអប់រំ ដើម្បីប្រយោជន៍ដល់ការសម្រេចព្រះអរហត្ត ចិត្តនោះ គប្បីជ្រាបថា ឈ្មោះថា សន្សំមកតាមសមគួរដល់ការបួស ។

អ្នកគប្បីសិក្សាយ៉ាងនេះថា ចិត្តរបស់យើងនឹងជាដូច្នេះ ។ បទថា

*លោកស្ស សមញ្ច វិសមញ្ច* (ការប្រព្រឹត្តល្អ និងការប្រព្រឹត្តមិនល្អរបស់សត្វលោក) បានដល់ សុចរិត និងទុច្ចរិតរបស់សត្វលោក ។ បទថា *លោកស្ស សម្ភវញ្ច វិភវញ្ច* (សេចក្តីចម្រើន និងសេចក្តីវិនាសរបស់សត្វលោក) បានដល់ សេចក្តីចម្រើន និងសេចក្តីសាបសូន្យរបស់សត្វលោកនោះ ន័យមួយទៀត គឺ សម្បត្តិ និងវិបត្តិ ។ បទថា *លោកស្ស សមុទយញ្ច អត្ថង្គមញ្ច* (ការកើត និងការរលត់របស់សត្វលោក) ត្រាស់សំដៅយកសង្ខារលោក ។ អធិប្បាយថា ដឹងការកើត និងការបែកធ្លាយនៃខន្ធទាំងឡាយ ។

ចប់អដ្ឋកថា បណ្ឌិតសូត្រទី ៩

# អដ្ឋកថា អាពាធសូត្រទី ១០

## ទ្រង់សម្ដែងសញ្ញា ១០ ដល់គិរិមានន្ទភិក្ខុអាពាធ

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាពាធសូត្រទី ១០ ដូចតទៅនេះ ៖*

[៦០] *បទថា* ***អនុកម្បំ ឧបាទាយ*** *(ទ្រង់ប្រោសអនុគ្រោះ) បានដល់ ទ្រង់អាស្រ័យសេចក្ដីអាណិតដល់គិរិមានន្ទភិក្ខុ ។ គប្បីជ្រាបរោគទាំងឡាយ មានរោគភ្នែកជាដើម ដោយអំណាចវត្ថុ ។ ពិតហើយ ធម្មតាថា អ្នកកើត សេចក្ដីជ្រះថ្លាហើយ មិនមានរោគ ។ បទថា* ***កណ្ណរោគោ*** *(រោគស្លឹកត្រចៀក) បានដល់ រោគខាងក្រៅត្រចៀក ។ បទថា* ***បិនាសោ*** *(រោគឈឺច្រមុះ) បាន ដល់ រោគខាងក្រៅច្រមុះ ។ បទថា* ***ឧសា*** *(រោគព្រោះខ្យល់) បានដល់ រោគក្នុងទីប្រើក្រចកខ្វារ ។ បទថា* ***បិត្តសមុដ្ឋានា*** *(មានប្រមាត់ជា សមុ-ដ្ឋាន) បានដល់ អាពាធដែលកើតចាកពីប្រមាត់ ។ គេថា អាពាធទាំងនោះ មាន ៣២ យ៉ាង ។ សូម្បីក្នុងអាពាធដែលមានស្លេស្មជាសមុដ្ឋាន ក៏មាន ន័យនេះដូចគ្នា ។ បទថា* ***ឧតុបរិណាមជា*** *(ដែលកើតពីរដូវប្រែប្រួល) បានដល់ រោគដែលកើតពីក្ដៅខ្លាំងត្រជាក់ខ្លាំង ព្រោះរដូវប្រែប្រួល ។ បទ*

ថា **វិសមបរិហារជា** (ដែលកើតពីការរក្សាមិនស្មើ) បានដល់ អាពាធដែលកើតពីការរក្សាឥរិយាបថមិនស្មើ មានឈរ អង្គុយ យូរពេកជាដើម ។ បទថា **ឱបក្កមិកា** (ដែលកើតពីសេចក្តីព្យាយាម) បានដល់ អាពាធដែលកើតព្រោះសេចក្តីព្យាយាម មានការសម្លាប់ និងចាប់ចងពីអ្នកដទៃជាដើម ។ បទថា **កម្មវិបាកជា** (ដែលកើតពីវិបាករបស់កម្ម) បានដល់ អាពាធដែលកើតពីវិបាករបស់កម្មដែលមានកម្លាំង ។ បទថា **សន្តំ** (ស្ងប់) បានដល់ គុណជាតដែលឈ្មោះថា សន្តៈ ព្រោះកិលេស មានរាគៈជាដើមស្ងប់ ។ ឈ្មោះថា **បណីតៈ** ព្រោះអត្ថថា មិនក្តៅក្រហាយ ។ បទដ៏សេសក្នុងទីគ្រប់កន្លែង មានអត្ថងាយហើយ ។

ចប់អដ្ឋកថា អាពាធសូត្រទី ១០

## ចប់សចិត្តវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

# យមកវគ្គវណ្ណនាទី ២

## អដ្ឋកថា អវិជ្ជាសូត្រទី ១

### *ពោជ្ឈង្គ ៧ ជាអាហាររបស់វិជ្ជា និងវិមុត្តិ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អវិជ្ជាសូត្រទី ១ ដូចតទៅនេះ ៖*

[៦១] *បទថា* ***សាហារំ*** *(មានអាហារ) បានដល់ មានបច្ច័យ ។ បទថា* ***វិជ្ជាវិមុត្តឹ*** *(វិជ្ជា និងវិមុត្តិ) បានដល់ ផលញ្ញាណ និងសម្បយុត្តធម៌ដ៏សេស ។ បទថា* ***ពោជ្ឈង្គា*** *(ពោជ្ឈង្គ) បានដល់ អង្គនៃបញ្ញាជាគ្រឿងត្រាស់ដឹង គឺ មគ្គ ។*

ចប់អដ្ឋកថា អវិជ្ជាសូត្រទី ១

# អដ្ឋកថា តណ្ហាសូត្រទី ២

## *អវិជ្ជាជាអាហាររបស់ភវតណ្ហា*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តណ្ហាសូត្រទី ២ ដូចតទៅនេះ ៖*

[៦២] *បទថា* ***ភវតណ្ហាយ*** *(របស់ភវតណ្ហា) បានដល់ របស់សេចក្តីប្រាថ្នាភព ។ ក្នុងសូត្រទាំងពីរ ត្រាស់ចំពោះវដ្តៈតែម្យ៉ាង ។ តែវដ្តៈក្នុងសូត្រទាំងពីរនេះ សូត្រទី ១ ត្រាស់វដ្តៈមានអវិជ្ជាជាមូល ។ សូត្រទី ២ ត្រាស់វដ្តៈមានតណ្ហាជាមូល ។*

ចប់អដ្ឋកថា តណ្ហាសូត្រទី ២

# អដ្ឋកថា និដ្ឋាសូត្រទី ៣

## បុគ្គល ១០ ពួក ដែលជឿមាំក្នុងព្រះតថាគត

គប្បីជ្រាបវិនិច្ឆ័យក្នុង និដ្ឋាសូត្រទី ៣ ដូចតទៅនេះ ៖

[៦៣] បទថា **និដ្ឋង្គតា** (ជឿមាំ) បានដល់ អស់សេចក្ដីសង្ស័យ ។ បទថា **ឥធ និដ្ឋា** (ជឿមាំក្នុងលោកនេះ) បានដល់ បរិនិព្វានក្នុងលោកនេះប៉ុណ្ណោះ ។ បទថា **ឥធ វិហាយ និដ្ឋា** (លះលោកនេះហើយទើបជឿ) បានដល់ លះលោកនេះហើយទៅកាន់ព្រហ្មលោកជាន់សុទ្ធាវាស ។

ចប់អដ្ឋកថា និដ្ឋាសូត្រទី ៣

# អដ្ឋកថា អវេច្ចសូត្រទី ៤

## *បុគ្គល ១០ ពួក ជ្រះថ្លាយ៉ាងមាំក្នុងព្រះតថាគត*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អវេច្ចសូត្រទី ៤ ដូចតទៅនេះ ៖*

[៦៤] *បទថា* ***អវេច្ចប្បសន្នា*** *(ជ្រះថ្លាមិនកម្រើក) បានដល់ ដល់ព្រមហើយដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ។*

*បទថា* ***សោតាបន្នា*** *(សោតាបន្ន) បានដល់ អ្នកដល់ក្រសែនៃអរិយមគ្គ ។*

ចប់អដ្ឋកថា អវេច្ចសូត្រទី ៤

# អដ្ឋកថា បឋមសុខសូត្រទី ៥

## *ហេតុឲ្យកើតទុក្ខ និងសុខ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសុខសូត្រទី ៥ ដូចតទៅនេះ ៖*

[៦៥] *សាមណ្ឌកានិបរិព្វាជក សួរព្រះសារីបុត្រដល់សុខទុក្ខ ដែលមានវដ្តៈជាមូល ។*

ចប់អដ្ឋកថា បឋមសុខសូត្រទី ៥

# អដ្ឋកថា ទុតិយសុខសូត្រទី ៦

## *ហេតុឲ្យកើតទុក្ខ និងសុខ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសុខសូត្រទី ៦ ដូចតទៅនេះ ៖*

[៦៥] *សាមណ្ឌកានិបរិព្វាជក សួរព្រះសារីបុត្រដល់សុខទុក្ខ ដែលមានសាសនាជាមូល ។*

ចប់អដ្ឋកថា ទុតិយសុខសូត្រទី ៦

# អដ្ឋកថា នទ្យុកបានសូត្រទី ៧

## អ្នកមិនមានសទ្ធាក្នុងកុសលធម៌ គប្បីបានសេចក្តីវិនាសក្នុងកុសលធម៌

*គប្បីជ្រាបវិនិច្ឆ័យក្នុង នទ្យុកបានសូត្រទី ៧ ដូចតទៅនេះ ៖*

[៦៧] *បទថា* ***នទ្យុកបានំ (នទ្យុកបានៈ)*** *បានដល់ និគមមានដែលឈ្មោះយ៉ាងនេះ ព្រោះសាងទុកក្នុងស្ថានទីដែលព្រះពោធិសត្វឲ្យពានរតាំងនៅក្នុងឱវាទ ហើយផឹកទឹកដោយដើមបបុស ក្នុងអតីត ។ បទថា* ***តុណ្ហីភូតំ តុណ្ហីភូតំ (ជាអ្នកនៅស្ងៀម)*** *សេចក្តីថា ទ្រង់រមិលមើលទិសណាៗ ក៏ទ្រង់ឃើញភិក្ខុសង្ឃនៅស្ងៀមក្នុងទិសនោះៗ ។ បទថា* ***អនុវិលោកេត្វា (ទ្រង់គ្រួតមើល)*** *បានដល់ ទ្រង់ក្រឡេកមើលអំពីទិសនោះ ។ បទថា* ***បិដ្ឋិ មេ គិលាយតិ (តថាគតបែរខ្នង)*** *សេចក្តីថា ហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់បែរព្រះបិដ្ឋិ ។ ព្រោះថា ព្រះមានព្រះភាគ កាលទ្រង់តាំងមហាបធាន (សេចក្តីព្យាយាមធំអស់) ៦ ឆ្នាំ ក៏មានទុក្ខផ្លូវព្រះវរកាយច្រើនដល់មកខាងក្រោយ គ្រាទ្រង់ព្រះជរា ព្រះអង្គទើបកើតរោគព្រះវាតៈខាង*

ព្រះបិដ្ឋិ ។ ពិតណាស់ អាពាធតូចៗ ពីព្រះឥរិយាបថ មានការប្រថាប់អង្គុយយូរជាដើម គ្របសង្កត់ព្រះឧបាទិន្នរកាយមិនបាន តែទ្រង់អាងប្រការនោះត្រាស់យ៉ាងនេះ ក៏ដើម្បីធ្វើឱកាសដល់ព្រះថេរៈ ។ បទថា **សង្ឃាដី បញ្ញាបេត្វា** (ទ្រង់ក្រាលសំពត់សង្ឃាដិ) សេចក្តីថា ទ្រង់ក្រាលសង្ឃាដិលើគ្រែដែលជាកប្បិយៈ (សមគួរ) ដែលគេរៀបចំទុកក្នុងទីដ៏សមគួរម្ខាង ។

ចប់អដ្ឋកថា បឋមឆឡកចានសូត្រទី ៧

# អដ្ឋកថា ទុតិយនឡកបានសូត្រទី ៨

## *អ្នកមិនមានសទ្ធាក្នុងកុសលធម៌ មិនសង្ឃឹមបាន ក្នុងសេចក្ដីមិនវិនាសឡើយ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយនឡកបានសូត្រទី ៨ ដូចតទៅនេះ ៖*

[៦៨] *ក្នុងសូត្រនេះ មិនមានព្រះអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា ទុតិយនឡកបានសូត្រទី ៨

# អដ្ឋកថា បឋមវត្ថុកថាសូត្រទី ៩

## កថាវត្ថុ ១០ ប្រការ

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមវត្ថុកថាសូត្រទី ៩ ដូចតទៅនេះ ៖*

[៦៩] *បទថា **តិរច្ឆានកថំ (តិរច្ឆានកថា)** បានដល់ រឿងដែលជំទាស់ផ្លូវសួគ៌ និងនិព្វាន ព្រោះជារឿងដែលមិននាំសត្វចេញចាកទុក្ខ ។ បណ្តាតិរច្ឆានកថានោះ កថា គឺ រឿងដែលប្រារព្ធព្រះរាជា ហើយដំណើរទៅដោយន័យជាដើមថា ព្រះបាទមហាសម្មតិរាជ ព្រះបាទមន្ធាតុរាជ ព្រះបាទធម្មាសោករាជ ទ្រង់មានអានុភាពច្រើន យ៉ាងនេះឈ្មោះថា **រាជកថា** ។ ក្នុង **ចោរកថា** ជាដើមក៏ន័យនេះ ។ កថា គឺ រឿងដែលពោលជាប់ទាក់ទងនឹងផ្ទះសម្បែង ដោយន័យជាដើមថា រាជាព្រះអង្គឯណោះ ស្រស់ស្អាតគួរចូលចិត្ត ក៏ជាតិរច្ឆានកថា ។ ចំណែកកថាដែលប្រព្រឹត្តទៅយ៉ាងនេះថា ព្រះរាជាសូម្បីព្រះអង្គនោះ មានអានុភាពច្រើនយ៉ាងនោះ ក៏នូវដល់ការវិនាសទៅ ដូច្នេះ ក៏តាំងនៅក្នុងកម្មដ្ឋាន ។ សូម្បីក្នុងពួកចោរ កថាដែលអាស្រ័យកម្មរបស់ចោរទាំងនោះប្រព្រឹត្តទៅ ដោយន័យថា មូលទេវចោរ*

មានអំណាចច្រើនយ៉ាងនេះ មេឃមាលចោរ មានអំណាចច្រើនយ៉ាងនេះ កថាដែលជាប់ទាក់ទងនឹងផ្ទះសម្បែងថា ឱហ្ន៎! ពួកគេជាអ្នកក្លាហាន ដូច្នោះក៏ជា **តិរច្ឆានកថា** ។ សូម្បីក្នុងរឿងចម្បាំងទាំងឡាយ មានការតយុទ្ធជាដើម កថាដែលប្រព្រឹត្តទៅដោយអំណាចសេចក្តីត្រេកអរក្នុងកម្ម ថា បុគ្គលឯណោះ ត្រូវបុគ្គលឯណោះ ធ្វើឲ្យស្លាប់យ៉ាងនេះ បាញ់យ៉ាងនេះ ឈ្មោះថា តិរច្ឆានកថា ។ ចំណែកកថាដែលប្រព្រឹត្តទៅយ៉ាងនេះថា សូម្បីអ្នកទាំងនោះ ក៏ដល់នូវការអស់ទៅ រមែងជាកម្មដ្ឋានក្នុងគ្រប់ៗ កថា ។ មួយទៀត ក្នុងរឿងអាហារ មានបាយជាដើម នឹងពោលដោយអំណាចសេចក្តីត្រេកអរក្នុងវត្ថុគួរប្រាថ្នាថា យើងទំពារស៊ី ផឹក បរិភោគ អាហារមានពណ៌ល្អ មានរសឆ្ងាញ់យ៉ាងនេះ មិនគួរ ។ តែនឹងពោលឲ្យមានប្រយោជន៍ថា ពីមុន យើងបានថ្វាយបាយ ទឹក សំពត់ ទីដេក កម្រងផ្កា របស់ក្រអូបដែលសម្បូរណ៍ដោយពណ៌ជាដើម ដល់អ្នកមានសីល បានធ្វើការបូជាព្រះចេតិយយ៉ាងនេះ ក៏គួរ ។

សូម្បីក្នុង **រឿងញាតិ** ទាំងឡាយ នឹងពោលដោយអំណាចសេចក្តី

ត្រេកអរថា ពួកញាតិរបស់យើងជាអ្នកខ្លាំងក្លាអង់អាច ឬថា ពីមុន ពួកយើងនាំគ្នាត្រាច់ទៅដោយយានដែលវិចិត្រយ៉ាងនេះ មិនគួរ ។ តែគប្បីពោលឲ្យជាប្រយោជន៍យ៉ាងនេះថា ពួកញាតិរបស់យើងនោះ ក៏ដល់នូវការអស់ទៅ ឬថា ពីមុន ពួកយើងបានថ្វាយស្បែកជើងយ៉ាងនេះដល់សង្ឃ ។ សូម្បីកថារឿងស្រុក ដែលប្រព្រឹត្តទៅដោយអំណាចស្រុកជាទីតាំងនៅជាសុខ ទីតាំងនៅមិនជាសុខ រកកិក្ខាបានងាយ រកកិក្ខាបានលំបាកជាដើម ឬដោយអំណាចសេចក្ដីត្រេកអរយ៉ាងនេះថា អ្នកស្រុកឯណោះ ជាអ្នកក្លាហាន មិនគួរ ។ តែនឹងពោលឲ្យមានប្រយោជន៍ថា ពួកគេមានសទ្ធាជ្រះថ្លា ឬថាគេដល់ការអស់ទៅ វិនាសទៅ ដូច្នេះក៏គួរ ។ សូម្បីក្នុង **កថារឿងនិគម នគរ ជនបទ** ក៏ន័យនេះដូចគ្នា ។

សូម្បីកថា **រឿងស្ត្រី** ដែលប្រព្រឹត្តទៅអាស្រ័យវណ្ណៈ និងទ្រង់ទ្រាយជាដើម ដោយអំណាចសេចក្ដីត្រេកអរ មិនគួរ ។ តែនឹងពោលយ៉ាងនេះថា ស្ត្រីម្នាក់នោះ មានសទ្ធាជ្រះថ្លា ក៏ដល់ការអស់ទៅ ដូច្នេះ ក៏គួរ ។ សូម្បីកថា **រឿងអ្នកក្លាហាន** ដែលប្រព្រឹត្តទៅដោយអំណាចសេចក្ដីត្រេកអរ

យ៉ាងនេះថា អ្នកចម្បាំងឈ្មោះនន្ទមិត្ត ជាអ្នកក្លាហាន ដូច្នេះ មិនគួរ ។ តែប្រព្រឹត្តទៅយ៉ាងនេះថា គេជាមនុស្សមានសទ្ធា ដល់ការអស់ទៅហើយ ទើបគួរ ។ ក៏ការពោល **រឿងសុរា** ក្នុងបាលីមានច្រើនយ៉ាង ពោលរឿងរបស់ស្រវឹងដោយអំណាចសេចក្ដីត្រេកអរ មិនគួរ ។ ពោលដោយទោសប៉ុណ្ណោះ ទើបគួរ ។ សូម្បីកថា **រឿងផ្លូវ** ដែលប្រព្រឹត្តទៅដោយអំណាចសេចក្ដីត្រេកអរថា ថ្នល់ឯណោះតាំងនៅល្អ តាំងនៅមិនល្អ មិនគួរ , តែពោលថា អ្នកធ្វើថ្នល់ឯណោះមានសទ្ធា គួរជ្រះថ្លា ក៏ដល់នូវការអស់ទៅ ដូច្នេះ ទើបគួរ ។ កថាដែលកើតឡើងប្រចាំត្រង់កំពង់ទឹក កថារឿងកំពង់ទឹក ឬកថារឿងទាសីកណ្ដៀតខ្អមទឹក លោកហៅឈ្មោះថា **កុម្ភដ្ឋានកថា** ។ សូម្បីកុម្ភដ្ឋានកថានោះ ដែលប្រព្រឹត្តទៅដោយអំណាចសេចក្ដីត្រេកអរថា ស្រ្ដីកណ្ដៀតខ្អមទឹក គួរជ្រះថ្លា ឆ្លាតក្នុងការរាំ ច្រៀង ដូច្នេះ មិនគួរ ។ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា នាងមានសទ្ធា ជ្រះថ្លា ដូច្នេះ គួរ ។

កថារឿងញាតិដែលស្លាប់ទៅហើយ ឈ្មោះថា **បុព្វេបេតកថា** ។ ក្នុងបុព្វេបេតកថានោះ គប្បីជ្រាបវិនិច្ឆ័យ ដូចគ្នានឹងកថារឿងញាតិបច្ចុប្បន្ន

(នៅមានជីវិត) ។ តិរច្ឆានកថាដែលមានសភាពផ្សេងៗ ដ៏សេស ក្រៅពីកថាដើម និងកថាក្រោយ ឈ្មោះថា **នានត្តកថា** ។ កថាសន្ទនាគ្នាដោយលោកាយតសាស្ត្រ វិតណ្ឌសាស្ត្រ ជាដើមយ៉ាងនេះថា លោកនេះនរណាសាង ទេវតាឯណោះជាអ្នកសាង ក្អែកសព្រោះមានឆ្អឹងស សត្វត្រដក់ក្រហមព្រោះមានឈាមក្រហម ឈ្មោះថា **លោកក្ខាយិកា** ។ កថាពោលដល់សមុទ្រ ដែលពោលដល់រឿងដែលគ្មានប្រយោជន៍ជាដើម យ៉ាងនេះថា ព្រោះហេតុអ្វី សមុទ្រទើបឈ្មោះថា សាគរ ព្រោះព្រះបាទសាគរទ្រង់ជីក សាគរឈ្មោះថា សមុទ្រ ព្រោះព្រះបាទសាគរទ្រង់ប្រកាសដោយ ព្រះរាជសាសន៍ថា សាគរយើងជាអ្នកជីក ឈ្មោះថា **សមុទ្ទក្ខាយិកា** ។ បទថា **ភវោ** ប្រែថា សេចក្តីចម្រើន ។ បទថា **អភវោ** ប្រែថា សេចក្តីសាបសូន្យ ។ បទថា **ឥតិភវោ ឥតិអភវោ** (សេចក្តីចម្រើនដោយប្រការនោះ សេចក្តីវិនាសដោយប្រការនោះ) សេចក្តីថា កថាដែលពោលដល់ហេតុដែលគ្មានប្រយោជន៍ មិនថាជាអ្វី ឲ្យប្រព្រឹត្តទៅ ឈ្មោះថា **ឥតិភវាភវកថា** ។

បទថា **តេជសា តេជំ** (តេជៈ... ដោយតេជៈ) បានដល់ យកតេជៈ

គ្របសង្កត់តេជៈរបស់ព្រះច័ន្ទ និងព្រះអាទិត្យនោះឯង ។ បទថា **បរិយា-ទិយ្យយាថ** (គប្បីគ្របសង្កត់) បានដល់ ធ្វើតេជៈរបស់ព្រះច័ន្ទ ព្រះអាទិត្យឲ្យអស់ទៅ ។ ក្នុងសេចក្តីនេះ មានរឿងសាធកៈដូច្នេះ ។ ភិក្ខុអ្នកសមាទានបិណ្ឌបាតជាវត្តមួយរូប សួរព្រះមហាថេរៈថា លោកម្ចាស់ដ៏ចម្រើន ភិក្ខុទាំងឡាយកាលនឹងយកតេជៈគ្របសង្កត់ តើតេជៈដូចម្តេច ។ ព្រះថេរៈពោលថា អ្នកមានអាយុ ភិក្ខុទាំងឡាយឈរកណ្តាលថ្ងៃមួយកន្លែង ធ្វើដោយអាការត្រង់ស្រមោលថ្ងៃមិនចុះខាងក្រោម មិនឡើងខាងលើ ។

ចប់អដ្ឋកថា បឋមវគ្គកថាសូត្រទី ៩

# អដ្ឋកថា ទុតិយវត្ថុកថាសូត្រទី ១០

## *ឋានៈដែលគួរសរសើរ ១០ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយវត្ថុកថាសូត្រទី ១០ ដូចតទៅនេះ ៖*

[៧០] *បទថា* ***បាសំសានិ ឋានានិ*** *(ឋានៈដែលគួរសរសើរ) បាន ដល់ ហេតុដែលនាំសេចក្ដីសរសើរមកឲ្យ ។ បទដ៏សេសគ្រប់កន្លែងមាន សេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា ទុតិយវត្ថុកថាសូត្រទី ១០

**ចប់យមកវគ្គវណ្ណនាទី ២**

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# អាកង្ខវគ្គវណ្ណនាទី ៣

## អដ្ឋកថា អាកង្ខសូត្រទី ១

### *ភិក្ខុសម្រេចសេចក្ដីប្រាថ្នា ព្រោះជាអ្នកសម្បូរ ដោយសីលជាដើម*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាកង្ខសូត្រទី ១ ដូចតទៅនេះ ៖*

[៧១] *បទថា **សម្បន្នសីលា** (ជាអ្នកសម្បូរដោយសីល) បានដល់ អ្នកមានសីលបរិបូរណ៍ អធិប្បាយថា ជាអ្នកដល់ព្រមដោយសីល ។ ក្នុងបទថា **ជាអ្នកសម្បូរដោយសីល** នេះ ភាពជាអ្នកមានសីលសម្បូរណ៍ រមែងមានដោយហេតុ ២ ប្រការ គឺ ដោយការឃើញទោសនៃសីលវិបត្តិ និងដោយការឃើញគុណនៃសីលសម្បត្តិ ហេតុសូម្បីទាំងពីរនោះ ក៏ពោលទុកពិស្ដារហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ក្នុងបទទាំងនោះ បទថា **ជាអ្នកសម្បូរដោយសីល** មានអធិប្បាយថា ព្រះសុមតត្ថេរៈ អ្នកនៅវត្តទីបវិហារពោលថា បានឮថា ព្រះមានព្រះភាគទ្រង់លើកចតុប្បារិសុទ្ធិសីលឡើង ដោយពាក្យមានប្រមាណប៉ុណ្ណេះ ទ្រង់សម្ដែងសីលដែលសំខាន់ឲ្យពិស្ដារក្នុងទីនោះ*

ដោយបទនេះថា **បាតិមោក្ខសំវរសំវុតា (ជាអ្នកសង្រួមដោយការសង្រួមក្នុងបាតិមោក្ខ)** ។ ចំណែកព្រះចូឡនាគត្ថេរៈ អ្នកទ្រទ្រង់ព្រះត្រៃបិដកជាអន្តេវាសិករបស់លោកពោលថា សូម្បីក្នុងបទទាំងពីរ ព្រះមានព្រះភាគក៏ត្រាស់បាតិមោក្ខសំវរៈ ព្រោះថា បាតិមោក្ខសំវរៈនុ៎ះឯង ជាសីល ចំណែក ៣ ទៀត ក្រៅពីនេះ ក៏ជាសីល ។ លោកទើបពោលដោយមិនដឹងថា "ឈ្មោះឋានៈដែលពោលហើយ មានហើយ" ហើយពោលថា ត្រឹមតែរក្សាទ្វារ ៦ ប៉ុណ្ណោះ ក៏ឈ្មោះថា ឥន្ទ្រិយសំវរសីល ត្រឹមតែធ្វើបច្ច័យឲ្យកើតឡើងដោយធម៌ក៏ដោយ ក៏ឈ្មោះថា អាជីវបារិសុទ្ធិសីល ត្រឹមតែពិចារណាក្នុងបច្ច័យដែលបានហើយថា នេះមានហើយ ទើបបរិភោគ ក៏ឈ្មោះថា បច្ចយសន្និស្សិតសីល ដោយត្រង់ បាតិសំវរៈប៉ុណ្ណោះ ឈ្មោះថា សីល បាតិមោក្ខសំវរៈរបស់ភិក្ខុណាដាច់ហើយ ភិក្ខុនេះមិនគប្បីពោលថា នឹងរក្សាសីលដ៏សេសបាន ដូចបុរសមានសីសៈដាច់ហើយ នឹងរក្សាដៃជើងទុកមិនបាន ។ ចំណែកបាតិមោក្ខសំវរៈរបស់ភិក្ខុណាមិនដាច់ ភិក្ខុនេះអាចញុំាងសីលដ៏សេសឲ្យជាប្រក្រតីបាន ដូចបុរសមានសីសៈមិនដាច់ ក៏រក្សាជីវិតទុក

បាន ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់លើកបាតិមោក្ខសំវរៈដោយបទថា ជាអ្នកបរិបូរដោយសីល នេះ ហើយត្រាស់ពាក្យវេវចនៈរបស់បទថា ជាអ្នកបរិបូរដោយសីល នោះឯងថា ជាអ្នកបរិបូរដោយបាតិមោក្ខ កាលទ្រង់សម្ដែងបទថា ជាអ្នកសម្បូរដោយបាតិមោក្ខ នោះឲ្យពិស្ដារ ទើបត្រាស់ថា ជាអ្នកសង្រួម ដោយការសង្រួមក្នុងបាតិមោក្ខ ជាដើម ។ បទថា បាតិមោក្ខសំវរសំវុតា (ជាអ្នកសង្រួម ដោយការសង្រួមក្នុងបាតិមោក្ខ) ជាដើម ក្នុងបទនោះ មានសេចក្ដីដូចពោលទុកហើយនោះឯង ។

សួរថា ហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ផ្ដើមថា បើភិក្ខុគប្បីប្រាថ្នាដូច្នេះ ។ ឆ្លើយថា ដើម្បីទ្រង់សម្ដែងអានិសង្សនៃសីល ។ ពិតហើយ បើភិក្ខុពួកបួសថ្មី ឬអ្នកមានបញ្ញាទន់ខ្សោយ នឹងគប្បីគិតយ៉ាងនេះថា ព្រះមានព្រះភាគទ្រង់ប្រៀនប្រដៅថា ពួកអ្នកចូរបំពេញសីល ចូរបំពេញសីល អ្វីជាអានិសង្ស អ្វីជាគុណវិសេស អ្វីជាសេចក្ដីចម្រើន ក្នុងការបំពេញសីល ។ ត្រាស់យ៉ាងនេះ ក៏ដើម្បីទ្រង់សម្ដែងអានិសង្ស ១០ ប្រការ ដល់ភិក្ខុទាំងនោះថា ប្រសិនបើភិក្ខុទាំងនោះ សូមប្បីស្ដាប់អានិសង្ស ដែលមាន

សេចក្តីស្រឡាញ់ពេញចិត្តរបស់ពួកសព្រហ្មចារីជាខាងដើម មានការអស់អាសវៈជាខាងចុងហើយ នឹងគប្បីធ្វើឲ្យសីលបរិបូរណ៍ ។ បណ្តាបទទាំងនោះ បទថា **អាកង្ខេយ្យ ចេ (បើ... ប្រាថ្នា)** បានដល់ នឹងគប្បីប្រាថ្នា ។ បទថា **បិយោ ចស្សំ (យើងគប្បីជាទីស្រឡាញ់)** បានដល់ យើងគប្បីជាអ្នកដែលសព្រហ្មចារីសម្លឹងមើលដោយភ្នែកគួរស្រឡាញ់ គប្បីមានការទំនុកបម្រុងឲ្យកើតសេចក្តីស្រឡាញ់ ។ បទថា **មនាបោ (ជាទីពេញចិត្ត)** បានដល់ ជាទីចម្រើនចិត្តនៃសព្រហ្មចារីទាំងនោះ ឬចិត្តរបស់សព្រហ្មចារីទាំងនោះ ព្រួកដល់ អធិប្បាយថា ដែលសព្រហ្មចារីផ្សាយដល់ដោយមេត្តាចិត្ត ។ បទថា **គរុ (ជាទីគោរព)** បានដល់ ជាទីតាំងនៃភាពធ្ងន់ (គោរព) នៃសព្រហ្មចារី ដូចឆត្រថ្ម ។ បទថា **ភាវនីយោ (ជាទីគួរសរសើរ)** បានដល់ ដែលសព្រហ្មចារីសរសើរយ៉ាងនេះថា លោករមែងដឹងប្រការដែលគួរដឹង ឃើញប្រការដែលគួរឃើញមកយូរហើយ ។ បទថា **សីលេស្វេវស្ស (គប្បីជាអ្នកធ្វើឲ្យបរិបូរក្នុងសីលទាំងឡាយ)** បានដល់ គប្បីជាអ្នកធ្វើឲ្យបរិបូរក្នុងចតុប្បារិសុទ្ធិសីល លោកអធិប្បាយថា គប្បីជាអ្នកប្រកបដោយ

ការធ្វើមិនឲ្យខ្វះខាត គឺ បរិបូរណ៍ ។

បទថា *អជ្ឈត្តំ ចេតោសមថមនុយុត្តោ (ប្រកបដោយសេចក្តីស្ងប់ចិត្តខាងក្នុង)* បានដល់ ប្រកបក្នុងសេចក្តីស្ងប់ចិត្តរបស់ខ្លួន ។ បទថា *អនិរាកតជ្ឈានោ (មិនឃ្លាតចាកឈាន)* បានដល់ មានឈានដែលមិនត្រូវនាំចេញខាងក្រៅ ឬមានឈានដែលមិនវិនាស ។ បទថា *វិបស្សនាយ (ដោយវិបស្សនា)* បានដល់ ដោយអនុបស្សនា ៧ យ៉ាង ។ បទថា *ព្រូហេតា សុញ្ញាគារានំ (ចម្រើនការនៅក្នុងផ្ទះស្ងាត់ចុះ)* បានដល់ ចម្រើនសុញ្ញាគារ ។ ក៏ក្នុងបទថា *ព្រូហេតា សុញ្ញាគារានំ (ចម្រើនការនៅក្នុងផ្ទះស្ងាត់)* នេះ ភិក្ខុទទួលកម្មដ្ឋាន ជាសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ចូលទៅកាន់សុញ្ញាគារ អង្គុយអស់ថ្ងៃ និងយប់ គប្បីជ្រាបថា ជាអ្នកចម្រើនសុញ្ញាគារ ។ នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ។ ចំណែកសេចក្តីពិស្តារអ្នកមានបំណង គប្បីមើលបានក្នុងវណ្ណនាអាកង្ខេយ្យសូត្រ អដ្ឋកថាមជ្ឈិមនិកាយចុះ ។

ក្នុងបទថា *លាភី (ជាអ្នកបាន)* គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ។ ព្រះ-

មានព្រះភាគ ទ្រង់មិនបានត្រាស់សេចក្តីបរិបូរក្នុងគុណ មានសីលជាដើម ជានិមិត្តនៃលាភ ។ ពិតណាស់ ព្រះមានព្រះភាគ ទ្រង់រមែងទូន្មានសាវក ទាំងឡាយយ៉ាងនេះថា មុនីហាក់ដូចជាកាត់ពាក្យដែលស្វែងរកអាហារចេញ ហើយ មិនគប្បីពោលបយុត្តវាចាស្វែងរកអាហារ ។ ភិក្ខុនោះ នឹងពោល រឿងសេចក្តីបរិបូរក្នុងគុណ មានសីលជាដើម ជានិមិត្តនៃលាភបានយ៉ាង ណា ។ ក៏ពាក្យនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ដោយអំណាចអធ្យាស្រ័យ របស់បុគ្គល ។ ពិតហើយ ភិក្ខុពួកណា មានអធ្យាស្រ័យយ៉ាងនេះ ព្រះ មានព្រះភាគទើបត្រាស់ដោយអំណាចអធ្យាស្រ័យប៉ុណ្ណោះ របស់ភិក្ខុទាំង នោះថា បើយើងមិនគប្បីលំបាកដោយបច្ច័យ ៤ សោត យើងក៏នឹងគប្បី នាំសីលទាំងឡាយឲ្យបរិបូរបាន ។ មួយទៀត ឈ្មោះថា បច្ច័យ ៤ ជា អានិសង្សព្រមដោយកិច្ច គឺ (នាទីរបស់សីល) ពិតដូច្នោះ បុគ្គលជា បណ្ឌិត នាំទ្រព្យដែលរក្សាទុកក្នុងឃ្លាំងជាដើមចេញមក មិនមែនបរិភោគ សូម្បីដោយខ្លួនឯង រមែងថ្វាយពួកលោកអ្នកមានសីល ព្រះមានព្រះភាគ ត្រាស់ពាក្យនេះ ក៏ដើម្បីទ្រង់សម្តែងអានិសង្សព្រមទាំងកិច្ច គឺ (មុខនាទី)

របស់សីល ។

ក្នុងវារៈទី ៣ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ។ ពាក្យថា **យេសាហំ** កាត់ជាបទថា **យេសំ អហំ** ។ បទថា **តេសន្តេ ការា (ការសក្ការៈរបស់ជនទាំងនោះ)** សេចក្ដីថា ការសក្ការៈ គឺ បច្ច័យទានទាំងនោះ ដែលពួកទេវតា ឬមនុស្សធ្វើក្នុងយើងទាំងនោះ ចូរមានផលច្រើន មានអានិសង្សច្រើន ហេតុនោះ សក្ការៈទាំងនោះ ឈ្មោះថា មានផលច្រើន ក៏ដោយផលដែលជាលោកិយសុខ ឈ្មោះថា មានអានិសង្សច្រើន ក៏ដោយផលដែលជាលោកុត្តរសុខ ។ ន័យមួយទៀត ពាក្យទាំងពីរនេះ ក៏មានអត្ថតែម្យ៉ាងដូចគ្នានុ៎ះឯង ។ **ភិក្ខាមួយវែកក្ដី បណ្ណសាលាដែលគេសាងលើទីដីត្រឹមតែ ៥ ហត្ថក្ដី** ដែលគេថ្វាយដល់ភិក្ខុដែលប្រកបដោយគុណ មានសីលជាដើម រមែងរារាំងចាកទុគ្គតិវិនិបាត បានច្រើនពាន់កប្ប និងជាបច្ច័យដល់អមតធាតុ គឺ ព្រះនិព្វានក្នុងទីបំផុតផង ។ ក៏មានបទថា **ឧភោទនំ អហមទាសឹ (យើងបានថ្វាយទឹកដោះ និងបាយ)** ជាដើម ជារឿងតួយ៉ាងក្នុងពាក្យនេះ ។ ម្យ៉ាងទៀត ទាំងបេតវត្ថុ (រឿងប្រេត) ទាំងវិមានវត្ថុ (រឿង

វិមាន) ជាគ្រឿងសាធកៈបានទាំងអស់ ។

ក្នុងវារៈទី ៤ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ។ បទថា **បេតា** (អ្នកស្លាប់ទៅហើយ) បានដល់ អ្នកទៅកាន់កពមច្ចុរាជ ។ បទថា **ញាតិ** (ញាតិ) បានដល់ ចំណែកខាងឪពុកម្តាយក្មេក ។ បទថា **សាលោហិតា** (សាលោ-ហិត) បានដល់ ជាប់ដោយខ្សែលោហិតតែមួយ មានជីតាជាដើម ។ បទថា **កាលកតា** (ធ្វើកាលហើយ) បានដល់ ស្លាប់ហើយ ។ បទថា **តេសន្តំ** (ការរឭកដល់របស់ញាតិសាលោហិតទាំងនោះ) បានដល់ ចិត្តដែលជ្រះថ្លាក្នុងយើងនោះ ឬការរលឹកដល់ព្រមទាំងចិត្តដែលជ្រះថ្លានោះ របស់ញាតិសាលោហិតទាំងនោះ ។ ពិតហើយ មាតា ឬបិតារបស់ភិក្ខុណា ធ្វើកាលៈមានចិត្តជ្រះថ្លាថា ព្រះថេរៈជាញាតិរបស់ពួកយើង ជាអ្នកមានសីល មានកល្យាណធម៌ រលឹកដល់ភិក្ខុនោះ សេចក្តីជ្រះថ្លានៃចិត្តនោះក្តី ត្រឹមតែការរលឹកដល់នោះក្តី របស់បុគ្គលនោះ រមែងមានផលច្រើន មានអានិសង្សច្រើន ។

បទថា **អរតិរតិសហោ** (ជាអ្នកគ្របសង្កត់សេចក្តីមិនត្រេកអរ និង

ត្រេកអរ) បានដល់ ជាអ្នកអត់ធន់ គ្របសង្កត់ ញាំញី សេចក្ដីមិនត្រេកអរក្នុងនេក្ខម្មប្បដិបត្តិ និងសេចក្ដីត្រេកអរក្នុងកាមគុណទាំងឡាយ ។ ក្នុងបទថា ភយភេរវសហោ (ជាអ្នកគ្របសង្កត់សេចក្ដីភ័យខ្លាច និងសេចក្ដីតក់ស្លុត) នេះ ចិត្តដែលភ័យខ្លាចក្ដី អារម្មណ៍ក្ដី ឈ្មោះថា ការភ័យខ្លាច ។ អារម្មណ៍តែម្យ៉ាង ឈ្មោះ សេចក្ដីតក់ស្លុត ។

ចប់អដ្ឋកថា អាកង្ខសូត្រទី ១

# អដ្ឋកថា កណ្ដកសូត្រទី ២

## ធម៌ដែលជាបន្លា ១០ ប្រការ

គប្បីជ្រាបវិនិច្ឆ័យក្នុង កណ្តកសូត្រទី ២ ដូចតទៅនេះ ៖

[៧២] បទថា *អភិញ្ញាតេហិ អភិញ្ញាតេហិ* (មានកេរ្តិ៍ឈ្មោះ) បានដល់ ដែលនរណាៗ ក៏ស្គាល់ គឺ ប្រាកដហើយដូចព្រះច័ន្ទពេញវង់ ដូចព្រះអាទិត្យកណ្ដាលផ្ទៃអាកាស ។ ក្នុងបទថា *បរម្បរាយ* នេះ ចំណែកខាងក្រោយហៅថា *បរ* ។ ចំណែកខាងមុខហៅថា *បុរ* ។ អធិប្បាយថា បរិវារចំនួនច្រើនអ្នកដែលដើរទៅខាងមុខ និងដែលជាប់តាមទៅអំពីខាងក្រោយ ។ បទថា *កណ្តកា* (បន្លា) ឈ្មោះថា បន្លា ព្រោះអត្ថថា មុត ។ បទថា *វិសូកទស្សនំ* (ការមើលមហោស្រពដែលជាសត្រូវ) បានដល់ មើលការលេងដែលជាបដិលោម ដែលជាសត្រូវ ។ បទថា *មាតុគាមូបចារោ* (ការជាប់តាមមាតុគ្រាម) បានដល់ ជាអ្នកត្រាច់ទៅជិតមាតុគ្រាម ។

ចប់អដ្ឋកថា កណ្ហកសូត្រទី ២

# អដ្ឋកថា ឥដ្ឋសូត្រទី ៣

## ធម៌ ១០ ប្រការ ដែលគួរប្រាថ្នា និងរកបានលំបាកក្នុងលោក

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឥដ្ឋសូត្រទី ៣ ដូចតទៅនេះ ៖*

*[៧៣] បទថា វណ្ណោ (វណ្ណៈ) បានដល់ វណ្ណៈនៃសរីរៈ ។ បទថា ធម្មា (ធម៌) បានដល់ លោកុត្តរធម៌ ៩ ។*

ចប់អដ្ឋកថា ឥដ្ឋសូត្រទី ៣

# អដ្ឋកថា វឌ្ឍិសូត្រទី ៤

## សេចក្តីចម្រើន ១០ ប្រការ

គប្បីជ្រាបវិនិច្ឆ័យក្នុង វឌ្ឍិសូត្រទី ៤ ដូចតទៅនេះ ៖

[៧៤] បទថា *អរិយា (ដ៏ប្រសើរ)* បានដល់ មិនមែនជារបស់បុថុជ្ជន ។ បទនេះត្រាស់ទុក ក៏ព្រោះលាយដោយធម៌ទាំងឡាយ មានសីលជាដើម ។ បទថា *សារាទាយី ច ហោតិ វរាទាយី (ជាអ្នកកាន់យកវត្ថុដែលជាសារៈ និងជាអ្នកកាន់យកវត្ថុដែលប្រសើរនៃកាយ)* សេចក្តីថា រមែងជាអ្នកចាប់ទុកនូវសារៈ និងចំណែកដ៏ប្រសើរ ។ អធិប្បាយថា រមែងកាន់យកនូវសារៈនៃកាយ និងចំណែកដ៏ប្រសើរនៃកាយនោះ ។

ចប់អដ្ឋកថា វឌ្ឍិសូត្រទី ៤

# អដ្ឋកថា មិគសាលាសូត្រទី ៥

## មិនគប្បីកាន់យកប្រមាណក្នុងបុគ្គលថា វិនាស និងចម្រើន តែគប្បីកាន់យកប្រមាណក្នុងធម៌

*គប្បីជ្រាបវិនិច្ឆ័យក្នុង មិគសាលាសូត្រទី ៥ ដូចតទៅនេះ ៖*

[៧៥] *ពាក្យណានឹងគប្បីពោលមុនក្នុងខាងដើមនៃសូត្រទី ៥ ពាក្យនោះ ក៏ពោលទុកហើយក្នុងឆក្កនិបាត ។ ក៏ក្នុងបទថា* **ទុស្សីលោ ហោតិ** *(ជាអ្នកទ្រុស្តសីល) ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ។*

*បទថា* **ទុស្សីលោ** *(ជាអ្នកទ្រុស្តសីល) បានដល់ ជាអ្នកមិនមានសីល ។ បទថា* **ចេតោវិមុត្តឹ** *ចេតោវិមុត្តិ) បានដល់ ផលសមាធិ ។ បទថា* **បញ្ញាវិមុត្តឹ** *(បញ្ញាវិមុត្តិ) បានដល់ ផលញ្ញាណ ។ បទថា* **នបជានាតិ** *(មិនដឹងច្បាស់) បានដល់ មិនដឹងដោយការរៀន និងការសាកសួរ ។ ក្នុងបទថា* **ទុស្សីល្យំ អបរិសេសំ និរុជ្ឈតិ** *(រលត់មិនមានសេសសល់នៃភាពជាអ្នកទ្រុស្តសីល) នេះ ការទ្រុស្តសីល ៥ យ៉ាង សោតាបត្តិមគ្គលះបានមុន ការទ្រុស្តសីល ១០ យ៉ាង អរហត្តមគ្គលះបានក្នុងខណៈផល-*

ចិត្ត (គឺអរហត្តផល) ការទ្រុស្តសីលទាំងនោះ ដែលឈ្មោះថា មគ្គលះបានហើយ ។ ទ្រង់សំដៅដល់ខណៈនៃផលចិត្ត ក្នុងសូត្រនេះ ទើបត្រាស់ថា **និរុជ្ឈតិ** (រលត់) ។ ក៏សីលរបស់បុថុជ្ជន រមែងដាច់ដោយហេតុ ៥ ប្រការ គឺ ត្រូវអាបត្តិបារាជិក ១ លាសិក្ខា ១ ចូលលទ្ធិតិរ្ថិយ ១ សម្រេចព្រះអរហត្ត ១ ស្លាប់ ១ ។ ក្នុងហេតុ ៥ ប្រការនោះ ហេតុ ៣ ប្រការខាងដើម ប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស , ប្រការទី ៤ ប្រព្រឹត្តទៅដើម្បីសេចក្តីចម្រើន , ប្រការទី ៥ មិនប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសនិងសេចក្តីចម្រើន ។ សួរថា ក៏សីលនេះដាច់ ព្រោះសម្រេចព្រះអរហត្តដូចម្តេច ។ ឆ្លើយថា ព្រោះថា សីលរបស់បុថុជ្ជនជាកុសលកម្មតែម្យ៉ាងប៉ុណ្ណោះ ចំណែកព្រះអរហត្តមគ្គ ប្រព្រឹត្តទៅដើម្បីអស់កុសលកម្ម និងអកុសលកម្ម សីលដាច់ ព្រោះសម្រេចព្រះអរហត្តយ៉ាងនេះ ។

បទថា **សវនេនបិ អកតំ ហោតិ** (មិនធ្វើកិច្ចសូម្បីដោយការស្តាប់) សេចក្តីថា ប្រការដែលគួរស្តាប់ ក៏មិនបានស្តាប់ ។ ក្នុងបទថា **ពាហុស-ច្ចេនបិ អកតំ ហោតិ** (មិនធ្វើកិច្ចសូម្បីដោយភាពជាពហូសូត) នេះ សេចក្តី

ថា ប្រការដែលគួរធ្វើដោយសេចក្ដីព្យាយាម ក៏មិនបានធ្វើ ។ ព្រោះមិនបានធ្វើសេចក្ដីព្យាយាមនោះ ទើបវិនាសចាកសួគ៌ខ្លះ ចាកមគ្គខ្លះ ។ បទថា **ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ** (មិនចាក់ធ្លុះសូម្បីដោយទិដ្ឋិ) សេចក្ដីថា ប្រការដែលគប្បីចាក់ធ្លុះដោយទិដ្ឋិ ក៏មិនបានធ្វើឲ្យប្រចក្ស ។ បទថា **សមាយិកម្បិ វិមុត្តឹ ន លភតិ** (រមែងមិនបាននូវវិមុត្តិ សូម្បីក្នុងសម័យ) សេចក្ដីថា អាស្រ័យមិនបានស្ដាប់ធម៌តាមកាលដ៏សមគួរ រមែងមិនបានបីតិនិងបាមោជ្ជៈ ។ បទថា **ហានាយ បរេតិ** (រមែងទៅកាន់ផ្លូវវិនាស) សេចក្ដីថា រមែងដល់សេចក្ដីសាបសូន្យ ។ បទថា **យថាភូតំ បជានាតិ** (ដឹងច្បាស់... តាមសេចក្ដីពិត) សេចក្ដីថា សម្រេចសោតាបត្តិផលហើយ រមែងដឹងដោយការរៀន និងសាកសួរថា ការទ្រុស្ដសីល ៥ យ៉ាង រមែងរលត់មិនមានសល់ ។

បទថា **តស្ស សវនេនបិ កតំ ហោតិ** (បុគ្គលនោះ ធ្វើកិច្ចសូម្បីដោយការស្ដាប់) សេចក្ដីថា ប្រការដែលគួរស្ដាប់ ក៏បានស្ដាប់ ។ បទថា **ពាហុសច្ចេនបិ កតំ ហោតិ** (ធ្វើកិច្ចសូម្បីដោយភាពជាពហូសូត) សេចក្ដី

ថា កិច្ចដែលគួរធ្វើដោយសេចក្ដីព្យាយាម ដោយហោច សូម្បីត្រឹមតែវិបស្សនាដែលមិនមានកម្លាំង ក៏បានធ្វើ ។ បទថា **ទិដ្ឋិយាបិ សុប្បដិវិទ្ធំ ហោតិ** (ចាក់ធ្លុះដោយល្អសូម្បីដោយទិដ្ឋិ) សេចក្ដីថា ការត្រាស់ដឹងបច្ច័យដោយហោច សូម្បីដោយលោកិយបញ្ញា ក៏បានធ្វើ ។ ពិតហើយ បញ្ញារបស់បុគ្គលនេះ រមែងជម្រះសីល គេរមែងសម្រេចគុណវិសេស ដោយសីល ដែលបញ្ញាជម្រះហើយ ។ បទថា **បមាណិកា** (ជាអ្នកដឹងប្រមាណ) បានដល់ ជាអ្នកដឹងប្រមាណក្នុងបុគ្គលទាំងឡាយ ។ បទថា **បមិនន្តិ** (រមែងប្រមាណ) បានដល់ គួរកាប់ គួរថ្លឹង ។ បទថា **ឯកោ ហីនោ** (បុគ្គលម្នាក់ទើបអាក្រក់) បានដល់ វិនាសចាកគុណទាំងឡាយតែម្នាក់ឯង ។ បទថា **បណីតោ** (ល្អ) បានដល់ ប្រសើរដោយគុណទាំងឡាយតែម្នាក់ឯង ។ បទថា **តំ ហិ** (ក៏ការប្រមាណនោះ) បានដល់ ធ្វើការប្រមាណនោះ ។ បទថា **អភិក្កន្តតរោ** (ល្អជាង) ប្រែថា ខ្ពង់ខ្ពស់ជាង ។ បទថា **បណីតតរោ** (ប្រណីតជាង) ប្រែថា ខ្ពង់ខ្ពស់ជាង ។

បទថា **ធម្មសោតោ និព្វហតិ** (រមែងពាល់ត្រូវក្រសែនៃធម៌) សេចក្ដី

ថា វិបស្សនាញាណដែលប្រព្រឹត្តទៅមានកម្លាំង រមែងនាំ គឺ ឲ្យសម្រេចអរិយភូមិ ។ បទថា **តទនន្តរំ កោ ជានេយ្យ** (នរណាហ្ន៎ គប្បីដឹងហេតុនោះបាន) សេចក្តីថា នរណានឹងគប្បីដឹងហេតុនោះៗ ។ បទថា **សីលវា ហោតិ** (ជាអ្នកមានសីល) បានដល់ រមែងមានសីល ដោយលោកិយ-សីល ។ បទថា **យត្ថស្ស តំ សីលំ** (ជាការដែល... នៃសីលរបស់គេ) សេចក្តីថា ដល់វិមុត្តិក្នុងព្រះអរហត្តហើយ សីល ក៏ឈ្មោះថា រលត់មិនមានសល់ ។ ប្រការយុត្តិក្នុងសីលនោះ ក៏ពោលទុកហើយនោះឯង ។ ក្នុងអង្គទាំងពីរក្រៅពីនេះ អនាគាមិផល ឈ្មោះថា វិមុត្តិ ។

ក្នុងសូត្រទី ៥ នេះ ត្រាស់ដល់ព្រះអរហត្តតែម្យ៉ាង ។ ពាក្យដ៏សេសក្នុងសូត្រទី ៥ នោះ ក៏គប្បីជ្រាបតាមន័យដែលពោលហើយចុះ ។

ចប់អដ្ឋកថា មិគសាលាសូត្រទី ៥

# អដ្ឋកថា អភព្វសូត្រទី ៦

*ធម៌ ៣ ប្រការ មានក្នុងលោក*

*ព្រះសម្មាសម្ពុទ្ធ ទើបត្រាស់ដឹងក្នុងលោក*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អភព្វសូត្រទី ៦ ដូចតទៅនេះ ៖*

[៧៦] *ក្នុងអភព្វសូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អភព្វសូត្រទី ៦

# អដ្ឋកថា កាកសូត្រទី ៧

## អសទ្ធម្ម ១០ ប្រការ

*គប្បីជ្រាបវិនិច្ឆ័យក្នុង កាកសូត្រទី ៧ ដូចតទៅនេះ ៖*

*[៧៧] បទថា **ធំសី** (កម្ចាត់បង់) បានដល់ ជាសត្វកម្ចាត់នូវគុណ មិនអើពើដល់គុណរបស់បុគ្គលណាៗ សូម្បីគេយកដៃចាប់ ក៏រើស្មុះចេញ បន្ទោបង់ឧច្ចារៈស្រោចលើសីសៈ ។ បទថា **បគព្ភោ** (ក្រអឺតក្រឧង) បានដល់ ប្រកបដោយសេចក្តីឃ្នើសឃ្នង គ្មានអៀនខ្មាស ។ តណ្ហា លោកហៅថា តិន្តិណៈ ក្នុងបទថា **តិន្តិណោ** ប្រកបដោយតណ្ហានោះ ឬច្រើនដោយសេចក្តីរង្កៀស ។ បទថា **លុទ្ទោ** ប្រែថា អាក្រក់ ។ បទថា **អការុណិកោ** (មិនមានករុណា) ប្រែថា គ្មានករុណា ។ បទថា **ទុព្វលោ** (គ្មានកម្លាំង) បានដល់ មិនមានកម្លាំង មានកម្លាំងតិច ។ បទថា **ឱរវិតា** (មានសំឡេងគ្រាវ) បានដល់ ហើរទៅហើយស្រែក ។ បទថា **នេចយិកោ** (សន្សំ) បានដល់ ធ្វើការសន្សំ ។*

ចប់អដ្ឋកថា កាកសូត្រទី ៧

# អដ្ឋកថា និគន្ថសូត្រទី ៨

## *អសទ្ធម្ម ១០ ប្រការ របស់ពួកនិគ្រន្ថ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និគន្ថសូត្រទី ៨ ដូចតទៅនេះ ៖*

[*៧៨*] *ព្រះសូត្រនេះ មិនមានព្រះអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា និគន្ថសូត្រទី ៨

# អដ្ឋកថា អាឃាតវត្ថុសូត្រទី ៩

## អាឃាតវត្ថុ ១០ ប្រការ

គប្បីជ្រាបវិនិច្ឆ័យក្នុង អាឃាតវត្ថុសូត្រទី ៩ ដូចតទៅនេះ ៖

[៧៩] បទថា *អដ្ឋានេ (ក្នុងទីមិនគួរ)* បានដល់ ក្នុងទីមិនមែនហេតុ ។ ពិតហើយ ហេតុជាដើមថា គេបានប្រព្រឹត្តវត្ថុដែលមិនជាប្រយោជន៍ដល់យើង ដូច្នេះ នឹងគប្បីបានក្នុងការប្រព្រឹត្តទៅរបស់វត្ថុ ដែលមានចិត្តឬថា ក្នុងវត្ថុដែលមិនមានចិត្តជាដើម ថា ដង្គត់ឈើ ផ្លាំងថ្ម រមែងមិនមាន ព្រោះដូច្នោះ អាឃាតក្នុងសេចក្ដីនេះ ទើបឈ្មោះថា អាឃាតក្នុងទីមិនមែនហេតុ ។ ពាក្យដ៏សេសគ្រប់កន្លែង មានសេចក្ដីងាយហើយ ។

ចប់អដ្ឋកថា អាឃាតវត្ថុសូត្រទី ៩

# អដ្ឋកថា អាឃាតប្បដិវិនយសូត្រទី ១០

## *ឧបាយជាគ្រឿងកម្ចាត់អាឃាតវត្ថុ ១០ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាឃាតប្បដិវិនយសូត្រទី ១០ ដូចតទៅនេះ ៖*

*[៨០] ក្នុងសូត្រនេះ មិនមានព្រះអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា អាឃាតប្បដិវិនយសូត្រទី ១០

## ចប់អាកង្ខវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៧ សូត្រ

# ថេរវគ្គវណ្ណនាទី ៤

## អដ្ឋកថា វាហុនសូត្រទី ១

*ព្រះតថាគតចេញចាកធម៌ ១០ ប្រការ*

*ឈ្មោះថា មានព្រះហឫទ័យប្រាសចាកដែនកិលេស*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វាហុនសូត្រទី ១ ដូចតទៅនេះ ៖*

[៨១] *បទថា* ***វិមរិយាទិកតេន*** *(ប្រាសចាកដែនកិលេស)* បានដល់ទម្លាយព្រំដែនកិលេស ហើយធ្វើមិនឲ្យមាន ។

ចប់អដ្ឋកថា វាហុនសូត្រទី ១

# អដ្ឋកថា អានន្ទសូត្រទី ២

*ភិក្ខុប្រកបដោយធម៌ ១០ ប្រការ*

*និងចម្រើនលូតលាស់ក្នុងធម្មវិន័យនេះ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អានន្ទសូត្រទី ២ ដូចតទៅនេះ ៖*

[៨២] *អានន្ទសូត្រទី ២ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អានន្ទសូត្រទី ២

# អដ្ឋកថា បុណ្ណិយសូត្រទី ៣

*ហេតុបច្ច័យ ១០ ប្រការ ព្រះធម្មទេសនា*

*ទើបប្រាកដដល់ព្រះតថាគត*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បុណ្ណិយសូត្រទី ៣ ដូចតទៅនេះ ៖*

[៨៣] *បទថា នោ ច បយិរុបាសិតា (មិនចូលទៅអង្គុយជិត) បានដល់ មិនទំនុកបម្រុង ។*

ចប់អដ្ឋកថា បុណ្ណិយសូត្រទី ៣

# អដ្ឋកថា ព្យាករណសូត្រទី ៤

## *កិក្ខុលៈធម៌ ១០ ប្រការ*

## *ទើបចូលដល់ចម្រើនល្អតលាស់ក្នុងធម្មវិន័យនេះ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ព្យាករណសូត្រទី ៤ ដូចតទៅនេះ ៖*

[៨៤] *បទថា* ***ឈាយី សមាបត្តិកុសលោ*** *(អ្នកបានឈាន ឈ្លាសក្នុងសមាបត្តិ) បានដល់ បុគ្គលដល់ព្រមដោយឈានទាំងឡាយ និងជាអ្នកឈ្លាសក្នុងសមាបត្តិ ។ បទថា* ***តរិណំ*** *(ភាពជាបុគ្គលទទេ) បានដល់ គ្មានប្រយោជន៍ ។ បទថា* ***វិចិនំ*** *(មិនមានគុណ) បានដល់ ការបែកអំពីគុណ មិនមានអ្វីជាគុណ ។ ន័យមួយទៀត ប្រៀបដូចជាចូលដល់ព្រៃធំ ហៅថា តរិណៈ និងព្រៃធំ ហៅថា វិចិណៈ ។ បទថា* ***អនយំ*** *ប្រែថា សេចក្តីមិនចម្រើន ។ បទថា* ***ព្យសនំ*** *ប្រែថា សេចក្តីវិនាស ។ បទថា* ***អនព្យសនំ*** *ប្រែថា សេចក្តីមិនចម្រើន និងសេចក្តីវិនាស ។ បទថា* ***កឹ នុ ខោ*** *ប្រែថា ព្រោះហេតុអ្វី ។*

ចប់អដ្ឋកថា ព្យាករណសូត្រទី ៤

# អដ្ឋកថា កត្ថីសូត្រទី ៥

## *ភិក្ខុលះធម៌ ១០ ប្រការ*

## *ទើបចូលដល់ចម្រើនលូតលាស់ក្នុងធម្មវិន័យនេះ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កត្ថីសូត្រទី ៥ ដូចតទៅនេះ ៖*

[៨៥] *បទថា កត្ថី ហោតិ វិកត្ថី (ជាអ្នកមានប្រក្រតីពោលអួត) បានដល់ ជាអ្នកមានប្រក្រតីនិយាយ មានប្រក្រតីនិយាយអួតអាង ចេះតែនិយាយឲ្យតែបាន ។ បទថា ន សតតការី (មិនប្រឹងប្រែងធ្វើសេចក្តីព្យាយាម) បានដល់ មិនធ្វើឲ្យជាប់តគ្នា ។*

ចប់អដ្ឋកថា កត្ថីសូត្រទី ៥

# អដ្ឋកថា អញ្ញសូត្រទី ៦

## ភិក្ខុលះធម៌ ១០ ប្រការ

## ទើបចូលដល់ចម្រើនល្អតលាស់ក្នុងធម្មវិន័យនេះ

គប្បីជ្រាបវិនិច្ឆ័យក្នុង អញ្ញសូត្រទី ៦ ដូចតទៅនេះ ៖

[៨៦] បទថា **អធិមានិកោ** (មានការសំគាល់ខុស) បានដល់ប្រកបដោយការសម្គាល់ថា សម្រេចហើយក្នុងធម៌ដែលមិនទាន់សម្រេច ។ បទថា **អធិមានសច្ចោ** (សម្គាល់ខុសក្នុងសច្ចៈ) បានដល់ សម្គាល់ថាសម្រេចហើយ ទើបពោលដោយសច្ចៈ ។

ចប់អដ្ឋកថា អញ្ញសូត្រទី ៦

# អដ្ឋកថា អធិករណសូត្រទី ៧

## ភិក្ខុប្រកបដោយធម៌ ១០ ប្រការ

## មិនប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលម្នាក់ឯង

*គប្បីជ្រាបវិនិច្ឆ័យក្នុង អធិករណសូត្រទី ៧ ដូចតទៅនេះ ៖*

[៨៧] *បទថា **អធិករណិកោ ហោតិ** (ជាអ្នកធ្វើអធិករណ៍) បានដល់ ជាអ្នកធ្វើអធិករណ៍ ។ បទថា **ន បិយតាយ** (មិន...ជាទីស្រឡាញ់) បានដល់ មិនប្រព្រឹត្តទៅដើម្បីជាទីស្រឡាញ់ ។ បទថា **ន គរុតាយ** (មិន... ជាទីគោរព) បានដល់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីគួរគោរព ។ បទថា **ន សាមញ្ញាយ** (មិន... ជាសមណៈ) បានដល់ មិនប្រព្រឹត្តទៅដើម្បីភាពជាសមណធម៌ ។ បទថា **ន ឯកីភាវាយ** (មិន... ប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលម្នាក់ឯង) បានដល់ មិនប្រព្រឹត្តទៅដើម្បីមិនមានចន្លោះ ។ បទថា **ធម្មានំ ន និសាមកជាតិកោ** (ជាអ្នកមិនពិចារណាធម៌ទាំងឡាយ) បានដល់ ជាអ្នកមិនពិចារណាលោកុត្តរធម៌ ៩ ជាអ្នកមិនចងចាំ ។ បទថា **ន បដិសល្លានោ** (ជាអ្នកមិនការពួនសម្ងំ)*

បានដល់ ជាអ្នកមិនពួនសម្ងំ ។ បទថា **សាថេយ្យានិ** (ការអួតអាង) បានដល់ មានអំនួត ។ បទថា **កុដេយ្យានិ** (កោង) បានដល់ មានការកោង ។ បទថា **ជិម្ហេយ្យានិ** (មិនត្រង់) បានដល់ មានការមិនទៀងត្រង់ ។ បទថា **វង្កេយ្យានិ** (វៀច) បានដល់ មានការវៀច ។

ចប់អដ្ឋកថា អធិករណសូត្រទី ៧

# អដ្ឋកថា ព្យសនសូត្រទី ៨

## ភិក្ខុពោលទោសព្រះអរិយៈ

## គប្បីដល់នូវសេចក្តីវិនាស ១០ យ៉ាង

*គប្បីជ្រាបវិនិច្ឆ័យក្នុង ព្យសនសូត្រទី ១០ ដូចតទៅនេះ ៖*

*[៨៨] ក្នុងបទថា **អក្កោសកបរិភាសកោ អរិយុបវាទី សព្រហ្មចារីនំ** (ជេរប្រទេចសព្រហ្មចារីទាំងឡាយ ពោលទោសព្រះអរិយៈ) នេះ គប្បីប្រកប **សព្រហ្មចារី** បទ ជាមួយ **អក្កោសក** បទ និង **បរិភាសក** បទ ថា ជាអ្នកជេរប្រទេចសព្រហ្មចារី ជាអ្នកផ្ចាសាសព្រហ្មចារី ។ បុគ្គលពោលប្រទូស្តដោយអន្តិមវត្ថុថា យើងនឹងសម្លាប់គុណរបស់ព្រះអរិយៈទាំងឡាយ រមែងឈ្មោះថា អរិយុបវាទី ។ បទថា **សទ្ធម្មស្ស ន វោទាយន្តិ** (ព្រះសទ្ធម្មរបស់ភិក្ខុនោះ រមែងមិនបរិសុទ្ធ) សេចក្តីថា ព្រះសទ្ធម្ម គឺ សាសនាដែលរាប់បានថា ជាត្រៃសិក្ខារបស់ភិក្ខុនោះ រមែងមិនដល់សេចក្តីផូរផង់ ។ រោគប៉ុណ្ណោះ គប្បីជ្រាបថា អាតង្កៈ ដូច្នេះ ព្រោះធ្វើឲ្យជីវិតលំបាក ក្នុងបទថា **រោគាតង្កំ** នេះ ។*

ចប់អដ្ឋកថា ព្យសនសូត្រទី ៨

# អដ្ឋកថា កោកាលិកសូត្រទី ៩

## *កោកាលិកភិក្ខុពោលអាឃាត*

## *ព្រះសារីបុត្ត និងព្រះមហាមោគ្គល្លាន*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កោលិកសូត្រទី ៩ ដូចតទៅនេះ ៖*

[៨៩] *បទថា កោកាលិកោ ភិក្ខុ យេន ភគវា តេនុបសង្កមិ (ភិក្ខុឈ្មោះថា កោកាលិកៈ ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់) សេចក្ដីថា ភិក្ខុកោកាលិកៈនេះ គឺ នរណា និងហេតុអ្វីទើបចូលទៅគាល់ ។ បានឮមកថា កោកាលិកភិក្ខុនេះ ជាបុត្ររបស់កោកាលិកសេដ្ឋី ក្នុងនគរកោកាលិកៈ រដ្ឋកោកាលិកៈ បួសហើយ នៅប្រចាំក្នុងវិហារដែលបិតាសាងទុក ។ តែភិក្ខុដែលជាសិស្សរបស់ព្រះទេវទត្ត ឈ្មោះថា ចូឡកោកាលិកៈ ។ ក៏កោកាលិកៈបុត្រព្រាហ្មណ៍នោះ ឈ្មោះថា មហាកោកាលិកៈ ។ ក៏កាលព្រះមានព្រះភាគប្រថាប់នៅក្រុងសាវត្ថី ព្រះអគ្គសាវកទាំងពីរ ក៏ចារិកទៅក្នុងជនបទព្រមទាំងភិក្ខុប្រមាណ ៥០០ រូប កាលថ្ងៃជិតចូលវស្សា បំណាងនឹងនៅដោយស្ងាត់ ទើបបញ្ជូនភិក្ខុទាំងនោះត្រឡប់*

ឲ្យត្រឡប់វិញ ខ្ញុំនលោកកាន់បាត្រ និងចីវរទៅកាន់នគរនោះ ក្នុងជនបទនោះ លុះដល់វិហារនោះ ក៏ទៅកាន់វិហារនោះ ។ ក្នុងវិហារនោះ ព្រះកោកាលិកៈក៏ធ្វើវត្តបដិបត្តិដល់ព្រះអគ្គសាវកទាំងពីរនោះ ព្រះអគ្គសាវកក៏សម្មោទនានឹងព្រះកោកាលិកៈនោះ ទទួលថា អ្នកមានអាយុ យើងនឹងនៅទីនេះ ៣ ខែ លោកកុំប្រាប់រឿងរបស់យើងដល់នរណាៗ ហើយក៏នៅចាំវស្សា លុះចាំវស្សាហើយ ក៏បវារណាក្នុងថ្ងៃបវារណា ក៏ប្រាប់លាកោកាលិកៈភិក្ខុថា អ្នកមានអាយុ យើងនឹងទៅ ។ កោកាលិកៈភិក្ខុពោលថា អ្នកមានអាយុ នៅមួយថ្ងៃទៀតចុះ ថ្ងៃស្អែកនេះសឹមទៅ ។ ស្អែកឡើង ក៏ចូលព្រះនគរប្រាប់មនុស្សម្នាទាំងឡាយថា អ្នកមានអាយុ អ្នកមិនដឹងទេឬថា ព្រះអគ្គសាវកទាំងពីរមកនៅក្នុងទីនេះ នរណាៗ នឹងមិននិមន្តលោកដោយបច្ច័យខ្លះឬ ។ អ្នកនគរទើបពោលថា លោកម្ចាស់ ព្រះថេរៈនៅទីណា ហេតុអ្វីលោកមិនប្រាប់ពួកយើង ។ កោកាលិកៈភិក្ខុពោលថា អ្នកមានអាយុ នឹងត្រូវប្រាប់ដូចម្តេច ពួកលោកមិនឃើញព្រះថេរៈ ២ រូបអង្គុយនៅលើថេរាសនៈទេឬ នោះឯងជាព្រះអគ្គសាវក ។ អ្នកនគរទាំង

នោះ ប្រញាប់ប្រញាល់ប្រជុំ រូបរួមទឹកដោះថ្លា ទឹកឃ្មុំជាដើម និងសំពត់ធ្វើចីវរទាំងឡាយ ។

កោកាលិកភិក្ខុគិតថា ព្រះអគ្គសាវកមានសេចក្ដីប្រាថ្នាតិចដ៏ក្រៃលែង នឹងមិនត្រេកអរលាភដែលកើតឡើងដោយបយុត្តវាចា (វាចានិយាយបញ្ឆិតបញ្ឆៀងដើម្បីលាភ) កាលលោកមិនត្រេកអរ ក៏នឹងប្រាប់ថា ឲ្យដល់ភិក្ខុប្រចាំវត្ត ដូច្នេះ ហើយទើបឲ្យគេកាន់លាភនោះទៅកាន់សំណាក់របស់ព្រះថេរៈ ។ ព្រះថេរៈឃើញហើយ ក៏បដិសេធថា បច្ច័យមិនសមគួរដល់យើង ទាំងមិនសមគួរដល់កោកាលិកៈភិក្ខុ ដូច្នេះ ហើយក៏ត្រឡប់ទៅ ។ កោកាលិកភិក្ខុកើតអាឃាតថា អ្វីហ្ន៎ ព្រះអគ្គសាវក កាលខ្លួនឯងមិនទទួល ក៏មិនឲ្យដល់យើង ហើយចៀសចេញទៅ ។ ព្រះអគ្គសាវកទាំងពីរនោះមកគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ក៏នាំបរិស័ទរបស់ខ្លួនចារិកទៅកាន់ជនបទទៀត ត្រឡប់មកកាន់នគរនោះ ក្នុងរដ្ឋនោះឯង តាមលំដាប់ ពួកអ្នកក្រុងចាំព្រះថេរៈបាន ក៏ចាត់ចែងទាន ព្រមបរិក្ខារ សាងមណ្ឌបកណ្ដាលព្រះនគរថ្វាយទាន ហើយបង្អោនបរិក្ខារថ្វាយព្រះថេរៈ ។ ព្រះថេរៈ

ក៏ប្រគល់ដល់ភិក្ខុសង្ឃ ។ ព្រះកោកាលិកៈឃើញដូចនោះគិតថា ព្រះអគ្គសាវកនេះ ពីមុនជាអ្នកប្រាថ្នាតិច ឥឡូវនេះក្លាយជាអ្នកមានសេចក្តីប្រាថ្នាអាក្រក់ ប្រហែលកាលមុននឹងធ្វើជាអ្នកប្រាថ្នាតិច សន្តោស និងស្ងប់ស្ងាត់ ទើបចូលទៅរកព្រះថេរៈ ពោលថា អ្នកមានអាយុ ពួកលោកពីមុនធ្វើដូចជាអ្នកប្រាថ្នាតិច តែឥឡូវនេះ ក្លាយជាភិក្ខុអាក្រក់ហើយ គិតថា ចាំឃើញនឹងទម្លាយទីពឹងរបស់ព្រះថេរៈទាំងនោះ ទើបប្រញាប់ចេញទៅ ចូលទៅគាល់ព្រះមានព្រះភាគ ។ ភិក្ខុកោកាលិកៈនេះ គប្បីជ្រាបថា ចូលទៅគាល់ព្រោះហេតុនេះ ។

ព្រះមានព្រះភាគ ឃើញកោកាលិកភិក្ខុនោះមកដោយរលះរលាំង ទ្រង់ពិចារណាក៏ជ្រាបថា ភិក្ខុនេះ មកដើម្បីប្រាថ្នានឹងជេរព្រះអគ្គសាវក តថាគតនឹងហាមបានទេហ្ន៎ ទ្រង់ឃើញថា ហាមមិនបាន លោកធ្វើខុសក្នុងព្រះថេរៈទាំងពីរមកហើយ នឹងកើតក្នុងបទុមនរកតែម្យ៉ាង ទ្រង់ហាមដល់ ៣ ដងថា កុំនិយាយយ៉ាងនេះឡើយ ដើម្បីទ្រង់ដោះវាទៈដែលថា ព្រះមាន-ព្រះភាគទ្រង់ជ្រាបថា កោកាលិកភិក្ខុតិះដៀលព្រះសារីបុត្រ និងមោគ្គល្លាន

ហើយ ទ្រង់ក៏មិនហាម និងដើម្បីនឹងទ្រង់សម្ដែងថា អរិយុបវាទមានទោស ច្រើន ។ បទថា **មាហេវំ** ក្នុងបទនោះ ប្រែថា កុំពោលយ៉ាងនេះឡើយ ។

បទថា **សទ្ធាយិកោ (ជាទីតាំងនៃសទ្ធា)** បានដល់ ហៅការជឿ នាំមកដែលសេចក្ដីជ្រះថ្លា ឬមានវាចាដែលគួរជឿបាន ។ បទថា **បច្ចយិកោ (ជាអ្នកមានព្រះពុទ្ធវចនៈដែលខ្ញុំព្រះអង្គគប្បីជឿបាន)** បានដល់ មានវាចា ដែលគួររាប់អាន ។ បទថា **បក្កាមិ (ចៀសចេញទៅ)** បានដល់ ត្រូវ អានុភាពរបស់កម្មជាស់តឿនក៏ចៀសចេញទៅ ។ ពិតហើយ កម្មដែល ដល់ឱកាសហើយ អ្វីៗ ក៏ហាមមិនបាន ។ បទថា **អចិរបក្កន្តស្ស** ប្រែថា ចៀសចេញទៅមិនយូរ ។

បទថា **សព្វោ កាយោ ផុដ្ឋោ អហោសិ (រាងកាយមាន... ពេញខ្លួន)** សេចក្ដីថា ទូទាំងខ្លួនមិនវៀរឱកាសត្រឹមតែចុងសក់ ក៏បានត្រូវពង បែកទាំងឡាយជ្រែកធ្លុះផុសឡើង ។ ក៏ព្រោះហេតុដែលកម្មបែបនោះ មិន អាចឲ្យវិបាកចំពោះព្រះភក្ត្រព្រះពុទ្ធទាំងឡាយ ដោយពុទ្ធានុភាព ក៏រមែង ឲ្យផលល្មមពេលផុតអំពីឧបចារៈទីគាល់ ដូច្នោះ ពងបែកទាំងឡាយទើប

ផុសឡើង កាលកោកាលិកភិក្ខុនោះចៀសទៅមិនយូរ ។ បទថា **កឡាយ-កមត្តិយោ** ប្រែថា ប៉ុនគ្រាប់សណ្តែកខ្មៅ ។ បទថា **វេលុវសេលាដុកមត្តិយោ** ប្រែថា ប៉ុនផ្លៃព្នៅខ្ចី ។ បទថា **បភិជ្ជឹសុ** ប្រែថា បែកហើយ ។ កាលពងបែកទាំងនោះបែកហើយ ទូទាំងខ្លួនក៏បានដូចជាខ្នុរទុំ ។ កោកាលិកភិក្ខុនោះ មានខ្លួនដែលឆ្អិនហើយ ដេកលើស្លឹកចេក ជិតសុំមទ្វារព្រះជេតពនដូចត្រីលេបថ្នាំពិស ។ គ្រានោះ មនុស្សទាំងឡាយដែលមកស្តាប់ធម៌ក៏នាំគ្នានិយាយថា ឱ! កោកាលិកៈ ឱ! កោកាលិកៈ ធ្វើមិនត្រូវឡើយ អាស្រ័យមាត់របស់ខ្លួនតែម្យ៉ាង ក៏ដល់នូវសេចក្តីវឡេះវល្ហយ ។ អារក្ខ-ទេវតាទាំងឡាយ ស្តាប់សំឡេងរបស់មនុស្សទាំងនោះ ក៏បានធ្វើសំឡេងតិះដៀល ។ អាកាសទេវតាស្តាប់អារក្ខទេវតា ក៏តិះដៀល ដូច្នោះដូចគ្នាហេតុនោះ ទើបកើតសំឡេងតិះដៀលតែមួយ ដោយឧបាយយ៉ាងនេះ ដរាបដល់អកនិដ្ឋភព ។

បទថា **តុទិ** បានដល់ ឧបជ្ឈាយ៍របស់ព្រះកោកាលិកៈ ឈ្មោះតុទិត្ថេរៈ សម្រេចអនាគាមិផល កើតក្នុងព្រហ្មលោក ។ លោកបានឮសំឡេង

តិះដៀលតាំងពីក្ដូម្ដកទេវតា.តៗ គ្នា ដរាបដល់ព្រហ្មលោក គិតថា កោកាលិកៈ ពោលបន្ទាបព្រះអគ្គសាវកដោយអន្ទិមវត្ថុ ធ្វើកម្មមិនត្រូវ ក៏គិតថា គួរអាណិត កាលយើងឃើញគេ ក៏ចូរកុំវិនាសឡើយ ចាំយើង នឹងប្រៀនប្រដៅគេ ដើម្បីឲ្យចិត្តជ្រះថ្លាក្នុងព្រះអគ្គសាវកទាំងពីរ ដូច្នេះ ហើយទើបមកឈរចំពោះមុខកោកាលិកៈភិក្ខុនោះ ។ លោកសំដៅយក តុទិព្រហ្មនោះ ទើបពោលពាក្យនេះថា ៗ តុទិបច្ចេកព្រហ្ម ។

បទថា **បេសលា** ប្រែថា ជាអ្នកមានសីលជាទីស្រឡាញ់ ។ ព្រះ កោកាលិកៈដេកបើកភ្នែកទាំងស្រវាំង ពោលយ៉ាងនេះថា **អ្នកមានអាយុ លោកជានរណា** ។ បទថា **បស្ស យាវញ្ច តេ (លោកចូរឃើញ... របស់លោកដែលមានហើយ)** សេចក្ដីថា ព្រះកោកាលិកៈពោលថា ចូរ មើល លោកធ្វើកំហុសមានប្រមាណប៉ុនណា កាលមិនឃើញខ្ទាចក្បាល ធំ ត្រង់ថ្ងាស់របស់ខ្លួន សម្គាល់ថា គប្បីជាស់តៀនយើងដែលមានចំណែក ប៉ុនគ្រាប់ស្ពៃប្ញ ។

គ្រានោះ តុទិព្រហ្មដឹងថា កោកាលិកៈនេះមិនពេញចិត្ត នឹងមិនជឿ

នរណាៗ ដូចត្រីដែលលេបថ្នាំពិស ទើបពោលនឹងកោកាលិកៈនោះថា **បុរិសស្ស ហិ** ជាដើម ។ បទថា **កុធារី (ប៉ូវថៅ)** ក្នុងគាថានោះ បាន ដល់ វាចាគ្រោតគ្រោតដូចកាប់ដោយប៉ូវថៅ ។ បទថា **ឆិន្ទតិ (កាត់)** បានដល់ រមែងកាត់ដែលឫសនោះឯង ពោលគឺ កុសលមូល ។ បទថា **និន្ទិយំ (អ្នកដែលគួរតិះដៀល)** បានដល់ បុគ្គលទ្រុស្តសីលដែលគប្បី តិះដៀល ។ បទថា **បសំសតិ (សរសើរ)** បានដល់ សរសើរប្រយោជន៍ ដ៏ខ្ពង់ខ្ពស់ ទើបពោលថា ព្រះខីណាស្រព ។ បទថា **តំ វា និន្ទតិ យោ បសំសិយោ (ឬតិះដៀលបុគ្គលដែលគួរសរសើរ)** សេចក្ដីថា ឬថា បុគ្គល ណាដែលគេគប្បីសរសើរជាព្រះខីណាស្រព កោកាលិកៈនេះ ក៏ទៅជាចោទ បុគ្គលនោះដោយអន្ទិមវត្ថុ ពោលថា ភិក្ខុនេះទ្រុស្តសីល ។

បទថា **វិចិនាតិ មុខេន សោ កលឹ (បុគ្គលនោះឈ្មោះថាសន្សំទុក្ខដោយច្រើន)** សេចក្ដីថា បុគ្គលនោះឈ្មោះថា សន្សំសេចក្ដីខុសនោះ ដោយមាត់ ។ បទថា **កលិនា តេន (ព្រោះទោសនោះ)** សេចក្ដីថា រមែងមិនជួបសេចក្ដីសុខព្រោះទោសនោះ ។ ពិតហើយ ការសរសើរអ្នក

ដែលគួរតិះដៀល និងការតិះដៀលអ្នកដែលគួរសរសើរ មានវិបាកស្មើគ្នា ។

បទថា **សព្វស្សាបិ សហាបិ អត្តនា** (ដោយខ្លួនឯងរហូតអស់ទាំងខ្លួន) សេចក្តីថា ឈ្មោះថា ការចាញ់ទ្រព្យក្នុងល្បែងភ្នាល់ទាំងឡាយណា ដោយទ្រព្យរបស់ខ្លួន ព្រមទាំងខ្លួន ការចាញ់ទ្រព្យយ៉ាងនេះ ជាទោសតិចតួច ។

បទថា **យោ សុគតេសុ** (បុគ្គល... ក្នុងព្រះអរិយៈដែលប្រព្រឹត្តទៅល្អហើយ) សេចក្តីថា បុគ្គលណាគិតប្រទូស្តក្នុងបុគ្គលដែលបដិបត្តិល្អ ការគិតប្រទូស្តរបស់បុគ្គលនោះ នេះមានទោសច្រើនជាងទោសនោះ ។

ឥឡូវនេះ ទ្រង់ព្រហ្មកាលនឹងសម្តែងថា សេចក្តីគិតប្រទូស្តនោះមានទោសច្រើនជាង ទើបពោលពាក្យថា **សតំ សហស្សានំ** (១០០.០០០) ជាដើម ។ បទថា **សតំ សហស្សានំ** (១០០.០០០) បានដល់ មួយសែនដោយការរាប់និរព្វុទៈ ។ បទថា **ឆត្តឹស** (៣៦) បានដល់ ៣៦ និរព្វុទៈទៀត ។ បទថា **បញ្ច ច** (និង ៥) បានដល់ ៥ អព្វុទៈ ដោយការរាប់អព្វុទៈ ។ បទថា **យមរិយគរហី** (តិះដៀលព្រះអរិយៈ) សេចក្តីថា អ្នកតិះដៀលព្រះអរិយៈ រមែងចូលដល់នរកណា នោះជាប្រមាណនៃអាយុ

ក្នុងនរកនោះ ។ បទថា **កាលមកាសិ** (បានធ្វើកាលៈ) សេចក្តីថា ក៏ស្លាប់ កាលឧបជ្ឈាយ៍ចៀសចេញទៅ ។

បទថា **បទុមនិរយំ** (បទុមនរក) សេចក្តីថា ឈ្មោះថា បទុមនរក ដែលផ្សេងរមែងមិនមាន ។ តែកើតក្នុងកន្លែងមួយ ក្នុងអវិចីមហានរកនុ៎ះឯង ។ ក៏ពាក្យថា **វីសតិខារិកោ** (២០ ខារី) មានអធិប្បាយថា ៤ បត្ថៈ ដោយបត្ថៈរបស់អ្នកដែនមគធៈ ជា ១ បត្ថៈ ក្នុងដែនកោសល , ៤ បត្ថៈដោយបត្ថៈនោះ ជា ១ អាឡ្ហកៈ , ៤ អឡ្ហកៈ ជា ១ ទោណៈ , ៤ ទោណៈ ជា ១ មានិកា , ៤ មានិកៈ ជា ១ ខារី , ទើបជា ២០ ខារី ដោយខារីនោះ ។ បទថា **តិលវាហោ** (រទេះល្ង) បានដល់ រទេះដឹកគ្រាប់ល្ង ដែលជាគ្រាប់ល្ងដ៏ល្អរបស់អ្នកដែនមគធៈ ។

បទថា **អព្វុទោ និរយោ** (អព្វុទនរក) សេចក្តីថា នរកឈ្មោះអព្វុទៈ ដែលផ្សេងនោះរមែងមិនមាន ។

ក៏ពាក្យថា អព្វុទៈនេះ ជាឈ្មោះទីកន្លែងដែលសត្វគប្បីឆេះ ដោយការរាប់អព្វុទនរកក្នុងអវិចីនរកនោះឯង ។ សូម្បីក្នុងនរកឈ្មោះថា និរព្វុទៈ

ជាដើម ក៏ន័យនេះ ។ ម្យ៉ាងទៀត ក្នុងនរកទាំងនេះ គប្បីជ្រាបដោយការរាប់ឆ្នាំយ៉ាងនេះ ។

ដូចជា ១០០ សែន ជា ១ កោដិ យ៉ាងណា ១០០ សែនកោដិ ឈ្មោះថា ១ បកោដិ ក៏ដូច្នោះ , ១០០ សែនបកោដិ ឈ្មោះថា ១ កោដិបកោដិ ។ ១០០ សែនកោដិបកោដិ ឈ្មោះថា ១ នហុត ។ ១០០ សែននហុត ជា ១ និន្នហុត , ១០០ សែននិន្នហុត ជា ១ អព្វុទៈ ។ យកអព្វុទៈនោះគុណនឹង ២០ ជា និរព្វុទៈ ។ ក្នុងគ្រប់បទក៏ន័យនេះឯង ។

ចប់អដ្ឋកថា កោកាលិកសូត្រទី ៩

# អដ្ឋកថា ពលសូត្រទី ១០

## *កម្លាំងរបស់ព្រះខីណាស្រព ១០ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពលសូត្រទី ១០ ដូចតទៅនេះ ៖*

[៩០] *គប្បីជ្រាបដោយន័យដែលពោលទុកហើយ ក្នុងខាងក្រោយនោះឯង ។ ពាក្យដ៏សេសក្នុងគ្រប់បទ ងាយហើយនោះឯង ។*

ចប់អដ្ឋកថា ពលសូត្រទី ១០

## ចប់ថេរវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

# ឧបាសកវគ្គវណ្ណនាទី ៥

# អដ្ឋកថា កាមភោគីសូត្រទី ១

## *កាមភោគីបុគ្គល ១០ ពួក*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កាមភោគីសូត្រទី ១ ដូចតទៅនេះ ៖*

*[៩១] បទថា សាហសេន (ការកំហែងសង្កត់សង្កិន) បានដល់កម្មដែលគ្រោតគ្រាត ។*

ចប់អដ្ឋកថា កាមភោគីសូត្រទី ១

# អដ្ឋកថា ទេវសូត្រទី ២

## *កាមភោគីបុគ្គល ១០ ពួក*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កាមភោគីសូត្រទី ១ ដូចតទៅនេះ ៖*

*[៩២] បទថា **ភយានិ (ភ័យ)** បានដល់ ភ័យ គឺ សេចក្តីតក់ស្លុតនៃចិត្ត ។ បទថា **វេរានិ (ពៀរ)** បានដល់ ពៀរចាកអកុសល និងពៀរចាកបុគ្គល ។ បទថា **អរិយោ ចស្ស ញាយោ (ក៏ញេយ្យធម៌ដែលជាអរិយៈ)** បានដល់ មគ្គព្រមទាំងវិបស្សនា ។ បទថា **ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ (កាលវត្ថុនេះមាន វត្ថុនេះទើបមាន... យ៉ាងនេះ)** សេចក្តីថា កាលហេតុ មានអវិជ្ជាជាដើមនេះមាន ផលមានសង្ខារជាដើម ទើបមាន ។ បទថា **ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ (ព្រោះវត្ថុនេះកើត វត្ថុនេះទើបកើត)** សេចក្តីថា សហជាតប្បច្ច័យណាមានហើយ ព្រោះការកើតឡើងនៃសហជាតប្បច្ច័យនោះ ផលក្រៅពីនេះ ឈ្មោះថា រមែងកើត ។ បទថា **ឥមស្មឹ អសតិ (កាលវត្ថុនេះមិនមាន)** សេចក្តីថា កាលហេតុមានអវិជ្ជាជាដើម មិនមាន ផលមានសង្ខារជាដើម ក៏មិនមាន ។*

*បទថា* **ឥមស្ស និរោធា** *(ព្រោះវត្ថុនេះរលត់) សេចក្ដីថា ព្រោះការមិនប្រព្រឹត្តទៅនៃហេតុ ការមិនប្រព្រឹត្តទៅនៃផលក៏មាន ។*

ចប់អដ្ឋកថា វេរសូត្រទី ២

# អដ្ឋកថា ទិដ្ឋិសូត្រទី ៣

## អនាថបិណ្ឌិកសេដ្ឋីប្រាប់ទិដ្ឋិរបស់ខ្លួន

## ដល់អញ្ញតិរ្ថិយ

គប្បីជ្រាបវិនិច្ឆ័យក្នុង ទិដ្ឋិសូត្រទី ៣ ដូចតទៅនេះ ៖

[៩៣] បទថា **សណ្ណាបេសុំ** (ឲ្យឈប់) បានដល់ ញុំាងឥរិយាបថខ្លះ ពាក្យនិយាយខ្លះ ឲ្យឈប់ ។ បទថា **អប្បសទ្ទវិនីតា** (បានទទួលការណែនាំដោយសំឡេងស្រាល) បានដល់ អ្នកដែលព្រះសាស្តាទ្រង់មានព្រះសូរសៀងតិច ត្រាស់តែល្មមប្រមាណ ទ្រង់ណែនាំហើយ ។ បទថា **បរឃោសប្បច្ចយា វា** (ឬព្រោះឃោសនារបស់អ្នកដទៃជាបច្ច័យ) បានដល់ ឬថា ព្រោះពាក្យរបស់បុគ្គលដទៃជាហេតុ ។ បទថា **ចេតយិតា** (ដែលបច្ច័យឲ្យកើតឡើងហើយ) បានដល់ បច្ច័យកំណត់ហើយ ។ បទថា **មង្កុភូតា** (អៀនខ្មាស) បានដល់ តូចចិត្ត អស់អំណាច ។ បទថា **បត្តក្ខន្ធា** ប្រែថា ឱន.ក ។ បទថា **សហធម្មេន** (ត្រូវតាមធម៌) បានដល់ ដោយពាក្យដែលមានហេតុ មានការណ៍ ។

ចប់អដ្ឋកថា ទិដ្ឋិសូត្រទី ៣

# អដ្ឋកថា វជ្ជិយសូត្រទី ៤

## *វជ្ជិយមាហិតគហបតី ញាំញីអញ្ញតិរ្ថិយបរិញ្វាជក*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វជ្ជិយសូត្រទី ៤ ដូចតទៅនេះ ៖*

[៩៤] *គហបតីមានឈ្មោះយ៉ាងនេះថា* ***វជ្ជិយមាហិតៈ*** *។ បទថា* ***សព្វំ តបំ (តបៈទាំងឡាយ)*** *សេចក្តីថា មានការធ្វើកិច្ចដែលធ្វើបានលំបាក ជាតបៈគ្រប់យ៉ាង ។ បទថា* ***សព្វំ តបស្សឹ (អ្នកមានតបៈទាំងអស់)*** *បានដល់ អ្នកអាស្រ័យតបៈគ្រប់យ៉ាង ។ បទថា* ***លូខាជីវឹ (អ្នកដែលចិញ្ចឹមជីវិតដោយអាការសៅហ្មង)*** *បានដល់ ប្រកបរឿយៗ នូវការចិញ្ចឹមជីវិតដោយការធ្វើកិច្ចដែលធ្វើបានលំបាក ។ បទថា* ***គារយ្ហំ*** *ប្រែថា អ្នកគួរតិះដៀល ។ បទថា* ***បសំសិយំ*** *ប្រែថា អ្នកគួរសរសើរ ។ បទថា* ***វេនយិកោ (ជាអ្នកណែនាំ)*** *បានដល់ អ្នកដែលខ្លួនឯងមិនបានណែនាំ តែបុគ្គលដទៃណែនាំ ។ បទថា* ***អប្បញ្ញត្តិកោ (ជាអ្នកមិនមានបញ្ញត្តិ)*** *សេចក្តីថា មិនអាចបញ្ញត្តិវត្ថុណាៗ ។ ន័យមួយទៀត បទថា* ***វេនយិកោ (ជាអ្នកណែនាំក្នុងផ្លូវវិនាស)*** *បានដល់ ជាអ្នកនាំសត្វឲ្យវិនាស ។ បទថា*

*អប្បញ្ញត្តិកោ* (ជាអ្នកមិនមានបញ្ញា) បានដល់ បញ្ញត្តិព្រះនិព្វានដែលមិនប្រចក្ស មិនអាចបញ្ញត្តិវត្ថុណាៗ ក្នុងសស្សតទិដ្ឋិជាដើម ។ បទថា *ន សោ ភគវា វេនយិកោ* (ព្រះមានព្រះភាគនោះ មិនមែនជាបុគ្គលណែនាំក្នុងផ្លូវវិនាស) សេចក្តីថា ព្រះមានព្រះភាគនោះ ទ្រង់ដឹងតាមសេចក្តីពិតយ៉ាងនេះ ទ្រង់បញ្ញត្តិកុសល និងអកុសល មិនមែនអ្នកដទៃគប្បីណែនាំ មិនមែនអ្នកដទៃឲ្យសិក្សា អធិប្បាយថា ព្រះមានព្រះភាគទ្រង់មិនមែននាំសត្វឲ្យវិនាស ទ្រង់ណែនាំដោយល្អ ទ្រង់ឲ្យសិក្សាដោយល្អ ទ្រង់ណែនាំសត្វ ព្រោះទ្រង់បញ្ញត្តិធម៌ដែលទ្រង់អាស្រ័យបញ្ញត្តិប្រកបដោយសតិ ។ លោកសម្តែងថា ការបញ្ញត្តិរបស់ព្រះមានព្រះភាគនោះ ជាការបញ្ញត្តិដែលល្អនោះឯង ។

បទថា *វិមុត្តិ វិមុច្ចតោ អកុសលា ធម្មា* (កាលបុគ្គលរួចផុតចាកការរួចផុតអកុសលធម៌ទាំងឡាយ) សេចក្តីថា អកុសលធម៌ទាំងឡាយឈ្មោះថា រមែងចម្រើនដល់ចិត្តដែលបង្អោនទៅកាន់អធិមុត្តិ គឺ មិច្ឆាទិដ្ឋិ ។ ទ្រង់សំដៅយកប្រការនោះ ទើបត្រាស់ពាក្យនេះ ។ តែការរួចផុតនៃចិត្ត

ក្នុងព្រះសាសនា រមែងមិនស្មុះទៅកាន់សទ្ធម្មធម៌ ព្រោះហេតុនោះ វិមុត្តិ

ការរួចផុត ទើបជាបច្ច័យដល់កុសលធម៌ប៉ុណ្ណោះ ។

ចប់អដ្ឋកថា វណិជ្ជសូត្រទី ៧

# អដ្ឋកថា ឧត្តិយសូត្រទី ៥

## *ព្រះមានព្រះភាគទ្រង់សម្ដែងធម៌ដល់សាវក*

## *ដើម្បីសេចក្ដីដឹងដ៏ក្រៃលែង*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧត្តិយសូត្រទី ៥ ដូចតទៅនេះ ៖*

[៩៥] *បទថា* ***តុណ្ហី អហោសិ*** *(ទ្រង់នៅស្ងៀម) សេចក្ដីថា ឧត្តិយបរិព្វាជកតាំងនៅក្នុងសត្តូបលទ្ធិ (លទ្ធិថាមានសត្វ) ទើបសួរក្នុងប្រការដែលមិនគួរសួរ ហេតុនោះទើបទ្រង់គង់ស្ងៀម ។ បទថា* ***សព្វំ សាមុក្កំសិកំ វត មេ*** *(ត្រូវយើង... ចំពោះមុខ) សេចក្ដីថា ព្រះសមណគោតមត្រូវយើងសួរដោយពាក្យសួរដ៏ខ្ពស់ ក្នុងបណ្ដាពាក្យសួរគ្រប់យ៉ាងក៏ទ្រង់ស្ងៀមមិនតប គង់នឹងមិនអាច មិនអាចនឹងតបដោយពិត ព្រោះហេតុនោះ លោកកុំមានការឃើញអាក្រក់ៗ ដូចដែលពោលមកនេះឡើយ ។ បទថា* ***តទស្ស*** *(នោះនឹងគប្បីប្រព្រឹត្តទៅ) បានដល់ ទិដ្ឋិនោះ គប្បីកើតឡើងយ៉ាងនេះ ។*

*បទថា* ***បច្ចន្តិមំ*** *(ដែលតាំងនៅជាយដែន) សេចក្ដីថា ព្រោះហេតុ*

ដែលប៉ម និងកំផែងជាដើម របស់នគរក្នុងមជ្ឈិមប្រទេសរឹងមាំ ឬមិនរឹងមាំ ឬថា មិនជាទីដែលចោរក័យខ្លាចដោយប្រការទាំងពួង ដូច្នោះ ទ្រង់មិនកាន់យកប្រការនោះ ទើបត្រាស់ថា **នគរដែលតាំងនៅជាយដែន** ។ បទថា **ទឡ្ហុទ្ទាលំ (មានគ្រឹះរឹងមាំ)** បានដល់ មានកំពែងរឹងមាំ ។ បទថា **ទឡ្ហបាការតោរណំ (មានកំពែង និងទ្វាររឹងមាំ)** បានដល់ មានកំពែងរឹងមាំ និងមានសន្ទះទ្វាររឹងមាំ ។ ព្រោះហេតុអ្វី ទើបពោលថា មានទ្វារតែមួយ ព្រោះថា ក្នុងនគរដែលមានទ្វារច្រើន ចាំទីងត្រូវមានអ្នករក្សាទ្វារដែលឆ្លាតច្រើននាក់ ទ្វារតែមួយមនុស្សតែម្នាក់ក៏ល្មម ។ ក៏អ្នកដទៃស្មើដោយបញ្ញារបស់ព្រះតថាគតមិនមាន ព្រោះដូច្នោះ ទើបពោលថា មានទ្វារតែមួយ ដើម្បីទីងសម្តែងសេចក្តីប្រៀបធៀបប្រការដែលព្រះសាស្តា ទ្រង់ជាបណ្ឌិត និងទ្រង់ដូចជាអ្នករក្សាទ្វារ ដូច្នោះ ។

បទថា **បណ្ឌិតោ (ជាបណ្ឌិត)** បានដល់ បុគ្គលប្រកបដោយភាពជាបណ្ឌិត ។ បទថា **ព្យត្តោ (ឈ្លាស)** បានដល់ បុគ្គលប្រកបដោយភាពជាអ្នកអាច ។ បទថា **មេធាវី (មានបញ្ញា)** បានដល់ អ្នកប្រកបដោយ

មេធា ពោលគឺ បញ្ញាដ៏ឥតទូវឧបត្តិនៃឋានៈ ។ បទថា **អនុបរិយាយបថំ** បានដល់ ផ្លូវកំពែងដែលមានឈ្មោះថា បញ្ចៀង ។ បទថា **បាការសន្ធឹ** (ទី.តនៃកំពែង) បានដល់ ទីដែលមិនមានឥដ្ឋ ២ ដុំ ។ បទថា **បាការវិវរំ** (ចន្លោះនៃកំពែង) បានដល់ ទីដែលជាប្រហោងរបស់កំផែង ។ បទថា **តទេវេតំ បញ្ហំ** (បញ្ហានេះឯង) សេចក្ដីថា ឧត្តិយបរិព្វាជក សួរបញ្ហាដដែល ដែលសួរទុកដោយន័យថា លោកទៀងជាដើម ហើយក៏បញ្ឈប់ ។ ដោយបទថា **សព្វោ ច តេន លោកោ** (លោកទាំងអស់) ព្រះថេរៈ សម្ដែងថា ឧត្តិយបរិព្វាជក តាំងនៅក្នុងសត្តូបលទ្ធិនោះឯង ទើបសួរដោយអាការយ៉ាងដទៃ ។

ចប់អដ្ឋកថា ឧត្តិយសូត្រទី ៥

# អដ្ឋកថា កោកនុទសូត្រទី ៦

## ព្រះអានន្ទឆ្លើយបញ្ហារបស់កោកនុទបរិព្វាជក

គប្បីជ្រាបវិនិច្ឆ័យក្នុង កោកនុទសូត្រទី ៦ ដូចតទៅនេះ ៖

[៩៦] បទថា **បុព្វាបយមានោ** (សំដិលខ្លួន) បានដល់ ធ្វើខ្លួនឲ្យប្រាសចាកទឹកដូចមិនទាន់ស្ងួតទឹក ។ សព្ទថា **កេត្ថ អាវុសោ** កាត់បទថា **កោ ឯត្ថ អាវុសោ** ។ បទថា **យាវតា អាវុសោ ទិដ្ឋិ** សេចក្តីថា ឈ្មោះថា ទិដ្ឋិ ៦២ យ៉ាង មានយ៉ាងណា ។ បទថា **យាវតា ទិដ្ឋិដ្ឋានំ** (ហេតុជាទីតាំងទិដ្ឋិមានប៉ុន្មាន) សេចក្តីថា ហេតុជាទីតាំងនៃទិដ្ឋិ ៨ យ៉ាង មានប្រមាណយ៉ាងនេះ គឺ ខន្ធជាហេតុទីតាំងនៃទិដ្ឋិក៏មាន អវិជ្ជាក៏មាន ផស្សៈក៏មាន សញ្ញាក៏មាន វិតក្កៈក៏មាន អយោនិសោមនសិការៈក៏មាន បាបមិត្តក៏មាន បរតោឃោសៈ (ការដឹកនាំរបស់អ្នកដទៃ) ក៏មាន ឈ្មោះថា ហេតុនៃទិដ្ឋិ ។ បទថា **អធិដ្ឋានំ** ប្រែថា ទីតាំងមាំនៃទិដ្ឋិ ពាក្យនេះជាឈ្មោះរបស់ទិដ្ឋិទីតាំងមាំគ្របសង្កត់ ហើយប្រព្រឹត្តទៅ ។

បទថា **ទិដ្ឋិបរិយុដ្ឋានំ** (សេចក្តីរួបរឹតនៃទិដ្ឋិ) បានដល់ ការរួបរឹត

នៃទិដ្ឋិ ដែលលោកពោលទុកយ៉ាងនេះថា គឺ ១ ទិដ្ឋិ គឺ ទិដ្ឋិគតៈ (ការឃើញ) ។ ២ ទិដ្ឋិគហណៈ ព្រៃ គឺ ទិដ្ឋិ ។ ៣ ទិដ្ឋិកន្តារៈ កន្តារៈ គឺ ទិដ្ឋិ ។ ៤ ទិដ្ឋិវិសូកៈ សត្រូវ គឺ ទិដ្ឋិ ។ ៥ ទិដ្ឋិវិប្ផន្ទិតៈ សេចក្តីក្តៅក្រហាយ គឺ ទិដ្ឋិ ។ ៦ ទិដ្ឋិសញ្ញោជនៈ សញ្ញោជនៈ គឺ ទិដ្ឋិ ។ ៧ ទិដ្ឋិសល្លៈ កូនសរ គឺ ទិដ្ឋិ ។ ៨ ទិដ្ឋិសម្ពាធៈ សេចក្តីចង្អៀតចង្អល់ គឺ ទិដ្ឋិ ។ ៩ ទិដ្ឋិបលិពោធៈ គ្រឿងកង្វល់ គឺ ទិដ្ឋិ ។ ១០ ទិដ្ឋិពន្ធនៈ គ្រឿងចង គឺ ទិដ្ឋិ ។ ១១ ទិដ្ឋិបាតៈ ជ្រោះ គឺ ទិដ្ឋិ ។ ១២ ទិដ្ឋានុស័យ អនុស័យ គឺ ទិដ្ឋិ ។ ១៣ ទិដ្ឋិសន្តាបៈ គ្រឿងដុត គឺ ទិដ្ឋិ ។ ១៤ ទិដ្ឋិបរិឡាហៈ គ្រឿងក្តៅផ្សា គឺ ទិដ្ឋិ ។ ១៥ ទិដ្ឋិគន្ថៈ គ្រឿងជាតក្រង គឺ ទិដ្ឋិ ។ ១៦ ទិដ្ឋុបាទាន ឧបាទាន គឺ ទិដ្ឋិ ។ ១៧ ទិដ្ឋាភិនិវេសៈ សេចក្តីប្រកាន់មាំ គឺ ទិដ្ឋិ ។ ១៨ ទិដ្ឋិបរាមាសៈ ការស្ទាបអង្អែល គឺ ទិដ្ឋិ ។ បទថា **សមុដ្ឋានំ** ជាវេវចនៈនៃទិដ្ឋិឋានៈនុ៎ះឯង ។ សមដូចដែលលោកពោលទុកថា ខន្ធជាបច្ច័យ ព្រោះអត្ថថា ប្រកាន់ឋានៈនៃទិដ្ឋិតាំងឡើង ។ គ្រប់បទគប្បីឲ្យពិស្តារចុះ ។ ក៏សោតាបត្តិមគ្គ ឈ្មោះថា

***ទិដ្ឋិសមុគ្ឃាតៈ*** *ព្រោះដកទិដ្ឋិគ្រប់យ៉ាងបានដោយសមុច្ឆេទ ។ បទថា* ***តម្ហំ*** *(យើង... នោះ) បានដល់ យើងដឹងទិដ្ឋិនោះបានគ្រប់យ៉ាង ។ បទថា* ***ក្យាហំ*** *វក្ខាមិ (យើងពោល... យ៉ាងណាបាន) បានដល់ យើងពោលព្រោះហេតុណា ។*

ចប់អដ្ឋកថា សោណសូត្រទី ៦

# អដ្ឋកថា អាហុនេយ្យសូត្រទី ៧

*ភិក្ខុប្រកបដោយធម៌ ១០ ប្រការ*

*ជាអ្នកគួរទទួលវត្ថុដែលគេនាំមកបូជា*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាហុនេយ្យសូត្រទី ៧ ដូចតទៅនេះ ៖*

[៩៧] *បទថា* ***សម្មាទិដ្ឋិកោ*** *(ជាសម្មាទិដ្ឋិ) បានដល់ ជាអ្នកមានការឃើញតាមសេចក្តីពិត ។*

ចប់អដ្ឋកថា អាហុនេយ្យសូត្រទី ៧

# អដ្ឋកថា ថេរសូត្រទី ៨

*ភិក្ខុប្រកបដោយធម ១០ ប្រការ រមែងនៅជាសុខ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ថេរសូត្រទី ១០ ដូចតទៅនេះ ៖*

[៩៨] *បទថា* ***អធិករណសមុប្បាទវូបសមកុសលោ*** *(ជាអ្នកឈ្លាសក្នុងការរម្ងាប់អធិករណ៍) បានដល់ ជាអ្នកឈ្លាសក្នុងការរម្ងាប់ការកើតឡើងព្រោះកំណត់មូលនៃអធិករណ៍ ៤ បាន ហើយក៏រម្ងាប់ចេញ ។*

ចប់អដ្ឋកថា ថេរសូត្រទី ៨

# អដ្ឋកថា ឧបាលិសូត្រទី ៩

## ព្រះឧបាលិទូលសូមទៅនៅសេនាសនៈព្រៃ

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបាលិត្រទី ៩ ដូចតទៅនេះ ៖

[៩៩] បទថា ទុរភិសម្ភវានិ ហិ (ទៅលំបាក) បានដល់ បានលំបាក រកបានលំបាក ។ លោកអធិប្បាយថា អ្នកមានសក្តិតូច មិនអាចនឹងកាន់យកបាន ។ បទថា អរញ្ញវនបត្ថានិ (ព្រៃស្បាត និងព្រៃស្រោង) សេចក្តីថា ព្រៃធំ និងព្រៃក្រាស់ ឈ្មោះថា អរញ្ញៈ ព្រោះសម្រេចអង្គជាព្រៃ ។ ឈ្មោះថា វនបត្ថៈ ព្រោះឆ្ងាយពីលំនៅស្រុក ជាស្ថានទីពួកមនុស្សមិនចូលទៅជិត ។ បទថា បន្តានិ (ដែលស្ងាត់) បានដល់ ឆ្ងាយហួសប្រមាណ ។ បទថា ទុក្ករំ បវិវេកំ (ធ្វើសេចក្តីវិវេកបានលំបាក) បានដល់ កាយវិវេកធ្វើបានលំបាក ។ បទថា ទុរភិរមំ (លំបាកនឹងអភិរម្យ) បានដល់ មិនមែនត្រេកអរបានងាយៗ ។ បទថា ឯកត្តេ (ក្នុងការនៅម្នាក់ឯង) បានដល់ ក្នុងភាពជាអ្នកនៅម្នាក់ឯង ។ ទ្រង់សម្តែងអ្វី ។ ទ្រង់សម្តែងថា សូម្បីកាលធ្វើកាយវិវេកបានហើយ ក៏លំបាកនឹងឲ្យចិត្តត្រេកអរ

ក្នុងសេនាសនៈនោះ ។ ពិតហើយ លោកនេះមានរបស់ជាគូៗ គ្នា ជាទីត្រេកអរ ។ បទថា **ហរន្តិ មញ្ញេ** (ដូចជានាំ) បានដល់ ដូចជានាំទៅ ដូចជាបបួលទៅ ។ បទថា **មនោ** (ចិត្ត) បានដល់ ចិត្ត ។ បទថា **សមាធឹ អលភមានស្ស** (អ្នកមិនបានសមាធិ) បានដល់ អ្នកមិនបានឧបចារសមាធិ ឬអប្បនាសមាធិ ។ ទ្រង់សម្តែងអ្វី ។ ទ្រង់សម្តែងថា ព្រៃទាំងឡាយ ដូចជាធ្វើចិត្តរបស់ភិក្ខុដូច្នេះឲ្យរវើរវាយ ដោយសំឡេងស្លឹកឈើ និងម្រឹគជាដើម និងវត្ថុដែលគួរខ្វាចមានប្រការផ្សេងៗ ។ បទថា **សំសីទិស្សតិ** (ទើបលិចចុះ) បានដល់ នឹងលិចចុះដោយកាមវិតក្កៈ ។ បទថា **ឧប្បិលវិស្សតិ** (នឹងអណ្តែតឡើង) បានដល់ នឹងអណ្តែតឡើងខាងលើ ដោយព្យាបាទវិតក្កៈ និងវិហិង្សាវិតក្កៈ ។

បទថា **កណ្ណសន្ទោវិកំ** ប្រែថា លាងត្រចៀកលេង ។ បទថា **បិដ្ឋិសន្ទោវិកំ** ប្រែថា លាងខ្នងលេង ។ ទាំងពីរយ៉ាងនោះ ការយកប្រមោយបឺតទឹកហើយស្រោចត្រង់ត្រចៀកទាំងសងខាង ឈ្មោះថា កណ្ណសន្ទោវិកៈ ស្រោចទឹកត្រង់ខ្នង ឈ្មោះថា បិដ្ឋិសន្ទោវិកៈ ។ បទថា **គាធំ**

វិទ្ធូតិ (បានចុះ) បានដល់ បានទីដ៏សមគួរ ។

បទថា កោ ចាហំ កោ ច ហត្ថិនាគោ (យើងជាអ្វី និងដំរីធំនេះជាអ្វី) សេចក្តីថា យើងជាអ្វី ស្តេចដំរីជាអ្វី ព្រោះថា យើងក្តី ស្តេចដំរីនេះក្តី ក៏ជាសត្វតិរច្ឆាន ទាំងស្តេចដំរីនេះក៏មានជើង ៤ ទាំងយើងក៏មានជើង ៤ សូម្បីយើងទាំងពីរក៏ស្មើៗ គ្នា មិនមែនឬ ។ បទថា វង្កកំ (នង្គ័លតូច) បានដល់ នង្គ័លតូចៗ សម្រាប់ក្មេងលេង ។ បទថា ឃដិកំ (ឈើហឹង) បានដល់ ល្បែងលេងឈើខ្លីវាយដោយឈើវែង ។ បទថា មោក្ខចិកំ (កន្ត្រាវឈើ) ល្បែងលេងបង្វិលឲ្យវិលជុំវិញ ។ លោកអធិប្បាយថា ល្បែងលេងដែលកាន់ចុងទុកលើអាកាស ដាក់ក្បាលចុះដី ហើយបង្វិលទាំងខាងក្រោមខាងលើ ។ បទថា ចិង្គុលិកំ (កន្ត្រាវស្លឹកឈើ) បានដល់ល្បែងលេងមានកង់ដែលធ្វើដោយស្លឹកត្នោតជាដើម វិលទៅបានព្រោះកម្លាំងខ្យល់ ។ នាឡិស្លឹកឈើហៅថា បត្តាឡ្ហកៈ ពួកក្មេងៗ យកស្លឹកឈើផ្សេងពីនាឡិនោះ វាល់ខ្សាច់លេង ។ បទថា រថកំ ប្រែថា រថតូចៗ ។ បទថា ធនុកំ ប្រែថា ធ្នូតូចៗ ។

ពាក្យថា *វា* ក្នុងបទថា *ឥធ ខោ បន វា* ជានិបាត ។ អធិប្បាយថា ក្នុងលោកនេះឯង ។ ពាក្យថា *ឥង្ឃ* ក្នុងបទថា *ឥង្ឃ ត្វំ ឧបាលិ សង្ឃេ វិហរាហិ* នេះ ជានិបាតចុះក្នុងអត្ថថា ដាស់តឿន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ទើបដាស់តឿនព្រះថេរៈ ដើម្បីប្រយោជន៍ដល់ការនៅកណ្តាលសង្ឃ មិនមែនទ្រង់អនុញ្ញាតការនៅព្រៃដល់ព្រះថេរៈនោះ ។ ព្រោះហេតុអ្វី ។ ព្រោះព្រះសាស្តាទ្រង់ព្រះតម្រិះថា បានឮថាព្រះថេរៈនៅក្នុងសេនាសនៈព្រៃ នឹងបំពេញបានតែវាសធុរៈតែម្យ៉ាង (វិបស្សនាធុរៈ) បំពេញគន្ថធុរៈមិនបាន តែព្រះថេរៈកាលនៅកណ្តាលសង្ឃ បំពេញធុរៈសូម្បីទាំងពីរនេះបាន នឹងសម្រេចព្រះអរហត្ត ទាំងនឹងជាប្រធានក្នុងផ្នែកព្រះវិន័យបិដក ដូច្នោះ តថាគតនឹងពោលសេចក្តីប្រាថ្នាអំពីមុននិងបុណ្យចាស់របស់គេ ហើយស្ថាបនាភិក្ខុនេះទុកក្នុងតំណែងដ៏កំពូលលើពួកភិក្ខុអ្នកទ្រទ្រង់វិន័យត្រង់កណ្តាលបរិស័ទ កាលទ្រង់ឃើញសេចក្តីនេះ ទើបទ្រង់មិនអនុញ្ញាតការនៅព្រៃដល់ព្រះថេរៈ ។

ចប់អដ្ឋកថា ឧបាលិសូត្រទី ៩

# អដ្ឋកថា អភព្វសូត្រទី ១០

*បុគ្គលលះធម៌ ១០ ប្រការ មិនគួរធ្វើ*

*ឲ្យជាក់ច្បាស់ព្រះអរហត្ត*

[១០០] *អដ្ឋកថាអភព្វសូត្រនេះ មានសេចក្ដីងាយហើយ ។*

## ចប់ឧបាសកវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៥ សូត្រ

## ចប់ទុតិយបណ្ណាសកៈ

# ចប់អដ្ឋកថា

# អង្គុត្តរនិកាយ ទសកនិបាត

# ឈ្មោះ

# មនោរថបូរណី

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| -ភិក្ខុ ចៅ សៀប វត្តអូស្ត្រាលី | $ 500 AUS |
| -ភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| -ឧបាសក សោម រតនៈ ព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| -ឧបាសក តាំង សុជល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |